# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៧ លេខ ៩ ខែ កញ្ញា

ព. ស. ២៥០៧ គ. ស. ១៩៦៥

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| ផ្នែកសាសនា | ទំព័រ |
|---|---|
| ១– សិប្បកថា ព្រះឧបាលិវង្ស ម៉ុង-សេស រៀបរៀង | ៨៧៤ |
| ២– កាយចិត្តកថា ព្រះមហា ជា-សុខ រៀបរៀង | ៨៨៧ |
| ៣– កិច្ចកថា ព្រះពុទ្ធត្ថេរ យន់-យូរ វត្តព្រះពុទ្ធមានបុណ្យ រៀបរៀង | ៩០៧ |

| ផ្នែកអក្សរសាស្ត្រ | |
|---|---|
| ៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) | ៩២៣ |
| ៥– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) | ៩២៨ |
| ៦– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. គាម ស្រាវជ្រាវ (ត) | ៩៣៩ |
| ៧– ឯកសារទំនៀមទម្លាប់ខ្មែរ រឿងស្រះយក្សឡោម ខេត្តរតនគិរី | ៩៥០ |
| ៨– ឯកសារ សាស្ត្រាស្ទឹកវិតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) | ៩៥៤ |
| ៩– សិលាចារឹកត្រពាំងរុន លោក ឌ. គាម ស្រាវជ្រាវ (ត) | ៩៧០ |
| ១០– សេចក្តីកត់ហេតុ អំពីការប្រជុំការងារនៅពុទ្ធសាសនបណ្ឌិត្យ | ៩៨៦ |
| ១១– ព្រះរាជក្រឹត្យ | ៩៩១ |



មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារៀល ២៣០រ០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។
ប.ព.

## សិប្បកថា

ព្រះឧបាលិវង្ស ម៉ុង-សេស រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៣ ដង

សូមនមស្ការចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះសង្ឃ ដោយសេចក្ដីគោរព) ។

សូមសម្ដែងអំពី សិប្បកថា តាមទំនងដែលមានមកក្នុងមង្គលសូត្រព្រមទាំងអដ្ឋកថា ល្មមជាតួយ៉ាង ។

ហត្ថកោសល្ល សេចក្ដីឆ្លៀវឆ្លាសប៉ិនប្រសប់ខាងការងារដោយដៃ គឺបេះធ្វើការកើតបានល្អត្រឹមត្រូវ ល្មមគេប្រើបានហៅថា សិប្បៈ ឬ សិល្បៈ ។ សិល្បៈ នេះបើសម្រេចហើយជាការគាប់ប្រសើរក្នុង

លោក ជាហេតុឲ្យបានទ្រព្យសម្បត្តិស័ក្តិយសខ្ពង់ខ្ពស់និងមានកិត្តិសព្ទល្អផ្សាយទៅសព្វទិស ។

៦ សិប្ប: នោះមាន ២ ប្រការគឺ អាគារិយសិប្ប: សេចក្តីឈ្លៀវឈ្លាសប៉ិនប្រសប់ដោយដៃរបស់អ្នកបួស ១ អនាគារិយសិប្ប: សេចក្តីឈ្លៀវឈ្លាសប៉ិនប្រសប់ដោយដៃរបស់គ្រហស្ថ ១ ។

## អនាគារិយសិប្ប:

អនាគារិយសិប្ប: នោះមានសេចក្តីថា ភិក្ខុក្នុងសាសនានេះ មានប្រាជ្ញាឈ្លាសវៃ ចេះធ្វើការងារធំដុំ និងការងារបន្ទាប់បន្សំ ដល់ពួកសព្រហ្មចារីបាន ចេះរៃលកកាត់ដេរជ្រលក់ត្រៃចីវរ និងសមណបរិក្ខារឯទៀត ៗ មានសំពត់និសីទនៈ សំពត់ជូតទឹកភ្លៀងនិងត្រៃគាំងជាដើម ត្រឹមត្រូវតាមបញ្ញត្តិ, ចេះបូកបាយអលាបទឹកកំបោរ ចេតិយ ចេះធ្វើខឿនចេតិយ ខឿនពោធិព្រឹក្ស ធ្វើរោងឧបោសថជាដើម ហៅថាការងារធំដុំ, ភិក្ខុចេះធ្វើកន្ទេលសំពប់លាងជើង វត្ថុសំរាប់ជូតជើងជាដើម ហៅថាចេះធ្វើការងារបន្ទាប់បន្សំ ។ ការចេះដឹងបែបនេះហៅថា នាថករណធម៌ គឺធម៌ធ្វើនូវទីពឹងចំពោះខ្លួន គឺបានសេចក្តីរាប់អានអំពីសំណាក់ឧបជ្ឈាយ៍អាចារ្យនិងព្រះថេរៈធំ ៗ ឯទៀត, ទាំងឧបាសកឧបាសិកាក៏ច្រើនស្រឡាញ់រាប់អានភិក្ខុបែបនេះ តែងទំនុកបំរុងបូជាដោយបច្ច័យទាំង ៤, ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា សិប្ប: បែបនេះជាមង្គលដ៏ឧត្តម ។

# អាគារិយសិប្បៈ

អាគារិយសិប្បៈ សេចក្ដីចៀវឆ្លាសប៉ិនប្រសប់ខាងការងារដោយដៃរបស់គ្រហស្ថនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ជាមង្គលដ៏ឧត្តម ចំពោះការងារណាដែលផុតអំពីការបៀតបៀនសត្វដទៃ ឃ្លាងអំពីអកុ-សលទាំងពួង គឺការងាររបស់ជាងកែវ ជាងមាស ជាងប្រាក់ ជាងស្មិត ជាងឥដ្ឋ-កំបោរ ជាងឈើជាដើម ។

សិប្បៈនេះបានជាព្រះអង្គទ្រង់សំដែងថាជាមង្គល ព្រោះជាហេតុឲ្យបានផលប្រយោជន៍ក្នុងលោកនេះ ដូចមានរឿងរ៉ាវតទៅនេះ ។

ពោធិរាជកុមារ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ បានជួលជាងឈើម្នាក់ឲ្យសាងប្រាសាទ ១ ខ្នងឈ្មោះថា «កោកនទប្រាសាទ» ប្រែថា «ប្រាសាទឈូកក្រហម» ។ ប្រាសាទនោះល្អក្រៃលែងជាងប្រាសាទឯទៀត ៗ ជាប្រាសាទធ្វើមកក្នុងព្រះនគរ ។ វេលាជិតហើយស្រេច ពោធិរាជកុមារមានព្រះបន្ទូលសួរជាងឈើថា ជាងឯងធ្លាប់ធ្វើប្រាសាទបែបនេះច្រើនដងច្រើនគ្រាណាស់មកហើយ ឬក៏ទើបនឹងធ្វើតែម្ដងនេះទេ?

ជាងឈើក្រាបទូលថា ទើបនឹងធ្វើតែម្ដងនេះទេ ។ ពោធិរាជកុមារទ្រង់ព្រះតំរិះថា «ជាងនេះទើបតែនឹងធ្វើប្រាសាទ ១ នេះ ល្អម្ល៉េះទៅហើយ តទៅមុខទៀតមុខតែធ្វើប្រាសាទគេឯទៀត ៗ ល្អជាងប្រាសាទអញមិនខាន បើដូច្នោះគួរអញសម្លាប់ជាងនេះចោលចេញ ឬក៏កាត់ដៃ

ទាល់ ឬផ្ញៀលវែកកាត់ចេញទើបបាន„ ។ លុះគិតហើយ ក៏មានព្រះបន្ទូលប្រាប់រឿងនោះដល់មាណពម្នាក់ឈ្មោះសញ្ជិកាបុត្រ ជាមិត្រសំឡាញ់របស់ខ្លួន ។ សញ្ជិកាបុត្រមានសេចក្ដីអាណិតអាសូរដល់ជាងឈើ ក៏និយាយប្រាប់ដំណើរនោះសព្វគ្រប់ ដល់ជាងឈើដោយស្ងាត់កំបាំង ។ ជាងឈើក៏រកឧបាយនឹងដោះខ្លួនឲ្យរួចអំពីសេចក្ដីវិនាស ។ លុះដល់ពេលតពីនោះមកបានជួបនឹងពោធិកុមារ ។ មានព្រះបន្ទូលសួរថា ប្រាសាទស្រេចហើយឬនៅ? ក្រាបទូលថា នៅមិនទាន់ស្រេចទេ នៅច្រើនណាស់ ហើយក្រាបទូលឲ្យរកឈើស្រាយ ស្ងួត ៗ ជាច្រើនមកឲ្យហាមឃាត់ថាកុំឲ្យមនុស្សណាមួយចូលទៅក្នុងប្រាសាទនោះឲ្យសោះវៀរលែងតែភរិយាខ្លួនមួយដែលនាំយកអាហារទៅឲ្យ ។

ជាងឈើក៏ធ្វើសកុណយន្ត គឺយន្តហោះមានសណ្ឋានដូចសត្វបក្សីដោយឈើស្រាយទាំងនោះ, ខាងក្នុងប្រាសាទ ។ ឯយន្តហោះរបស់ជាងឈើនោះ មានរូបភាពដូចសត្វបក្សីគ្រុឌ ។ ជាងឈើបង្គាប់ភរិយាឲ្យលក់ដូរទ្រព្យសម្បត្តិទាំងអស់ យកសុទ្ធតែមាសនិងប្រាក់រៀបចំដំណើរទុកជាស្រេច លុះសម្រេចសកុណយន្តហើយ ក៏នាំភរិយានិងកូនឡើងជិះសកុណយន្តយកមាសប្រាក់និងទ្រព្យឯទៀតដែលស្រាល ៗ ដាក់ក្នុងសកុណយន្តទាំងស្វាមីភរិយានិងកូនបើកសកុណយន្ត ហោះចេញតាមបង្អួចប្រាសាទ ហោះទៅកាន់ប្រទេសព្រៃហិមពាន្ត ទៅចុះត្រង់ទីកន្លែង ១ ដ៏

សមគួរ បានសាងទីក្រុង ១ ត្រង់កន្លែងនោះ ៗ លុះនៅក្នុងទីក្រុងនោះយូរៗទៅ ជាងឈើបានសោយរាជ្យ ជាស្ដេចក្នុងនគរនោះព្រះនាមថា តាដួភៈ ហាងកាជ បានថ្កុំថ្កើងរុងរឿងដរាបដល់អស់ព្រះជន្ម ៗ

សំដែងរឿងនេះដើម្បីញុំាងសាធុជនឲ្យជ្រាប អំពីកំឡាំង ហត្ថ-កោសល្យ សេចក្ដីឆ្លៀវឆ្លាសប៉ិនប្រសប់ដោយដៃដែលហៅថាសិប្បនោះ អាចឲ្យប្រយោជន៍គឺសេចក្ដីសុខចំរើន ស័ក្តិយសទ្រព្យសម្បត្តិក្នុងលោកនេះពិតប្រាកដ ៗ

ន័យមួយទៀត ក្នុងកម្ពុជរដ្ឋយើងនេះ អ្នកកាន់ព្រះពុទ្ធសាសនាមានចំនួនច្រើន អ្នកខ្លះមានសេចក្ដីសង្ស័យដដែលគ្នាថា ខ្មែរយើងធ្វើបុណ្យធ្វើទានច្រើនជាងគេ ហេតុអ្វីក៏ក្រខ្សត់ទ្រព្យសម្បត្តិជាងគេ ? ជាតិដទៃគេមិនសូវធ្វើបុណ្យធ្វើទានទេ ខ្លះគ្មានធ្វើសោះ ហេតុអ្វីក៏គេច្រើនមានទ្រព្យសម្បត្តិជាងយើង ?

សូមឆ្លើយតបប្រស្នានេះ ឲ្យឃើញថាបុណ្យក័ព្វព្រេងសំណាងនិងសិប្បៈមានលក្ខណការណ៍ផ្សេងគ្នាទេ, ដូចមានសេចក្ដីតទៅនេះ :

ព្រះសព្វញ្ញុពុទ្ធទ្រង់ជ្រាបហេតុផលសព្វគ្រប់ ទ្រង់សំដែងមង្គលសូត្រត្រង់គាថាទី ២ ត្រង់មង្គលទី ៥ ថា បុព្វេ ច កតបុញ្ញតា ការកសាងបុណ្យកុសលអំពីជាតិមុនៗមក, ក៏បានជាមង្គលក្នុងបច្ចុប្បន្ននេះ គឺបរិបូណ៌ដោយទ្រព្យសម្បត្តិ ស័ក្តិយសធំខ្ពង់ខ្ពស់ក្នុងលោកនេះ ៗ ព្រះ-

អដ្ឋកថាបាឡីលោកទាញរឿងរ៉ាវមកអាងដូចមានតទៅនេះ ព្រះបាទគោកាកវណ្ណតិស្សមហារាជ បានសោយរាជ្យក្នុងរោហនជនបទ ទីក្រុងឈ្មោះ មហាគ្រាម, លុះទ្រង់សោយព្រះទិវង្គតទៅ មានព្រះរាជបុត្រមួយព្រះអង្គព្រះនាម ទុដ្ឋគាមណីអភ័យ សោយរាជ្យស្នងព្រះបិតាឡើង ។ សម័យជាខាងក្រោយ ព្រះបាទទុដ្ឋគាមណីអភ័យ ទ្រង់ស្តេចយាងចេញអំពីរោហនជនបទ ទ្រង់ធ្វើគុតស្តេច ទមិឡ ១ ព្រះអង្គព្រះនាម ឯឡារៈ ហើយទ្រង់បានឡើងជាឯករាជ ទ្រង់គង់នៅក្នុងអនុរាធបុរី លង្កាទ្វីប ។ ក្នុងគ្រាកាលដែលព្រះសម្ពុទ្ធបរិនិព្វានហើយកន្លងទៅបាន៣៧២ឆ្នាំ ព្រះបាទទុដ្ឋគាមណីអភ័យ មានបុណ្យអស្ចារ្យ មានកំណប់ទ្រព្យជាច្រើនផុសឡើងសំរាប់ព្រះអង្គ ក្នុងទីជុំវិញនៃក្រុងអនុរាធបុរី ព្រោះបានកសាងបុណ្យកុសលទុកមកអំពីជាតិមុន ៗ ។

១- ខាងភាគទិសក្បៀសានប្រមាណ ៣ យោជន៍ អំពីក្រុងអនុរាធបុរី ក្នុងស្រុកមួយឈ្មោះ អាចរវិដិគ្រាម មានដុំមាសជាច្រើនប្រវែង ១ ចំអាមក៏មាន ១ អង្គុលីក៏មាន ផុសឡើងលើផែនដីប្រមាណ ១៦ ការីស(១) ត្រូវជា ២.០០០ ហត្ថ ។

---

១– បញ្ចវីសសតំ ហត្ថា ករីសន្តិ មតំ តថា
ចតុសដ្ឋី ច តំ ការី ការី ចត្តារិ យោជនំ
ប្រែថា : ១២៥ ហត្ថ ហៅថា ១ ករីស ៦៤ ករីស ត្រូវជា ១ ការុត ៤ ការុត ត្រូវជា ១ យោជន៍ ។

២- ខាងភាគទិសឦសានប្រមាណ ៧ យោជន៍ ក្នុងជនបទមួយឈ្មោះ តម្ពបិដ្ឋ ត្រើយខាងនាយនៃស្ទឹងគង្គា មានទង់ដែងជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៣- ខាងភាគទិសអាគ្នេយ៍ប្រមាណ ៤ យោជន៍ ក្នុងស្រុកមួយឈ្មោះកាបិត្រាម មានកែវមណីជាច្រើនផុសឡើងលើផ្ទៃផែនដី ។

៤- ខាងភាគទិសឦសានប្រមាណ ៨ យោជន៍ ក្នុងអម្ពដ្ឋកោលជនបទ មានប្រាក់ផុសឡើងក្នុងគុហា ១ ។

៥- ខាងភាគទិសពាយព្យប្រមាណ ៥ យោជន៍ ក្នុងកំពង់ ១ ឈ្មោះឧរុវេលៈ មានកែវមុក្តាជាច្រើន ទំហំប៉ុនផ្លែកន្ទួតព្រៃខាងតូច មានទ្រង់ទ្រាយដូចផ្លែកន្ទួតព្រៃចំនួន ៦០ រទេះធំ ព្រមទាំងកែវប្រពាឡផង ផុសឡើងនៅលើគោក ។

៦- ខាងភាគទិសឦសានប្រមាណ ៧ យោជន៍ អំពីអនុរាធបុរី មានកែវមណី ៤ ដុំ មានសម្បុរដូចផ្កាត្រកៀត ប្រវែង ១ ចំអាម ៤ ធ្នាប់ ទំហំប៉ុនថូសម្រាប់កិនយ៉ាងតូច ផុសឡើងនៅលើផ្នែកខ្សាច់ ក្នុងស្ទឹងតូច ១ ដែលហូរកាត់ស្រុក ១ ឈ្មោះបេឡិវាបិតាគ្រាម ចុះទៅក្នុងបឹង ១ ។

មនុស្សទាំងឡាយដែលបានឃើញមាសជាដើមផុសឡើងដូច្នោះ ក៏នាំគ្នាមកក្រាបបង្គំទូលព្រះបាទ ទុដ្ឋគាមណីអភ័យ ៗ ក៏មានព្រះរាជឱង្ការត្រាស់បង្គាប់ ឲ្យដឹកទាំងពួនមកដាក់ជាព្រះរាជទ្រព្យក្នុងព្រះ

ឃ្លាំងរបស់ព្រះអង្គ ៗ នេះជាផលរបស់បុណ្យ ភ័ព្វព្រេងសំណាងព្រះមហាក្សត្រអង្គនេះ ទ្រង់បានកសាងទុកមកអំពីជាតិមុន មិនមែនកើតដោយកម្លាំងព្យាយាម ឬវិជ្ជាសិល្បសាស្ត្រ ក្នុងបច្ចុប្បន្ននេះទេ ៗ

ឯ សិប្បៈមង្គលទី ៨ គាថាទី ៣ ក្នុងមង្គលសូត្រនេះ ដូចបានសម្តែងមកហើយខាងដើមនោះ និយាយតែចំពោះវិជ្ជាសិល្បសាស្ត្រដែលសម្រេចហើយក្នុងបច្ចុប្បន្ននេះ អាចឲ្យផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ដូចជាព្រះ-បាទ តារដ្ឋវាហានរាជ នោះឯង ៗ មនុស្សក្នុងលោកនេះ ទោះជាតិណាក៏ដោយ ប្រទេសណាក៏ដោយ ដែលមានទ្រព្យសម្បត្តិថ្កុំថ្កើងរុងរឿងមិនមែនសុទ្ធតែសម្រេចមក អំពីការកសាងបុណ្យកុសលអំពីជាតិមុនទាំងអស់ទេ សម្រេចមកអំពីវិជ្ជាសិល្បសាស្ត្រក្នុងបច្ចុប្បន្ននេះក៏មានដោយច្រើន, ព្រោះហេតុនោះហើយបានជាប្រទេសធំ ៗ ឯទៀត គេខំប្រឹងប្រែងរៀនវិជ្ជាគ្រប់មុខបានចេះដឹងច្រើន បានទៅជាអ្នកមានទ្រព្យសម្បត្តិច្រើនថ្កុំថ្កើងរុងរឿងជាងប្រទេសដែលល្ងង់ខ្លៅ ៗ មួយយ៉ាងទៀត មានសម្តែងក្នុងគម្ពីរព្រះ-ពុទ្ធសាសនា ក្នុងទីឯទៀតថា បុគ្គលអ្នកមានបុណ្យភ័ព្វ ច្រើនតែអន្ទោលទៅចាប់កំណើតកើតក្នុងត្រកូលស្តុកស្តម្ភក្នុងប្រទេសធំ ៗ សមទឹងបុណ្យដែលខ្លួនបានកសាងទុកមក ៗ បើមកកើតក្នុងត្រកូលខ្សត់ខ្សោយក្នុងប្រ-ទេសតូច ៗ ដែលក្រីក្រទ្រព្យធនធ្វើម្តេចទឹងសមតាមទំនងបុណ្យភ័ព្វ?

ការឆ្លើយតបប្រស្នាចប់តែប៉ុណ្ណេះ ៕

ម្យ៉ាងទៀត អ្នកដែលប្រកបដោយវិជ្ជាសិល្បសាស្ត្រ មិនត្រឹមតែបានផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ, បើបានជួបប្រទះទីងស្រែបុណ្យល្អ បានបណ្តុះពូជបុណ្យទៅក្នុងស្រែបុណ្យនោះ ទឹងបានផលប្រយោជន៍ច្រើនក្នុងបរលោកទៀតផង បានសម្រេចប្រយោជន៍ដ៏ឧត្តមគឺមគ្គផលនិព្វានផងទៀត ដូចមានរឿងក៏តទៅនេះ

ក្នុងកាលកន្លងទៅហើយ ឃោតា ឆឡ្យកាពោ មានជាងត្បាញកន្ទេលបបុសម្នាក់ នៅក្នុងនគរពារាណសី, ថ្ងៃ ១ ជាងនោះដើរទៅកាន់ស្រែបានជួបនឹងព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ ក៏បង្គាប់ទាសកម្មករឲ្យទៅធ្វើការងារក្នុងស្រែ, ឯអាត្មាឯងត្រឡប់មកផ្ទះវិញនិមន្តព្រះបច្ចេកពុទ្ធឲ្យនាទក្នុងផ្ទះ ហើយក៏និមន្តទៅកាន់ឆ្នេរទន្លេគង្គា ទៅជាមួយនឹងកូនប្រុសម្នាក់ផងបានសង់បណ្ណសាលាគឺសាលាប្រក់ស្លឹក ១ ខ្នង យកឈើឧទុម្ពរធ្វើជាជើងជញ្ជាំង យកកន្ទេលបបុសធ្វើជាជញ្ជាំង ធ្វើទីចង្ក្រមណ៍១ ផង,និមន្តព្រះបច្ចេកពុទ្ធឲ្យគង់នៅក្នុងបណ្ណសាលានោះអស់ ៣ ខែ ។ ជនទាំង២នាក់គឺបិតានិងបុត្រប្រុសបានប្រគេនត្រៃចីវរដល់ព្រះបច្ចេកពុទ្ធដែលគង់ចាំវស្សារួចហើយ បានគោរពប់អានទំនុកបំរុងបូជាព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គដទៃទៀត ដូចព្រះបច្ចេកពុទ្ធ ១ អង្គមុននោះដែរ ។ ជនទាំង ២ នាក់គឺបិតានិងបុត្រប្រុសលុះធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងពិភពតាវត្តឹង្សសោយទិព្វសម្បត្តិក្នុងឆកាមាវចរសួគ៌ ជាអនុលោមនិងបដិលោម ។

ចំណែកខាងទេវបុត្រជាបិតាស្ថិតនៅក្នុងទេវលោកដដែល ចំណែកទេវបុត្រជាបុត្រប្រុសក៏ច្យុតចុះមកចាប់កំណើតក្នុងផ្ទៃនាងសុមេធាទេវី ជាមហេសីនៃព្រះបាទ សុរុចិរាជ ក្រុងមិថិលា ដែនវិទេហៈគ្រប់កំណត់១០ ខែ ក៏ប្រសូតមក គេថ្វាយព្រះនាមថា មហាបនាទកុមារ, លុះមានព្រះជន្មាយុ ១៦ ឆ្នាំ ក៏បានសម្រេចវិជ្ជាសិល្បសាស្ត្រគ្រប់ប្រការ ។ ព្រះរាជបិតាទ្រង់ត្រាស់បង្គាប់ពួកវត្ថុវិជ្ជាចារ្យ គឺអាចារ្យដែលចេះមើលទីដីសង់ផ្ទះថា អ្នករាល់គ្នាចូលនាំយកជាងមកសាងប្រាសាទ ឲ្យកូនរបស់អញ អញនឹងអភិសេកកូនអញឲ្យសោយរាជ្យ ។ ពួកវត្ថុវិជ្ជាចារ្យក៏ទទួលព្រះរាជឱង្ការ ហើយពិចារណាមើលប្រទេសផែនដីដោយសព្វគ្រប់ ក៏កើតក្ដៅរំជួលដល់អាស្នាព្រះឥន្ទ្រាធិរាជមួយរំពេចភ្លាម ដោយអានុភាពបុណ្យរបស់ មហាបនាទកុមារ នោះ ៗ ព្រះឥន្ទ្រាធិរាជទ្រង់ជ្រាបការណ៍នោះសព្វគ្រប់ ទ្រង់ប្រើព្រះវិស្សុកម្មទេវបុត្រឲ្យចុះមកសាងប្រាសាទថ្វាយ មហាបនាទកុមារ ។ ព្រះវិស្សុកម្មទេវបុត្រក៏កៀសខ្លួនជាមេជាងមកកាន់សំណាក់ពួកជាង បញ្ជូនពួកជាងឲ្យត្រឡប់ទៅកាន់ឋានលំនៅរៀងខ្លួន ហើយយកដំបងវាយផែនដី ក៏ស្រាប់តែមានប្រាសាទកែវ ៧ ប្រការ មានសណ្ឋាន ៤ ជ្រុងស្មើភាគគឺ ទទឹងកន្លះយោជន៍ បណ្ដោយកន្លះយោជន៍ កំពស់ ២៥ យោជន៍មានជាន់ ៧ ផុសឡើងភ្លាមមួយរំពេចៗ មហាបនាទ ស្ដេចគង់នៅជាសុខសម្រាន្តក្នុងប្រាសាទកែវជាអស្ចារ្យ

នោះបានធ្វើបុណ្យមានទានជាដើម ។ លុះទ្រង់សោយព្រះទិវង្គតទៅ ក៏បានទៅកាន់ស្ថានសួគ៌ទេវលោកវិញ ។ ប្រាសាទនោះក៏ស្រុតលិចចុះទៅក្នុងទន្លេគង្គា ។ គេបានសាងទីក្រុងមួយ ឈ្មោះ បយាគប្បតិដ្ឋាន ចំត្រង់ដំណើរប្រាសាទនោះ មានស្រុកមួយឈ្មោះ កោដិគ្រាម នៅចំត្រង់កំពូលប្រាសាទនោះ ។ លុះដល់មកក្នុងពុទ្ធុប្បាទយើងនេះ នឡការទេវបុត្រ ជាកូននោះ ក៏ច្យុតអំពីទេវលោក មកកើតជាកូននៃ ភទ្ទិយសេដ្ឋី ក្នុងទីក្រុងភទ្ទិយៈ គេឲ្យឈ្មោះថា ភទ្ទជិ-កុមារ ។ គ្រានោះព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្ត ជាតិ-យាវ័ន អាស្រ័យនៅទីក្រុងភទ្ទិយៈ ។ ពួកជនដែលនៅក្នុងទីក្រុងបាននាំគ្នាសាងមណ្ឌបសម្រាប់ធ្វើទាន ត្រង់កណ្តាលទីក្រុង ហើយថ្វាយទានដ៏ច្រើន ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចរួចហើយ ទ្រង់ធ្វើអនុមោទនាក្នុងមណ្ឌបនោះ ។ ភទ្ទជិកុមារ ក៏ចូលទៅគាល់ព្រះសាស្តា បានស្តាប់ធម៌ក៏បានសម្រេចអរហត្តផល ទៅកាន់វត្តជាមួយនឹងព្រះសាស្តា ចូលបួសបានឧបសម្បទាជាភិក្ខុ ។ ព្រះសាស្តាទ្រង់គង់ក្នុងវត្ត ជាតិយាវ័ននោះបាន ៧ ថ្ងៃ ទ្រង់ស្តេចទៅកាន់ចារិក បានស្តេចទៅដល់កោដិគ្រាម លុះធ្វើភត្តកិច្ចរួចហើយ ក៏ធ្វើអនុមោទនា ។ ភទ្ទជិថេរ កាលដែលកំពុងធ្វើអនុមោទនា ក៏ចេញទៅខាងក្រៅស្រុក អង្គុយចូលឈានក្រោមម្លប់ឈើ ជិតកំពង់ទន្លេគង្គា ដោយគិតថា «នឹងក្រោកឡើងក្នុងពេលដែល

ព្រះសាស្តាស្តេចយាងមក» ។ កាលដែលមានព្រះថេរចាស់ ៗ និមន្តមកមិនបានក្រោកឡើង លុះដល់ពេលដែលព្រះសាស្តាស្តេចយាងមកដល់ទើបក្រោកឡើងតែម្តង ។ ពួកភិក្ខុជាបុថុជ្ជននាំគ្នាពោលទោសកុទ្ទិត្ថេរថាមិនគោរពព្រះថេរៈចាស់ ៗ ។ ព្រះសាស្តាទ្រង់ស្តេចទៅគង់លើទូកឃ្លាប មានព្រះបន្ទូលហៅកុទ្ទិត្ថេរ ឲ្យឡើងជិះទូកជាមួយនឹងព្រះអង្គ, កុទ្ទិត្ថេរក៏ហោះឡើងហើយចុះគង់លើទូក ១ ។ ព្រះសាស្តាមានព្រះបន្ទូលសួរក្នុងពេលដែលទូកទៅដល់ពាក់កណ្តាលទន្លេគង្គាថា នែកុទ្ទិប្រាសាទដែលលោកធ្លាប់អាស្រ័យនៅ ក្នុងកាលដែលលោកសោយរាជ្យជាស្តេចឈ្មោះ មហាបនាទ នោះ តើនៅត្រង់កន្លែងណា ? កុទ្ទិត្ថេរក្រាបបង្គំទូលថា ប្រាសាទនោះលិចចុះទៅត្រង់កន្លែងនេះ ។ លុះក្រាបបង្គំទូលហើយថ្វាយបង្គំព្រះសាស្តារួចចុះទៅដោយកម្លាំងឫទ្ធិ យកម្រាមដៃចុកកំពូលប្រាសាទហោះទៅឰដ៏អាកាស បង្ហាញឲ្យឃើញពល់គ្នាហើយលែងទៅវិញ ដើម្បីកាត់នូវសេចក្តីសង្ស័យរបស់បុថុជ្ជន ។ ប្រាសាទនោះក៏ធ្លាក់ទៅនៅត្រង់កន្លែងដដែលវិញ គ្មានអន្តរាយខូចខាតរហូតដល់មកសព្វថ្ងៃនេះ ។

សួរថា ប្រាសាទនោះហេតុអ្វីបានជាមិនទាន់អន្តរាយ?

ឆ្លើយថា ដោយអានុភាពនៃនឡការទេវបុត្រជាបិតាដើម ។ ព្រោះថា នឡការទេវបុត្រ នោះនឹងបានជាព្រះរាជាចក្រពត្តិព្រះនាមសង្ខៈក្នុង

អនាគត ប្រាសាទនោះនឹងផុសឡើង សំរាប់ព្រះពេជានោះ, ដោយហេតុនេះបានជាមិនទាន់អន្តរាយ ។

សម្តែងរឿងនេះដើម្បីបញ្ជាក់អំពីកម្លាំងវិជ្ជាសិល្បសាស្ត្រ ដែលប្រកបដោយធម៌ បើបង្អោនទៅរកបុណ្យកុសលនឹងបានផលប្រយោជន៍ទៅក្នុងអនាគត នឹងបានខ្ពង់ខ្ពស់រុងរឿងក្នុងមនុស្សលោកនិងទេវលោក បានសម្រេចព្រះនិព្វានក្នុងជាតិជាទីបំផុត ។

ចប់ សិប្បកថា

មនុស្សល្ងង់ តែងជួបប្រទះ ទង្គិចហេតុដែលនាំឲ្យកើតសេចក្តីសោកមួយពាន់ដង ឬហេតុនាំឲ្យកើតភ័យមួយរយដង ក្នុងមួយថ្ងៃ ៗ តែអ្នកប្រាជ្ញជួបប្រទះទង្គិចហេតុដូច្នេះឥតអង្គីមានឡើយ ។

ស្រីហិតោបទេស

# កាយចិត្តកថា

ព្រះមហា ជា·សុខ

រៀបរៀង

មនុស្សយើងមានគ្រឿងប្រកបសំខាន់ ២ យ៉ាងគឺ កាយ និង ចិត្ត។ វត្ថុទាំងពីរនេះ អាស្រ័យគ្នាទៅវិញទៅមក ប្រៀបដូចជាគ្រួសារមួយ, តែងមានការចំរើន និងការវិនាសជាប់ទាក់ទងគ្នា មានផលប្រយោជន៍រួមគ្នា ផ្សេងតែឧបករណ៍ដែលមកជាជំនួយប៉ុណ្ណោះ ។

កាយ បានដល់អ្វី ? បានដល់រូប, គឺខ្លួនយើងនេះឯង ដែលប្រកបដោយគ្រឿងផ្សំ គឺក្បាល ១ ដៃ ២ ជើង ២ ។

ចិត្ត បានដល់អ្វី ? បានដល់វត្ថុម្យ៉ាង ដែលមានសមត្ថភាពក្នុងការគិត, ការពិចារណា នូវហេតុការណ៍ផ្សេង ៗ ឧទាហរណ៍ដូចជាគិតទៅស្រុកនេះ - ស្រុកនោះ, គិតកែខៃស្ថានការណ៍ដែលនៅជុំវិញខ្លួន, គិតចង់បានវត្ថុនេះ វត្ថុនោះ ។

## អាហាររបស់កាយ

វត្ថុមានជីវិតទាំងអស់ រមែងត្រូវការអាហារ, អាហារជាបច្ច័យនៃជីវិតសំខាន់បំផុត ខានមិនបាន, ដើមឈើមិនមានមាត់ដូចមនុស្សសត្វ គង់ត្រូវការអាហារដូចជាយើងដែរ ។

ដើមឈើត្រូវការអាហារបែបណា ? ដោយវិធីដូចម្ដេច ?

ដើមឈើទាំងឡាយ រាប់តាំងពីស្មៅរហូតដល់ឈើធំ ៗ មានស្វាយ, គគីរ, ឈើទាលជាដើម មានឫសសំខាន់ពីរបែប គឺឫសរយោងដុះញែកពីគល់ចេញទៅខាង ដូចជាចន្ទល់សម្រាប់ទប់ដើមឲ្យនៅនឹង ឬឈរបាន; ឫសមួយទៀតចាក់ចុះត្រង់ទៅក្នុងដីជ្រៅ ដែលហៅថា ឫសកែវ ។ ឫសកែវនេះ សម្រាប់ស្រូបយកជីជាតិអំពីដី និងទឹក ដើម្បីនាំទៅចិញ្ចឹមដើម មែក ធាងរបស់វា មិនតែប៉ុណ្ណោះ ដើមឈើត្រូវការខ្យល់អាកាស ដោយស្រូបខ្យល់អាកាសតាមស្លឹករបស់វាយកទៅបម្រុងទៀតផង, បើមិនមានវត្ថុទាំងនេះទេ ដើមឈើគ្រប់ចំពូកនឹងរស់នៅពុំបាន ។

មនុស្សត្រូវការអាហារច្រើនលើសលប់ជាងដើមឈើទៅទៀត ព្រោះមនុស្សមានឧបករណ៍នៃជីវិត វិចិត្រពិស្ដារណាស់ ។ អាហារដែលមនុស្សត្រូវការ តើអាហារបែបណា ? រឿងអាហារនេះ យើងគ្រប់គ្នាស្គាល់ច្បាស់ហើយ តែបើនិយាយបោះយកត្រង់សំខាន់ ៗ មានបីប្រភេទ :

១- អាហារកើតអំពីអង្ករ, ផ្លែឈើ, មើមដូចជាដំឡូង, ត្រាវ, សណ្ដែកជាដើម ។

២- អាហារកើតអំពីត្រី, សាច់ និងអន្លក់ផ្សេង ៗ មានស្ពៃ, សាលាដ, សណ្ដែកបណ្ដុះជាដើម ។

៣- អាហារកើតអំពីប្រេង, ខ្លាញ់, ទឹកដោះសត្វជាដើម ។

នៅមានវត្ថុខ្លះទៀត ជាអាហាររបស់កាយ ដូចជា :

ទឹក ជាវត្ថុដែលរាងកាយត្រូវការជាអតិបរមា ព្រោះតួកោសិកា (Cells)គ្រប់តួរួមទាំងឈាមផង មានទឹកលាយឡំនៅប្រមាណ៨ភាគរយ, ទឹកជួយរំលាយអាហារបានយ៉ាងស្រួល; ធ្វើឲ្យអាហារ និងរ៉ែធាតុផ្សេងៗ ក្នុងកាយអណ្តែតឡើង ហើយជ្រួតជ្រាបទៅបម្រុងកាយ ។

រ៉ែធាតុ ដូចជាជាតិអំបិល ជាតិដែកជាដើម ជាវត្ថុសម្រាប់រក្សាក្រុត (Acid)របស់ទឹកក្នុងកាយឲ្យគង់នៅ ហើយ ជួយរក្សាឆ្អឹងឲ្យមាំមួនជាដរាប ។

វីតាមីន ជាវត្ថុសំខាន់ណាស់ មនុស្សតាំងពីកើតរហូតដល់ស្លាប់ នឹងចំរើនបាន ក៏ដោយសារមានជាតិវីតាមីនក្នុងកាយគ្រប់គ្រាន់ ។ វីតាមីនធ្វើកាយឲ្យមាំ, ចក្ខុប្បសាទថ្លាស្អាត, ឲ្យឃ្លានបាយ, ការពារមិនឲ្យកើតរោគសើស្បែក, ធ្មេញពុក, រាក់ប៊ីធ្មេញ, ឆ្អឹងស្រួយ, ឆ្អឹងទន់, ស្ពឹក ជាដើម ។

វត្ថុទាំងនេះ ជាអាហាររបស់កាយ ជួយបម្រុងកាយឲ្យចំរើនធាត់ធំ ប្រកបការងារបានតាមត្រូវការ ។

## អាហាររបស់ចិត្ត

ចិត្តជាធម្មជាតិមានរូបរាង (មានតែឈ្មោះហៅ) តែជាវត្ថុត្រូវការអាហារ ដូចជាកាយដែរ ប៉ុន្តែគ្រាន់អាហាររបស់ចិត្ត ជាវត្ថុមិនមានរូបប៉ុណ្ណោះ ។ អាហាររបស់ចិត្តបានដល់អ្វី ? ធម៌ជាអាហាររបស់ចិត្ត;

ចិត្តអាស្រ័យធម៌, ចិត្តផ្តិតយកធម៌, ចិត្តសន្សំធម៌ ។

ធម៌ក្នុងទីនេះ សំដៅយកសភាវៈល្អ, ការប្រសើរ ដូចជាសេចក្តីអាណិតអាសូរ, ការអត់ធ្មត់, ព្យាយាម; ខ្មាសសេចក្តីអាក្រក់, ខ្លាចផលនៃសេចក្តីអាក្រក់, ការប៉ិនប្រសប់, ការទឹងធឹង, ការស្គាល់ហេតុផលជាដើម ។

មនុស្សមានចិត្តកាចឃោរឃៅ ការប្រព្រឹត្តិរបស់អ្នកនោះ ក៏ឃោរឃៅ បើមានចិត្តល្អមេទម ចរិយាក៏រៀបរយតាម, ហេតុនោះ ដើម្បីការពារការប្រព្រឹត្តិអាក្រក់ មិនសមរម្យ ត្រូវអប់រំចិត្តឲ្យមានមេត្តាប្រណីឡើងឲ្យចេះស្រឡាញ់អំពើល្អ ប្រព្រឹត្តតាមគន្លងធម៌ មិនបំពានលើសិទ្ធិអ្នកដទៃ ស្គាល់ប្រយោជន៍ខ្លួន និងអ្នកដទៃ ប្រើយោនិសោមនសិការៈគ្រប់វេលា ។ ចិត្តកាលផ្តិតយកសេចក្តីល្អទាំងនេះបាន ឬមានធម៌មកបម្រុងរក្សា ឈ្មោះថាចិត្តបានទទួលអាហារ រមែងជាចិត្តមានកម្លាំងរឹងប៉ឹង ចំរើន, ស្អាត មិនរសេមរសាម អាចការពារកាយដែលខ្លួនអាស្រ័យនៅនោះ មិនឲ្យប្រព្រឹត្តអំពើអាក្រក់ផ្សេង ៗ បាន ។

## រោគកាយ

វត្ថុក្នុងលោក តែងមានគូប្រយុទ្ធប្រឆាំងគ្នាជាដរាប ដូចជា សុខៈ មាននៅត្រង់ណា ទុក្ខ តែងមាននៅត្រង់នោះផង, ការចំរើនមានក្នុងទីណា ការវិនាសតែងមានក្នុងទីនោះផង, ជាតិមានការស្លាប់ជាគូ

ទំនាស់ ៗ កាយបានចំរើនធាត់ធំហើយ ជាធម្មតា ត្រូវតែមានការទ្រុឌទ្រោម; វិនាសទៅវិញ នេះជាសភាវធម៌មាននៅប្រចាំលោក ៗ ចុះអ្វីធ្វើកាយឲ្យទ្រុឌទ្រោម-វិនាស ? គឺរោគ, រោគជាសភាវៈធ្វើកាយឲ្យស្គាំងស្គម-វិនាស ៗ អ្វីហៅថា «រោគ», ពាក្យថា «រោគ» នេះ យើងអាចដឹងបានដោយងាយ ព្រោះធ្លាប់ប្រទះមកគ្រប់គ្នាហើយ បើនឹងប្រែ គួរប្រែថា «ជំងឺ» ការឈឺចាប់ ៗ ឃ្លង់; ដំបៅ, ពក; គម, ប៉ូស, រិលមុខ, ចុកចង្កេះ, ស្ពឹក ជាដើម ហៅថា រោគ ៗ កាយដែលមានអាការៈទាំងនេះ ហៅថាកាយមានរោគ, កាយត្រូវរោគជះជាន់ហើយ រមែងជាកាយពិការ អន់កម្លាំង ស្គាំងស្គម, ប្រកបការងារក៏មិនបានស្រួល រោគបន្ថយអាយុជីវិតសត្វឲ្យខ្លី, កាយណាត្រូវរោគជះជាន់ញឹកញាប់ គឺឈឺច្រើន កាយនោះចាស់ក៏ឆាប់ ស្លាប់ក៏ងាយ ៗ

## រោគចិត្ត

ចិត្តមានធម្មជាតកម្លាំង ដែលយើងមើលមិនឃើញ មិនមានអ្វីមកប្រៀបផ្ទឹមបាន មានអំណាចលើសលប់អ្វីទាំងអស់ មានឥទ្ធិពលវិសេសជាងវត្ថុផងទាំងឡាយ មានតម្លៃប្រសើរជាងមាសពេជ្រ ធម្មជាតនេះក៏គឺ «កម្លាំង» នៃចិត្ត, មនុស្សមានកម្លាំងចិត្តខ្លាំង រមែងធ្វើគុណប្រយោជន៍ឲ្យខ្លួនឯង និងអ្នកដទៃ បានច្រើនណាស់ ៗ អ្នកដែលមានកម្លាំងចិត្តខ្សោយ ធ្វើគុណប្រយោជន៍ឲ្យខ្លួនឯង និងអ្នកដទៃ បានតិចតួច

ណាស់ ដូនកាលមិនបានអ៊ូសោះ ទាំងនេះក៏ព្រោះចិត្តរបស់អ្នកនោះពិការ ដោយសាររោគគ្របសង្កត់ ។

រោគចិត្តនេះ មានឫទ្ធិខ្លាំងជាងរោគកាយ, កើតបានឆាប់រហ័ស ដូចផ្លេកបន្ទោរ, អាចរីកអាការក្នុងមួយរំពេចបានធំជាងភ្នំទៅទៀត ។ ក្នុងមួយថ្ងៃ ៗ រោគចិត្តអាចកើតបាន ១០០ មុខ ឬ ១០០ បំពូក ។ តែ ពាក្យថា «រោគ» របស់ចិត្តនេះ អ្នកប្រាជ្ញខាងពុទ្ធសាសនា មិននិយម ហៅ, លោកនិយមហៅថា «កិលេស» ដូច្នេះទៅវិញ ។

ចិត្តដែលត្រូវរោគគឺកិលេសរុករាន មានអាការបញ្ចេញមកឲ្យប្រាកដ ច្រើនបែប ច្រើនយ៉ាងណាស់ តែគួរសំខាន់ជាងគេគឺ :

១_ លោភ: សេចក្តីប្រាថ្នា, ការចង់បាន ។

២_ ទោស: គិតប្រទូសរ៉ាយ ។

៣_ មោហ: វង្វេង ។

រោគទាំង ៣ នេះ ជាគូសត្រូវធំបំផុត បំផ្លាញសុខភាព ទ្រព្យ យសស័ក្តិមនុស្សយើងឲ្យវិនាសច្រើនឥតគណនា ។

១_ លោភ: មនុស្សយើងតែងមានសេចក្តីប្រាថ្នា - ចង់បានវត្ថុ ដែលខ្លួនត្រូវការជាប្រក្រតី ។ ការចង់បាននេះកើតក្នុងចិត្ត ដោយហេតុ ចិត្តបានប្រទះនឹងឥដ្ឋារម្មណ៍ កាលកើតមានច្រើនឡើង ៗ ក៏បិទបាំងចិត្ត មិនឲ្យនឹកគិតដល់បុណ្យ បាប, ត្រូវ ខុស មានតែចង់បានចំណែកមួយ,

គតិនេះទៅ ចិត្តក៏ខ្វល់ខ្វាយរកវត្ថុដែលចង់បាននោះដោយវិធីផ្សេង ៗ ជាការលួចខ្លះ ជាការសម្លាប់គេខ្លះ ប្រព្រឹត្តខុសប្រពៃណីលោកខ្លះ និយាយកុហកខ្លះ តាមតែឃើញថា ប្រើវិធីណាបានផលប្រយោជន៍ដល់ខ្លួន ត្រង់គេឯទៀតសុខទុក្ខយ៉ាងណា ៗ នោះឥតគិតឡើយ ។

លោកធម៌នេះ អ្នកកាន់ពុទ្ធសាសនា មានការយល់ពុំសូវស្របគ្នាទេ អ្នកខ្លះថា ការចង់បាននេះជាតួលោភៈ អ្នកដែលមានការចង់បាន ឈ្មោះថាអ្នកមានលោភៈ, មនុស្សដែលខំប្រឹងរកស៊ី ព្រោះត្រូវលោភៈជំរុញឲ្យធ្វើ, អ្នកខ្លះបដិសេធទស្សនៈនេះ បើដូច្នេះ យើងនឹងដោះស្រាយដូចម្ដេច ? តើទស្សនៈណាខុស ? ទស្សនៈណាត្រូវ ? ។

ជាបឋម យើងគួរពិចារណាពាក្យថា „សេចក្ដីប្រាថ្នា, ការចង់បាន,, សិន មុននឹងវិនិច្ឆ័យរឿងនេះ ។

ការប្រាថ្នា ការចង់បាន ជាអាការរបស់ចិត្ត ដែលកើតដោយសារចិត្តជួបប្រទះនឹងហេតុការណ៍ ដូចជាភ្នែកឃើញរូបជាដើម ក៏កើតការដឹងក្នុងរូបនោះ ថាល្អ, ស្អាត, សម ទើបកើតការស្រឡាញ់រូបនោះ តពីនោះក៏ប្រែសភាពជាចង់បាន គឺចង់បានរូបល្អ សម្លៀងពាក់ ចង់បានផ្ទះល្អនៅអាស្រ័យ ចង់បានទ្រព្យសម្បត្តិ, ចង់បានយសស័ក្តិ ដូច្នេះជាដើម ការប្រាថ្នា ការចង់បានបែបនេះ នៅក្នុងលក្ខណៈនៃការប្រាថ្នា - ចង់បានធម្មតា, មិនមែនធ្លាក់នរកព្រោះសេចក្ដីប្រាថ្នានេះទេ ។ សេចក្ដីប្រាថ្នា-

ចង់បានជាដើមហ្នឹងឯង តែងមានទំហំរីកខ្លាំងជាធម្មតា ដកបងល់គិតរកវត្ថុដែលខ្លួនត្រូវការចង់បាននោះ ដោយវិធីមិនល្អ ខុសច្បាប់ ខុសទម្លាប់ទំនៀម ដូចជាការប្លន់ លួច បោកប្រាស ជាដើម សេចក្ដីប្រាថ្នាដូច្នេះទើបជាលោភៈ ។ ម្យ៉ាងទៀត ការប្រាថ្នា-ចង់បានប្រាក់មាស សម្បត្តិច្រើនពប់រយ ពប់ពាន់រៀល ឬចង់សាងឋានៈខ្លួនឲ្យខ្ពង់ខ្ពស់ ជាអនុមន្ត្រី, វរមន្ត្រី, ឧត្តមមន្ត្រី ហើយតាំងចិត្តគិតរកដោយផ្លូវត្រឹមត្រូវមិនខុសនឹងច្បាប់ ដូច្នេះក៏មិនចាត់ជាលោភៈដែរ, តែផ្ទុយទៅវិញ បើចង់បានឋានៈ សម្បីជាទាបក្រោមអនុមន្ត្រី ហើយគិតរកដោយវិធីសូកប៉ាន់ដើម្បីតំណែងនេះ, ប្រាថ្នាចង់បានប្រាក់សម្បីតែមួយរៀល ហើយគិតរកដោយវិធីលួចបន្លំ ឬប្រើឧបាយណាមួយឲ្យខាងតែបានប្រាក់នោះ យ៉ាងនេះ ទើបចាត់ជាលោភៈ ព្រោះហេតុថាការចង់បាននោះ មានអកុសលចូលលាយឡំផង ។

ដើម្បីបញ្ជាក់រឿងនេះឲ្យច្បាស់, សូមអ្នកអាន អានសិង្គាលសូត្រត្រង់សំដែងពីទិដ្ឋធម្មិកត្ថប្រយោជន៍ ហើយពិចារណាមើល គង់នឹងយល់ចិត្តបាន ។

ក្នុងសូត្រនោះ ព្រះអង្គសំដែងឧបាយវិធី ៤ យ៉ាង ដើម្បីឲ្យបាននូវទ្រព្យសម្បត្តិ, យសស័ក្តិ, មិត្តសំឡាញ់ និងសេចក្ដីសុខរើងគឺ :

១– **ឧដ្ឋានសម្បទា** បរិបូណ៌ដោយការព្យាយាម គឺខំប្រឹងប្រែង

ធ្វើនាទីដែលខ្លួនត្រូវធ្វើ មិនខ្ជិលច្រអូស, មិនបន្ធូរបន្ថយ ទំឲ្យបានសំរេច ដូចគោលបំណង ។

២– អារក្ខសម្បទា រក្សាទ្រព្យដែលរកបានមកដោយព្យាយាមនោះ មិនឲ្យខូចវិនាស ព្រោះធ្វេស, ចេះទុកដាក់ទ្រព្យឲ្យរៀបរយ, ចេះជួសជុលរបស់ដែលទ្រុឌទ្រោម, របស់ណានៅប្រើប្រាស់បាន មិនគួរបោះបោល, មិនទុករបស់ឲ្យនៅទំនេរ ដូចជាទីដី គួរបណ្ដុះពូជ ដាំឈើឲ្យផ្លែ ដាំផ្កាជាដើម គឺធ្វើយ៉ាងណាឲ្យបានផលអំពីទ្រព្យដែលមានហើយនោះ មួយជាន់ ពីរជាន់ទៀត ។

៣– កល្យាណមិត្តតា រាប់រកតែមនុស្សមានសន្ដានល្អ ចរិយាត្រឹមត្រូវធ្វើជាមិត្រ ។

៤– សមជីវិតា ចេះប្រើប្រាស់ទ្រព្យសមតាមកម្លាំងទ្រព្យដែលមាន ចេះធ្វើដំណើរជីវភាពឲ្យសមតាមឋានៈ ។

នេះ បញ្ជាក់ឲ្យឃើញព្រះទ័យដ៏ពេញពោរដោយព្រះមហាករុណាធិគុណដែលមានចំពោះសព្វសត្វ របស់ព្រះពុទ្ធម្ចាស់, ព្រះអង្គបានត្រួសត្រាយផ្លូវឲ្យយើងដើរ, ទ្រង់ពុំបានតិះដៀលអ្នកចង់បាន ចង់មានទេ, តាំងជួយប្រាប់វិធីប្រកបជីវភាពឲ្យថែមទៀត ។ ទ្រង់តិះដៀលតែអ្នកដែលមានបំណងចង់បានហួសព្រំដែន ដូចពោលហើយ ។ ប្រសិនជាការប្រាថ្នា-ចង់បាន ចាត់ជាលោភៈនោះ ការដែលព្រះអង្គសំដែង

ទិដ្ឋធម្មិកត្ថប្រយោជន៍ ទុកដូចជាទ្រង់គាំទ្រឲ្យសត្វខំបំពេញលោភៈ ធ្វើលោភៈឲ្យកើតមាន, តែផ្ទុយទៅវិញ រឿងលោភៈនេះ ព្រះអង្គសំដែងថាជាមូលនៃសេចក្ដីអាក្រក់ទាំងពួង, អ្នកដែលមានចិត្តត្រូវលោភៈគ្របសង្កត់ហើយ រកសេចក្ដីសុខ សេចក្ដីចំរើន ពុំបានទេ ។ ព្រោះលោភៈជាសត្រូវរបស់ចិត្ត កើតក្នុងចិត្ត ហើយធ្វើចិត្តឲ្យអន្ទះអន្ទែង សោប់សល់ៗ ចិត្តទទួលសុខបាន លុះត្រាតែចិត្តមានឥស្សរៈផុតពីអំណាចអ្វីទាំងអស់ បើចិត្តត្រូវកិលេស គឺលោភៈជះជាន់ ឈ្មោះថាចិត្តមិនមានឥស្សរៈ ។ ចិត្តដែលធ្លាក់ក្នុងអាការដូច្នេះ ដូចជាកាយមានរោគ ទទួលទានអាហារក៏មិនឆ្ងាញ់ ធ្វើការងារពុំបានស្រួល ទឹងគិតអ្វី ។ តែងតែស្របតាមគោលបំណងរបស់វត្ថុដែលមានអំណាចជាង សូម្បីតែលោភៈបង្គាប់ឲ្យលួច, ប្លន់, បោកប្រាសគេក៏យក ។ ចិត្តយ៉ាងនេះ ហៅថាចិត្តទុព៌ល, ចិត្តអន់កម្លាំង, ចិត្តពិការ, ចិត្តមានជម្ងឺ ដូច្នេះ រសនៃសេចក្ដីសុខនឹងកកើតមិនបាន ។

២_ទោសៈ គិតប្រទូសរ៉ាយ :

បុថុជ្ជនរមែងមានការពេញចិត្ត និងមិនពេញចិត្តចំពោះអារម្មណ៍ដែលមកប៉ះទង្គិចជាប្រក្រតី, បើប្រទះអារម្មណ៍ល្អ ក៏សោមនស្ស, បើប្រទះអារម្មណ៍អាក្រក់ ក៏សំដែងអាការក្នាញ់ ទឹងតតអានអ្វីក៏មិនស្រួល ។ បើរម្ងាប់មិនបានក្នុងខណៈនេះទេ ចិត្តក៏នឹងប្រែសភាពទៅជាក្រោធសំដែង

អាការវិបរិតផ្សេង ៗ មានអាការអន្ទះអន្ទែង, ក្តៅក្រហាយ ដើរក៏មិនស្រួល អង្គុយក៏មិនសុខ ៗ ចិត្តស្ទុះទៅចាប់អារម្មណ៍ដែលធ្វើឲ្យខឹងនោះញាប់ពេក ហើយល្អិតផង ទើបបណ្តាលទៅជាក្តៅក្រហាយ ដូចជាយើងយកដៃដុះអវយវៈណាមួយរបស់យើងឲ្យញាប់ ក៏នឹងមានអាការក្តៅត្រង់កន្លែងដែលដុះនោះដូច្នោះដែរ ៗ បើក្រោធខ្លាំងពេក អាចធ្វើខ្លួនអ្នកនោះឲ្យញ័រ មុខមាត់ឡើងក្រហម ដៃជើងញាក់ទទ្រើក ទាំងនេះព្រោះឈាមដែលហូរទៅចិញ្ចឹមរាងកាយប្រែសភាពជាឈាមពុះកញ្ជ្រោល បើយកដៃទៅដាក់ត្រង់ទ្រូង ក៏នឹងដឹងថាមានអ៊ូបុកពីក្នុងទ្រូងមក ដូចជាគេបញ្ច្រាំមំសៈ ក្នុងវេលាដូច្នេះ កម្លាំងចិត្តត្រូវវិនាស គិតក៏ច្រើនខុស និយាយច្រើនតែជ្រុល បើកំពុងលេងកីឡាផង កុំសង្ឃឹមថានឹងមានជ័យជំនះឡើយ ព្រោះកម្លាំងចិត្តត្រូវបែងតស៊ូនឹងក្រោធផង តស៊ូនឹងបរបក្សផង ៗ មនុស្សខ្ទះខឹងខ្លាំងពេកទៅ ដួលសន្លប់ក៏មាន ដួនកាលសរសៃឈាមដាច់ស្លាប់មួយរំពេច ព្រោះឈាមរត់ខ្លាំងពេកក៏មាន ៗ

បើរម្ងាប់ការក្រោធនេះមិនបានទេ ចិត្តក៏នឹងកើតមានអាការម្យ៉ាងទៀត គឺការប្រាសចាកធម៌មេត្តា អាចប្រទូសរ៉ាយ បៀតបៀន អ្នកដែលធ្វើខ្លួនឲ្យខឹងនោះ ដោយប្រការផ្សេង ៗ មានជេរ, វាយ, កាប់, សម្លាប់គេជាដើម តែមុននឹងទៅប្រទូសរ៉ាយគេនោះ ប្រទូសរ៉ាយខ្លួនឯងសិន គឺធ្វើចិត្តអ្នកនោះឲ្យបានការក្តៅក្រហាយ ហើយទើបប្រទូស្តអ្នក

ផងទៃជាខាងក្រោយ ។ ផលដែលកើតអំពីការប្រទូសរ៉ាយគេ ក៏ជាប់តាមមក ជាការជាប់គុកខ្លះ, ជាការវិនាសទ្រព្យខ្លះ, ត្រូវគេជំនៀលខ្លះ, មិនមានគេរាប់អានខ្លះ ។

ទោសៈជាភេគអន្តរាយយ៉ាងសម្បើម អាចរំលាយសុខភាពរបស់បុគ្គលអ្នកត្រូវទោសៈគ្របសង្កត់នោះបានដោយងាយ ហើយជាភេគធ្វើអ្នកនោះឲ្យទៅជាសត្រូវនឹងអ្នកដទៃទៀត ។

៣_មោហៈ វង្វេង, បានដល់អាការនៃចិត្តមិនអាស្រ័យហេតុផល គិតមិនដល់, ដឹងមិនទាន់ក្នុងអំពើខុស ត្រូវ ល្អ អាក្រក់ ជាដើម ។ មោហៈនេះ អ្នកខ្លះចូលចិត្តថា ជាការល្ងង់ខ្លៅនៃចិត្ត, តែសេចក្ដីពិត ការល្ងង់ជាលក្ខណៈរបស់អវិជ្ជា ។

ចិត្តជាធម្មជាតមានសមត្ថភាពច្រើនបែបយ៉ាងណាស់ ដូចជាសមត្ថភាពក្នុងការធ្វើ, ក្នុងការនិយាយ, ក្នុងការគិតជាដើម វេលាធ្វើត្រូវប្រើសមត្ថភាពក្នុងការធ្វើ, ហើយបង្អង់សមត្ថភាពដទៃទុកសិន, ក្នុងការនិយាយ ការនឹកគិតក៏ដូចគ្នា, នៅមានសមត្ថភាពម្យ៉ាងទៀតដែលចិត្តត្រូវតែប្រើគ្រប់ពេល គឺការដឹងខុសត្រូវ ដឹងល្អ អាក្រក់ ។ ការដឹងខុសត្រូវ ល្អអាក្រក់នេះ ត្រូវតែមានជាប់នឹងការគិតជាដរាប ។ ក្នុងខណៈណា ចិត្តមិនប្រើការដឹងខុសត្រូវ ខណៈនោះ ចិត្តឈ្មោះថាមានមោហៈ ត្រូវមោហៈគ្របសង្កត់ ។ ការមិនប្រើការដឹងខុសត្រូវនៃចិត្ត

នេះហើយ ធ្វើបុគ្គលល្អឲ្យក្លាយទៅជាមនុស្សអាក្រក់ មិនថាអ្នកនោះជាអ្វី នៅក្នុងឋានៈណា រៀនចេះចប់គម្ពីរព្រះត្រៃបិដក, ត្រៃវេទ, មានសញ្ញាប័ត្រជាន់ខ្ពស់ ជាវិស្វករ ជាវេជ្ជបណ្ឌិតទេ ។ ការមិនដឹង មិនចេះដទៃទៀត ដូចជាមិនចេះអក្សរ មិនចេះច្បាប់ ឲ្យឈ្មោះបានត្រឹមតែមិនចេះអក្សរ មិនចេះច្បាប់ប៉ុណ្ណោះ មិនមែនធ្វើមនុស្សឲ្យធ្លាក់នរកព្រោះមិនចេះអក្សរ មិនចេះច្បាប់ឡើយ ។ អ្នកដែលចេះដឹងច្រើន តែធ្វើមិនប្រើការដឹងខុសត្រូវ ល្អអាក្រក់ គង់ឲ្យឈ្មោះថាមានមោហៈ ត្រូវមោហៈបិទបាំង, ផ្ទុយទៅវិញ អ្នកខ្លះចេះដឹងតិចទេ សូម្បីតែសញ្ញាប័ត្រជាន់ទាប ក៏ប្រឡងមិនបានដែរ តែជាអ្នកចេះដឹងខុសត្រូវ ល្អអាក្រក់ អ្នកនោះអាចផុតពីមោហៈបានក្នុងខណៈនោះ ។ មោហៈមិនមែនការមិនដឹងមិនចេះ, ការមិនដឹងជាតួអវិជ្ជា, ការមិនប្រើការចេះដឹងនៃចិត្ត ទើបជាមោហៈ ។

មោហៈជាតួកេតដ៏សំខាន់របស់ចិត្ត អាចដឹកនាំឲ្យបុគ្គលធ្វើសេចក្តីអាក្រក់បានគ្រប់ផ្លូវ សម្លាប់គេខ្លះ លួចទ្រព្យគេខ្លះ កុហកខ្លះ ព្រមទាំងជាឧបករណ៍ជួយ លោភៈ និង ទោសៈ ឲ្យមានកម្លាំងខ្លាំងទៅទៀត ។

កេតចិត្តគឺលោភៈ ទោសៈ និង មោហៈ ជាកេតមានមហិទ្ធិឫទ្ធិយ៉ាងសាហាវ, កើតបានយ៉ាងរហ័ស, ប្រៀបដូចជាខ្យល់ព្យុះ អាចបំផ្លាញផ្ទះសាលាឲ្យបាក់បែកក្នុងវេលាមួយរំពេចបាន ព្រមទាំងមានពិសពុល

ជាផលពេលដែលកើតតាមកន្លែងកាយទៅទៀត ។ ចិត្តជាមូលដ្ឋាននៃជីវិត កាលចិត្តមានពេលអន្ទះអន្ទែង ក្តៅក្រហាយ រកសេចក្តីសុខពុំមានហើយ កន្លែងកាយក៏ឈឺចាប់ ក្តៅក្រហាយតាម បន្ថយកម្លាំងកាយ កម្លាំងចិត្តឲ្យទុព្វលភាពគ្រប់ខណៈ ឲ្យប្រព្រឹត្តអាក្រក់បានគ្រប់ផ្លូវ ។

## ថ្នាំនិងវិធីបំបាត់រោគ

កាយរមែងមានការក្តៅ, គ្រុនក្តៅ, ស្រេក, ឃ្លាន, អាពាធផ្សេងៗ ជិះជាន់ជាប្រក្រតី តែទោះបីដូច្នោះ គង់ធម្មជាតិបានបង្កើតវត្ថុគ្រឿងសម្រាប់កែខៃដែរ បើមិនមានវត្ថុសម្រាប់កែទេ នោះនឹងមិនមានអ្នកសល់នៅលើផែនដីនេះឡើយ ។ ក្តៅត្រូវផ្លូតទឹកឬបក់ផ្លិតកែ, គ្រុនក្តៅត្រូវដណ្តប់សំពត់កែ, ស្រេកផឹកទឹកបំបាត់, ឃ្លានបរិភោគអាហារ, ឈឺចុកចាប់ (ទុច្ចារៈបស្សាវៈ) ត្រូវបន្ទោបង់ចេញ, គ្រុនប្រើថ្នាំសម្រាប់បំបាត់គ្រុន ស្អឹកត្រូវប្រើថ្នាំបំបាត់ស្អឹក គឺមានអាការពេលបែបណា ប្រើថ្នាំនិងវិធីឲ្យសមតាមពេលនោះ, ពេលអាចធូរថយកម្លាំង ឬវិនាសទៅវិញ តាមគួរដល់កម្លាំងនៃថ្នាំនោះ ។

ចិត្តក៏ដូចជាកាយដែរ កាលត្រូវពេល គឺកិលេសគ្របសង្កត់ហើយ គង់មានថ្នាំនិងវិធីកែព្យាបាលឲ្យជាសះបាន ។ ថ្នាំសម្រាប់ព្យាបាលចិត្តបានដល់ធម៌ ឬធម្មោសថ ។

លោភៈ ឱសថសម្រាប់បំបាត់ គឺសន្តោស បានដល់សេចក្តី

ក្រេកអរក្នុងវត្ថុដែលខ្លួនរកបានដោយសុចរិត និងក្នុងវត្ថុដែលខ្លួនមាន, អប់រំចិត្តកុំឲ្យក្រេកអរហួសព្រំដែន ដែលនាំឲ្យខូចសីលធម៌ ។

ទោសៈ ឱសថសម្រាប់កែ គឺមេត្តាករុណា បានដល់ការប្រាថ្នាឲ្យអ្នកដទៃបានសេចក្តីចំរើន គិតជួយដោះទុក្ខគេ អប់រំអធ្យាស្រ័យឲ្យឃើញចិត្តថ្លើមអ្នកដទៃ ដោយប្រៀបនឹងខ្លួនថា «យើងស្រឡាញ់សុខស្អប់ទុក្ខយ៉ាងណា គេក៏ស្រឡាញ់សុខ ស្អប់ទុក្ខដូចគ្នាដែរ មិនគួរធ្វើឲ្យគេក្តៅក្រហាយឡើយ» ។

មោហៈ ឱសថសម្រាប់បំបាត់ គឺសតិសម្បជញ្ញៈ បានដល់ការកំណត់ដឹងលក្ខណៈនៃការធ្វើ និយាយ និងការគិតឲ្យមានហេតុផល, ឃើញគុណទោសថា នេះគួរ, នេះមិនគួរ, ហាត់ធ្វើការរិះគិតឲ្យមានវិចារណញ្ញាណឡើង ។

កាយក៏ដោយ ចិត្តក៏ដោយ បើបណ្តោយឲ្យកើតរោគ ឬកិលេសបានហើយ សូម្បីមានវិធីរក្សាគ្រប់គ្រាន់ ក៏គង់ធ្វើសេចក្តីលំបាកក្នុងការរក្សាឲ្យជា ជួនកាលរក្សាមិនជា ដល់នូវក្តីមរណៈក៏មាន ទៅជាឆ្កួតក៏មាន ដូចជាផ្ទះដែលត្រូវភ្លើងឆេះ រមែងធ្វើសេចក្តីលំបាកឲ្យដល់ម្ចាស់ ក្នុងការលត់ភ្លើងនោះ ជួនកាលលត់មិនបានដល់នូវការខូចខាត ប្រើការលែងកើតក៏សឹងមានដូច្នោះដែរ ។

ព្រោះហេតុនោះ វិធីការពារមុនពេលទាំងនេះកើត ជាវិធីល្អបំផុត

ហើយមានកម្លាំងពូកែ គួរជាទីទុកចិត្តបាន ។

វិធីការពារ តើធ្វើដូចម្ដេច ? គឺការប្រយ័ត្ន, រក្សាកំផក ឬហៅថា

## អនាម័យ ។

ជីវិតរបស់យើងសំខាន់ នៅត្រង់មានអនាម័យ, កាលជីវិតមានអនាម័យហើយ វិជ្ជា, ការងារផងទាំងឡាយ រមែងកើតបានដោយងាយ ព្រោះអនាម័យជាអណ្ដូង ជាទីកើតនៃវិជ្ជា និងការងារនោះៗ ។ ការមិនមានរោគបៀតបៀន, មានសុខភាពបរិបូណ៌, មានកម្លាំងកាយគ្រប់គ្រាន់, មានកម្លាំងចិត្តល្អ, គិតបានរហ័ស នេះគឺអនាម័យ បានដល់កាយ និងចិត្តប្រាសចាករោគជិះជាន់ ។

ដោយន័យនេះ អនាម័យមានពីរប្រភេទ គឺអនាម័យផ្នែកកាយ និងអនាម័យផ្នែកចិត្ត :

១- **អនាម័យផ្នែកកាយ** ការរក្សា, ការពារកាយមិនឲ្យមានរោគ ហៅថា **អនាម័យកាយ** ទីនីសំដែងខ្លី ៗ ដូចតទៅនេះ :

### (១) ស្គាល់ប្រមាណក្នុងរឿងអាហារ :

- បរិភោគតែល្មម មិនឲ្យឆ្អែតពេក ដល់ថ្នាក់ហល់ តិចពេក ដកបធ្វើកាយឲ្យរសាប់រសល់ ។
- បរិភោគតែអាហារល្អមានរសជាតិ ។
- មិនបរិភោគអាហារឆ្អុម, ស្អុយ ។ល។

– វៀរចាកអាហារដែលមានរសជាតិប្រៃពេក ជូរពេក, ហឹរពេក ។

– កុំបរិភោគហួសពេក (ធាតុពិការ) ។

- បរិភោគទំពារឲ្យល្អិត (ធាតុពិការ) ។

– កំពុងបរិភោគ កុំនឹកអារម្មណ៍មិនល្អ ដូចជាក្រោធ ។

· វេលាបរិភោគធ្វើចិត្តឲ្យរីករាយ ។

– បរិភោគត្រូវតាមវេលា ។

– កំពុងហត់ កុំបរិភោគ ។

– ផឹកតែទឹកឆ្អិន ឬត្រងស្អាត ។

(២) ស្គាល់ប្រមាណក្នុងការដេក

– ដេកឲ្យត្រង់តាមវេលា ។

– កុំដេកច្រើនពេក· តិចពេក (ក្នុង ២៤ ម៉ោង ដេកយ៉ាងតិច ៧-៨ម៉ោង តែមិនមែនចែកវេលាថ្ងៃ ២ ម៉ោង ល្ងាច ៦ ម៉ោង) ។

– ដេកពីព្រលប់ ភ្ញាក់មុនអរុណរះ ។

(៣) គួរបញ្ចេញកម្លាំងកាយ: ដូចជាលើកដៃ-ជើង ដើម្បីឲ្យសាច់ដុំកម្រើក ។

(៤) ឧច្ចារៈបស្សាវៈ:

–ទៅតាមវេលា (ពេលមុនអាហារព្រឹកល្អ) ។

- កុំទំអត់ទប់ឧច្ចារៈបស្សាវៈវេលាឈឺ ។
- ព្យាយាមកុំឲ្យទល់ ។

(៥) ការសំអាតកាយ៖

ឧស្សាហ៍ងូតទឹកជម្រះកាយ កុំឲ្យមានក្លិន ។
- កុំទុកក្រចកឲ្យវែង ។

(៦) ការសំអាតសំលៀកបំពាក់៖

- កុំឲ្យមានក្លិនស្អុះស្អាប ។
- ឧស្សាហ៍បោកគក់ ។

(៧) សំអាតទីនៅឲ្យស្អាតជានិច្ច៖

- ប្រយ័ត្នកុំឲ្យមានសម្រាម, ស្មៅ, ទឹកដក់នៅក្បែរផ្ទះ (កើតមូស)។
- របស់សំណល់ត្រូវចោលបន្តរណ្តៅគ្របឲ្យជិត បើមិនគ្របត្រូវរោយផេះ ឬកំបោរពីលើ ដើម្បីកុំឲ្យរុយទំ ។

(៨) រក្សាគ្រឿងបរិភោគឲ្យស្អាត ប្រយ័ត្នរុយទំ ធូលីចូល ។

(៩) ព្យាយាមប្រើឥរិយាបថ៤គឺ៖ ដេក អង្គុយ ឈរ ដើរ ឲ្យស្មើ ។

(១០) គួរវៀរដើរលេងយប់ហួសពេល ។

(១១) គួរវៀរវត្ថុស្រវឹងគឺ៖ ស្រា កញ្ឆា អាភៀន ព្រោះវត្ថុទាំងនេះធ្វើក្រពះឲ្យពិការ - ធាតុពិការ - កើតរោគមហារីកក្នុង

ក្រពះ សួត ពោះវៀន ធ្វើសរសៃវិញ្ញាណឲ្យស្ពឹក ការនាំទុនជយ ។

កាលយើងរក្សាកាយតាមន័យដ៏សង្ខេបនេះ ឈ្មោះថាមានអនាម័យផ្នែកកាយ ។ វត្ថុសំខាន់ក្នុងកាយយើង គឺចិត្ត ក៏ត្រូវការពារកុំឲ្យរោគមកបៀតបៀនដែរ បើចិត្តមានរោគហើយ កាយសូម្បីយើងបានបម្រុងរក្សាល្អយ៉ាងណាក៏ដោយ គង់មិនបានសេចក្ដីសុខសម្រាន្ត, ដោយហេតុថាចិត្តជានាយលើកាយបង្គាប់ឲ្យកាយធ្វើកិច្ចសព្វយ៉ាង ។ នាយមិនល្អបាវព្រាវក៏មិនល្អតាម ។

ព្រោះហេតុនេះ ចិត្តជាវត្ថុត្រូវតែបម្រុងរក្សាឲ្យមានអនាម័យឡើង ។

២–អនាម័យផ្នែកចិត្ត ការរក្សាចិត្តមិនឲ្យមានរោគ គឺប្រាសចាកអារម្មណ៍អាក្រក់មកបៀតបៀន ដូចសំដែងដោយខ្លី ៗ តទៅនេះ :

(១) ហាត់គិតឲ្យមានរបៀប គឺបង្គាប់ចិត្តឲ្យគិតតែក្នុងរឿងដែលត្រូវគិត ។

(២) រក្សាកម្លាំងចិត្ត

– ត្រូវជឿខ្លួនឯង ។
– ទំសង្កត់ការភ័យខ្លាចដែលកើតដល់ខ្លួន ។
– ព្យាយាមធ្វើតាមវេលាដែលបានកំណត់ទុកហើយ ទុកណាមានឧបស័គ្គក្នុងរវាង ក៏មិនព្រមលើកលែង ។

- មិនគិតឲ្យហួសពីគោលបំណង ។
- ពិចារណាមុនទីងជឿមគិ ឬទស្សនៈណាមួយ ។
- កុំនាំរឿងហួសវិស័យមកគិត ។
- កុំយកអនិដ្ឋារម្មណ៍ (អាក្រក់) មកទុកក្នុងចិត្ត ។

## (៣) ការហាត់ធ្វើសមាធិ

- ធ្វើចិត្តស្ងប់ចាកអារម្មណ៍ ។
- ធ្វើចិត្តឲ្យមានតែអារម្មណ៍មួយ ។
- ធ្វើចិត្តឲ្យនឹង ។

ចិត្តដែលបានប្រើវិធីការពារដូចខាងលើនេះរមែងជាចិត្តមានកម្លាំងៗ កម្លាំងចិត្តនេះ អាចគ្រប់គ្រងលោកបាន ហើយសំខាន់ជាងកម្លាំងកាយខ្លាំងពូកែច្រើនរយពាន់ដងទៅទៀត អ្នកដែលមានកម្លាំងចិត្តល្អហើយ កម្លាំងកាយរមែងកើតមានតាមមកផង កាលបើដូច្នេះ សេចក្ដីសុខសម្រាន្ត ជាគុណដែលបុគ្គលនោះត្រូវតែបានទទួលជាប្រាកដ ។

ព្រោះហេតុនោះអ្នកប្រាជ្ញថាសេចក្ដីចំរើន គួររក្សាកាយ និងចិត្តរបស់ខ្លួនឲ្យមានកម្លាំង កុំឲ្យធ្លាក់ទៅក្នុងអំណាចនៃរោគ និងកិលេសញាំញីបាន ។

# កិច្ចកថា

*ព្រះពុទ្ធត្ថេរ យន់-យូរ វត្តព្រះពុទ្ធមានបុណ្យ*

រៀបរៀង

អាត្មាភាពសូមស្រង់យកពុទ្ធភាសិត ដែលមាននៅក្នុងគម្ពីរខុទ្ទកនិកាយធម្មបទ ត្រង់ពុទ្ធវគ្គ មកធ្វើអត្ថាធិប្បាយដូចមានបទបាលីថា :

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ

ប្រែថា «ការបានចំពោះនូវកំណើតជាមនុស្សជាការក្រ, ជីវិត ការរស់នៅនៃសត្វទាំងឡាយជាការក្រ, ការ (បាន) ស្តាប់នូវព្រះសទ្ធម្មជាការក្រ, ការកើតឡើងនៃព្រះពុទ្ធទាំងឡាយជាការក្រ ។

ពុទ្ធភាសិតនេះ សំដែងអំពីកម្រ ៤ យ៉ាងគឺ :

១- កិច្ឆោ មនុស្សប្បដិលាភោ កម្របានកើតជាមនុស្ស ។

២- កិច្ឆំ មច្ចាន ជីវិតំ បានកើតជាមនុស្សហើយ ក្រនឹងមានជីវិតរស់នៅ ។

៣- កិច្ឆំ សទ្ធម្មស្សវនំ បានរស់នៅហើយ ក្រនឹងបានស្តាប់ ឬក្រនឹងបានជួបនូវព្រះសទ្ធម្ម ។

៤- កិច្ឆោ ពុទ្ធានមុប្បាទោ ក្រនឹងមានព្រះពុទ្ធកើតឡើងក្នុងលោក ។

សូមលើកយកកម្រ ៤ យ៉ាងនេះ មកពែកញែកធ្វើអត្ថាធិប្បាយមួយ ម្តង ៗ ជាលំដាប់ដូចតទៅនេះ :-

១. កិច្ឆោ មនុស្សប្បដិលាភោ ក្រនឹងបានកើតជាមនុស្ស

ពាក្យថា មនុស្ស បានដល់បុគ្គលដែលស្គាល់ហេតុល្អ និងហេតុអាក្រក់ ឬស្គាល់ល្អ ស្គាល់អាក្រក់ ស្គាល់ខុស ស្គាល់ត្រូវជាដើម ដូចមានបរិគ្រោះថា ការណាការណំ មនតិ ជានាតីតិ=មនុស្សា ។

ពាក្យថា ក្រនឹងបានកើតជាមនុស្ស លោកសំដៅយកហេតុពីរយ៉ាងគឺ :

ក) ក្រនឹងបានកើតជាមនុស្ស

ខ) បានកើតជាមនុស្សហើយ ក្រនឹងមានលក្ខណៈជាមនុស្ស ។

នៅក្នុងពិភពលោកនេះ, បើគេពុំបានពិចារណាឲ្យដិតដល់ទេ ហាក់ដូចជាមានមនុស្ស ឬអ្នកដែលបានកំណើតជាមនុស្សច្រើនកុះករជា-អនេកប្បការ គឺច្រើនរូប ច្រើនជាតិ ច្រើនសាសន៍ ច្រើនភាសាណាស់ ដូចជាកំណើតមនុស្សនោះ ពុំមែនបានដោយក្រទេ គឺបានដោយងាយ ៗ-ពេក ប៉ុន្តែបើគេធ្វើវិចារណ៍ឲ្យម៉ត់ចត់ដិតដល់មែនទែនទៅគង់នឹងដឹងថា កំណើតមនុស្សក្រណាស់ ពុំងាយរកបានឡើយ ។ ព្រោះហេតុអ្វី ? ។ ព្រោះថា ក្នុងលោកសន្និវាសនេះមានភូមិ ៣ គឺ: អបាយភូមិ១, មនុស្សភូមិ១ និងទេវភូមិ១ ។ ក្នុងអបាយភូមិ មាននរកដែលមានឈ្មោះជាច្រើន ហើយដែលមានសត្វធ្លាក់ទៅរងទុក្ខច្រើនជាអនេក, ភូមិប្រេត ភូមិអសុរកាយ

ទីឋានភូមិតិរច្ឆាន ក៏ដូចគ្នា ៗ បើលើកយកត្រឹមតែភូមិសត្វតិរច្ឆានមួយមកធ្វើការប្រៀបធៀបទីឋានមនុស្ស ឬទីឋានកំណើតមនុស្ស ក៏គង់នឹងឃើញថា ពពួកសត្វមានកំរិតច្រើនលើសមនុស្សលោកនេះរាប់លានកោដិគុណទៅហើយ ពុំចាំបាច់ពោលទៅដល់សត្វដែលកើតនៅក្នុងនរក ប្រេត អសុរកាយ ឬពពួកទេពនិករឡើយ ។

មែនពិត ក្នុងកំណើតពពួកសត្វជាន់ទាប រាប់អំពីកំណើតតិរច្ឆានចុះទៅជាជីវិតប្រកបដោយសប្បដិភ័យ ស្រេកឃ្លានរងទុក្ខវេទនា ត្រូវគេព្យាបាទវាយដំច្រំឆាក់កាប់សម្លាប់ទទួលទុក្ខទារុណគ្រប់ពេលវេលា ៗ ពពួកសត្វទាំងនោះ កាលបើបានដឹងថា កំណើតមនុស្សមានសេចក្ដីសុខ មានសេរីភាព មានអាធិបតេយ្យបរិបូណ៌ មានជីវិតខ្ពង់ខ្ពស់ជាងខ្លួន ក៏ផ្គង់ចិត្តលើកឡើងនូវឆន្ទៈប្រាថ្នាចង់បានកំណើត មនុស្សគ្រប់ ៗ គ្នា ហើយមានសេចក្ដីធុញទ្រាន់ ជិនឆ្អន់ ជ្រប់មុខទីឋានកំណើតរបស់ខ្លួនហួសប្រមាណ កុំថាឡើយតែពពួកសត្វ សូម្បីតែមនុស្សដូចគ្នា កាលបើបានឃើញនូវជីវិតអ្នកដទៃរុងរឿងខ្ពង់ខ្ពស់ជាងខ្លួន ក៏តាំងផ្ចង់ចិត្តប្រាថ្នាចង់បានជីវិតបែបនោះដែរ ៗ តែដំណើរនៃសេចក្ដីប្រាថ្នារបស់សត្វទាំងនោះ ពុំងាយនឹងបានសម្រេចដូចចិត្តឡើយ ព្រោះកម្មអាក្រក់ទុច្ចរិត ដែលខ្លួនបានធ្វើមកពីអតីតជាតិនៅឃុំគ្រងពាក់ព័ន្ធឲ្យរងវិបាកដ៏រ៉ាំរ៉ៃតទៅទៀត ពុំឲ្យសម្រេចដូចបំណង ៗ បើទុកជាបានរំដោះចាកកម្មពៀរ ហើយបានមកកើតជាមនុស្ស

ក៏ពុំងាយនឹងបានជាមនុស្សថ្ងៃថ្មីទៀត ពីព្រោះកំណើតមនុស្ស ពុំមែនបានដោយសារគ្រាន់តែតាំងចិត្តប្រាថ្នា ហើយពុំបានបំពេញកុសលកម្មផ្សេង ៗ នោះទេ ។ តាមពិត អ្នកដែលបានកើត ជាមនុស្សហើយមានស័ក្តិយសខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិនិងបរិវារសម្បត្តិច្រើន សុទ្ធតែបានអំពីការខំប្រឹងប្រែងធ្វើកុសលដ៏ធំអំពីអតីតជាតិទុកសំរាប់ខ្លួនផង ខំប្រឹងសន្សំសំចៃកសាងក្នុងជាតិនេះផង ។

ម្យ៉ាងទៀត កំណើតជាមនុស្សនេះ ជាកំណើតកសាង នូវកំណើតឯទៀតៗ ទាំងអស់ ។ អ្នកដែលបានទៅកើតជាទេវបុត្រ-ទេវតា ក្នុងសួគ៌ទេវលោក ក៏បានមកអំពីការកសាងក្នុងកំណើតជាមនុស្ស ។ អ្នកដែលទៅកើតក្នុងព្រហ្មលោកក៏បានមកអំពីខ្លួនខំប្រឹងចំរើនក្នុងកំណើតជាមនុស្ស អ្នកដែលមានកំណើតជាសត្វតិរច្ឆាន អសុរកាយ ប្រេត ក៏បានមកអំពីអំពើអាក្រក់ ដែលខ្លួនបានធ្វើក្នុងកំណើតជាមនុស្សនេះទៅដែរ ។ ដូច្នេះហើយគេអាចទាយស្មានដោយត្រូវថា បុគ្គលណាកើតជាមនុស្សហើយធ្វើអំពើល្អពុំកើត បុគ្គលនោះច្បាស់ជាធ្វើពូជមនុស្សរបស់ខ្លួនឲ្យចូលសាបសូន្យទៅបរលោក ។ បុគ្គលកើតជាតិជាមនុស្សក្នុងជាតិនេះ ហើយធ្វើអ្វីដែលនាំឲ្យចំរើនដល់ខ្លួន និងជាតិកំណើតរបស់ខ្លួនមិនបាន ទោះបីខំអួតអាងថាខ្លួននឹងចាំធ្វើនៅពេលនេះឬពេលនោះដូច្នេះ ជាសំដីដែលអ្នកប្រាជ្ញពុំអាចជឿកើតឡើយ ។

មួយវិញទៀត អំពើអាក្រក់ធ្វើហួសទៅហើយ ពុំអាចនឹងកែបានឡើយ ដូចនិទានសេដ្ឋីបុត្រ៤នាក់ក្នុងគម្ពីរធម្មបទថា:

ក្នុងសម័យកាលដែលព្រះពុទ្ធទ្រង់ព្រះនាមកស្សបបានកើតឡើងក្នុងលោក, ព្រះអង្គបានយាងទៅកាន់ក្រុងពារាណសី ជាមួយនឹងព្រះខីណាស្រពពីរម៉ឺនអង្គជាបរិវារ ។ អ្នកក្រុងពារាណសី ពីរនាក់ក៏មាន បីនាក់ក៏មាន ច្រើនគ្នាក៏មាន បានបូករួមគ្នាថ្វាយអាគន្តុកទាន ដល់ព្រះអង្គព្រមទាំងខីណាស្រពជាសាវ័ក ។ គ្រានោះ មានសេដ្ឋីបុត្រ៤នាក់ ជាសម្លាញ់យ៉ាងជិតស្និទ្ធនឹងគ្នា ម្នាក់ៗមានសម្បត្តិ ៤០ កោដិ ។ សេដ្ឋីបុត្រទាំង៤នាក់នោះ ពិភាក្សាគ្នាថា» ទ្រព្យសម្បត្តិមាននៅក្នុងផ្ទះយើងច្រើនណាស់ តើយើងនឹងយកទ្រព្យសម្បត្តិទៅធ្វើអ្វី ? ។ កាលដែលព្រះពុទ្ធព្រមទាំងសាវ័កគង់នៅក្នុងទីនោះ សេដ្ឋីបុត្រទាំង៤នាក់, សូម្បីតែម្នាក់ក៏ពុំមានគិតឬនិយាយថា យើងនឹងឲ្យទាន, យើងនឹងធ្វើសក្ការបូជា, យើងនឹងរក្សាសីល ដូច្នេះសោះ, បែរជានិយាយថា « យើងនឹងនាំគ្នាផឹកសុរា ដែលមានរស់ខ្លាំង យើងនឹងទំពាស៊ីសាច់មានរស់ជាតិឆ្ងាញ់ យើងនឹងបរិភោគបាយកោដសាលីមានរសប្រសើរផ្សេងៗ យើងនឹងយកប្រាក់ទៅទិញចិត្តកូនក្រមុំប្រពន្ធអ្នកដទៃដែលល្អយកមកលេងសើចសប្បាយ» ។ ចាប់តាំងពីពេលនោះមក សេដ្ឋីបុត្រទាំង ៤ ក៏តាំងចាយវាយស៊ីផឹក យកលុយទៅទាក់យកកូន-ប្រពន្ធអ្នកដទៃ ដែលមានរូបល្អៗ មកប្រព្រឹត្តបរទារិកកម្ម

អស់កាលដ៏យូរអង្វែងឆ្នាំ, លុះអស់អាយុទៅ, ក៏ធ្លាក់ទៅកេះក្នុងអវិចីមហានរក អស់មួយចន្លោះព្រះពុទ្ធ, ដោយសេសសល់ផលកម្ម ក៏មកកើតក្នុងលោហកុម្ភីនរកប្រកបដោយយោជន៍៦០ ។

សេដ្ឋីបុត្រទាំង ៤ នេះ ត្រូវនាយនិរយបាលស្ទូរក្នុងខ្ទះទង់ទឹកលោហធាតុមានទំហំ ៦០ យោជន៍ អណ្ដែតក្នុងខ្ទះ ៣០ ឆ្នាំនរក ទើបមកដល់មាត់ខ្ទះ, លិចចុះទៅវិញ ៣០ ឆ្នាំនរក ទើបដល់ទៅបាតខ្ទះលោហធាតុវិញ ។ សេដ្ឋីបុត្រនរកទាំង ៤ នាក់នេះ, ដោយសេចក្ដីវេទនាខ្លាំងហួសកំរិតពេក ក៏កង់ចាលចង់បញ្ចេញពាក្យ បញ្ជាក់អំពីចិត្តកង់ចាលរបស់ខ្លួនម្នាក់ ៗ មួយគាថាគឺ :

សេដ្ឋីបុត្រទី ១ ចង់ពោលថា

ទុជ្ជីវិតមជីវិម្ហ យេ សន្តេ ន ទទាម្ហ សេ
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ហ អត្តនោ ។

យើងទាំងឡាយ មានជីវិតរស់នៅលំបាកខ្លាំងណាស់ កាលដែលភោគៈទាំងឡាយកំពុងមាន (ច្រើន) យើងទាំងឡាយនោះពុំបានធ្វើទាន យើងទាំងឡាយនោះឈ្មោះថា ពុំបានធ្វើនូវទីពឹងដល់ខ្លួន ។

សេដ្ឋីបុត្រទី ២ ចង់ពោលថា

សដ្ឋិវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។

កាលដែលយើងកំពុងឆេះក្នុងនរក ពាន់នៃឆ្នាំ ៦០ ទាំងឡាយពេញលេញសព្វគ្រប់ហើយ កាលណាហ្ន៎ទីបំផុត (នៃសេចក្តីទុក្ខ) នឹងមាន (ដល់យើងអេះ) ។

សេដ្ឋីបុត្រទី ៣ ចង់ពោលថា

នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ
តទា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស ។

ម្នាលអ្នកដូចជាខ្ញុំ ទីបំផុត (នៃសេចក្តីទុក្ខ) ពុំមានដល់យើងទាំង-ឡាយទេ, ទីបំផុត (នៃសេចក្តីទុក្ខ) នឹងមានមកពីណា, ទីបំផុត (នៃសេចក្តីទុក្ខ) មិនប្រាកដដល់យើងទាំងឡាយឡើយ ព្រោះថាក្នុងកាល (ដែលយើងកើតជាសេដ្ឋីបុត្រ) នោះ ខ្ញុំនឹងអ្នកទាំងឡាយ បានធ្វើប្រា-កដនូវបាប ។

សេដ្ឋីបុត្រទី ៤ ចង់ពោលថា

សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ ។

ខ្ញុំនោះ បើបានទៅអំពីលោហកុម្ភីនរកនេះទៅហើយបានកំណើតជាមនុស្ស នឹងជាអ្នកដឹងនូវ (ព្រះសទ្ធម្ម) ជាអ្នកមានសីល នឹងធ្វើនូវកុសលឲ្យច្រើន ។

តែដោយអំណាចទឹកលោហធាតុ ពុះក្តៅរំលេកព្រោលខ្លាំង សត្វ

នរកទាំង៤នេះ ហើយមាត់ពោលបានតែមួយម៉ាត់ម្នាក់ៗ នៅត្រង់អក្ខរៈដើមបាទនៃគាថានីមួយៗថា ទុ. ស. ន. សោ ប៉ុណ្ណោះឯងៗ

សេដ្ឋីបុត្រទាំង៤នាក់ ក្នុងនិទានខាងលើនេះសុទ្ធតែធ្លាប់បានកំណើតជាមនុស្ស ហើយជាមនុស្សថ្លៃថ្នូរ មានទ្រព្យសម្បត្តិច្រើនផងៗ តែដោយសេចក្ដីប្រមាទថា មានតែអញមានប្រាក់កាសចាយរាយច្រើន ប្រសើរជាងគេ គិតតែពីសប្បាយ ដើរស៊ីចាយផឹកស្រា ប្រព្រឹត្តអនាចារនឹងកូនប្រពន្ធអ្នកដទៃ ហេតុដល់ទៅធ្វើកំណើតមនុស្សរបស់ខ្លួនឲ្យវិនាសខូចក្លាយទៅបានកំណើតជាសត្វនរក ត្រូវនាយនិរយបាលចាប់យកទៅស្ងោរក្នុងខ្ទះទឹងទឹកលោហធាតុ ទើបត្រូវក់ខ្លួន បង់បានជាកំណើតមនុស្សវិញ ហើយថែមទាំងពោលថា បើបានមកកើតជាមនុស្សវិញ ពងបាលភ័យខ្លាចលែងហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ទៀតហើយ ៗ តែសំដីនឹងចិត្តភ័យខ្លាចរបស់សេដ្ឋីបុត្រទាំងបួននួ ពុំអាចឲ្យរួចរដោះឡើយ ព្រោះកាលខ្លួនកើតជាមនុស្ស បានប្រព្រឹត្តធ្វើអំពើខ្មៅអាក្រក់ហួសទៅហើយ ៗ

មែនពិត កំណើតមនុស្សរបស់បុគ្គលមួយរូបៗ អាចក្លាយទៅជាកំណើតតិរច្ឆាន អសុរកាយ ប្រេត នរក ឬក្លាយទៅជាកំណើតមនុស្សទេវតាបានដោយសារអកុសលកម្ម,ឬកុសលកម្មដែលបុគ្គលនោះបានធ្វើៗ

ន័យនេះ សម្ដេចព្រះពុទ្ធភាសិតថា កម្មំ សត្តេ វិភជ្ជតិ យទិទំ ហីនប្បណីតតាយ កម្ម គឺកុសលកម្ម និង អកុសលកម្ម តែងចែក

សត្វឲ្យថោកទាបនិងថ្លៃថ្នូរ ៗ ហេតុនេះ ពុទ្ធបរិស័ទទាំងឡាយ ដែលបានកើតជាមនុស្សហើយ គួរគប្បីរក្សាកំណើតមនុស្សនេះ ឬធ្វើកំណើតមនុស្សរបស់ខ្លួនឲ្យបានបរិវត្តន៍ពីហីនភាព ទៅឧត្តមភាព ពីទាសភាពទៅភុជិស្ស-ភាព មូឡ្ហភាពទៅបណ្ឌិតភាព ដោយខំលះបង់នូវអំពើក្រខ្វក់ទុច្ចរិត ហើយប្រព្រឹត្តសាងសន្សំកុសល មានរក្សាសីលនិងឲ្យទានជាដើម តាមកម្លាំងទ្រព្យនិងកម្លាំងសទ្ធាចុះ ៗ

ហេតុម្យ៉ាងទៀត បានកើតជាមនុស្សហើយ ត្រឹមមានលក្ខណៈជាមនុស្ស ៗ បានសេចក្ដីថា មានរូបរាងកាយទាំងមូលជាមនុស្សហើយ តែមានចិត្តគំនិតនិងចរិយាមារយាទខុសពីគន្លងធម៌ច្បាប់របស់មនុស្ស ៗ ជនប្រភេទនេះ ច្រើនជាមនុស្សពាល ចូលចិត្តប្រព្រឹត្តបាបធម៌ផ្សេងៗ តាមអំពើពុតពាលរបស់ខ្លួន មានលួច ប្លន់ កាប់សម្លាប់ បោកកុហកឆក់ប្រ-វ័ញ្ច បៀតបៀនមនុស្សសត្វគ្រប់ឲ្យរងទុក្ខវេទនាជាអនេកប្បការ ព្រោះទំនងនេះ ទើបលោកចែកប្រភេទមនុស្សជា ៤ គឺ :

ក) មនុស្សនេរយិកោ មានរូបរាងកាយជាមនុស្ស តែមានសេចក្ដីប្រព្រឹត្តដូចគ្នានឹងសត្វនរក ៗ

ខ) មនុស្សបេតោ មានរូបរាងកាយជាមនុស្ស តែមានចិត្តគំនិតការប្រព្រឹត្តប្រហែលគ្នានឹងប្រេត ៗ

គ) មនុស្សតិរច្ឆានោ មានរូបរាងកាយជាមនុស្ស តែមានអំពើ

អាក្រក់លំទាំសត្វតិរច្ឆាន ។

ឃ) មនុស្សភូតោ មានរូបកាយជាមនុស្ស ហើយមានចិត្ត គំនិតនិងចរិយាថ្លៃថ្នូរសមជាមនុស្ស ។

ង) មនុស្សទេវោ មានរូបកាយជាមនុស្ស ហើយមានចិត្ត ប្រសើរដូចទេវតា ។

២- កិច្ឆំ មច្ចាន ជីវិតំ បានកើតជាមនុស្សហើយ ក្រនឹង មានជីវិតរស់នៅ ។ ពាក្យថា «ជីវិត» បានដល់ធាតុក្ដៅម្យ៉ាង ដែល មានទំនាក់ទងយ៉ាងជិតស្និទ្ធនឹងរូបកាយរបស់មនុស្សសត្វ, ហើយ ត្រូវការសម្ភារៈច្រើនឥតគណនា ។ រូបកាយទាំងមូល ប្រៀបដូចជា សម្បុករបស់ជីវិតនេះឯង បើសម្បុកបែកបាក់ទៅ ជីវិតក៏វិនាសទៅដែរ ។ ជីវិតនេះ តូចក្រៃលែងតូច ឆ្មារក្រៃលែងឆ្មារ គ្មានពណ៌សម្បុរ ឬទ្រង់-ទ្រាយលក្ខណៈឲ្យល្មមមើលឃើញដោយមំសចក្ខុបានឡើយ ។ ជីវិតនេះ បើនឹងវិនាសទៅវិញ ក៏ពុំអាចដឹងបានងាយទេ ជួនក៏វិនាសតាមវ័យ ។ វ័យរបស់មនុស្សទាំង ៣ គឺ បឋមវ័យ, មជ្ឈិមវ័យ និងបច្ឆិមវ័យ គឺជាវ័យ របស់ជីវិតនេះឯង ។ តែជួនកាលជីវិតក៏វិនាស មិនដើរទៅតាមចង្វាក់វ័យ ទាំង ៣ នេះឡើយ ខ្លះស្លាប់ក្នុងបឋមវ័យ ខ្លះស្លាប់ក្នុងមជ្ឈិមវ័យ ខ្លះទៀត ក៏ស្លាប់ក្នុងបច្ឆិមវ័យ ។ ហេតុនេះហើយបានជាមានពាក្យពីបូរាណកាល ថា ស្លាប់មុនចាស់ ។ បុគ្គលដែលជាម្ចាស់ជីវិត, ដោយមានសេចក្ដីស្រ-

ឡាញ់យ៉ាងប្តូរផ្តាច់ទឹងជីវិតរបស់ខ្លួន  ក៏ខំប្រឹងប្រែងស្វះស្វែងរកគ្រឿងឧបភោគបរិភោគ  មិនខ្វាចនឿយហត់  យកមកចិញ្ចឹមបំប៉នថែរក្សាគ្រប់ពេលវេលា តែគង់ពុំបានសុខសាន្តគ្រប់កាលគ្រាឡើយ ។ ជួនកាលសុខស្រួល ជួនកាលមានជម្ងឺដំកាត់ មិនរើសពេលវេលា ជួនយប់ ជួនថ្ងៃ ។ ពោះបីថ្នាក់ថ្នម ជ្រើសរើសរកឱសថ ឬរកគ្រូពេទ្យជំនាញយ៉ាងណា ជួនក៏សមប្រកប ជួនក៏ពុំសមប្រកបដូចបំណងឡើយ ។ ពួកសត្វទាំងឡាយតែងមានសេចក្តីនឿយលំបាកច្រើនយ៉ាងណាស់ មាននឿយទឹងពាណិជ្ជកម្ម, កសិកម្ម, គោរក្ខកម្ម; កម្មករលីសែងជាដើម ប្រមូលបានកម្រៃប្រាក់កាសមកគ្រាន់តែសំរាប់ផ្គត់ផ្គង់ នូវសម្ភារៈឲ្យជីវិតនោះឯង ជួនគ្រប់ជួនពុំគ្រប់ ។ អង្គការរដ្ឋ  ក៏ដូចជាអង្គការឯកជនទាំងឡាយដែរ  គឺខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃ  រកសម្ភារៈយកមកឲ្យម៉ាស៊ីនជីវិតចំពាស៊ីតែប៉ុណ្ណោះ  ហេតុនេះហើយបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា „ជីវិតការរស់នៅនៃសត្វទាំងឡាយក្រ ។

៣- កិច្ឆំ សទ្ធម្មស្សវនំ បានរស់នៅហើយ ក្រទឹងបានស្តាប់ ឬបានជួបនូវព្រះសទ្ធម្មៈ  ពាក្យថា  ព្រះសទ្ធម្ម បានដល់ព្រះបរមពុទ្ធោវាទដែលប្រៀនប្រដៅសត្វលោកឲ្យលះបង់អំពើអាក្រក់  ឲ្យធ្វើអំពើល្អ  ឲ្យលះបង់កិលេសមានរាគៈ ទោសៈ មោហៈជាដើម  ឲ្យចំរើនកុសលធម៌ ឬច្បាប់សំរាប់ការពារសេចក្តីសុខដល់មនុស្សលោក ។ ព្រះសទ្ធម្មមានគុណ

វិសេសសំខាន់ច្រើនយ៉ាងណាស់ ទុកដូចជាប្រទីបសំរាប់បំភ្លឺផ្លូវដែលងងឹត ឲ្យសត្វដើរបានស្រួល ។ ព្រះសទ្ធម្មទុកដូចនាវា សំរាប់ចម្លងសត្វពីត្រើយនៃសេចក្តីទុក្ខៈក្តៅក្រហល់ក្រហាយ ឬឆ្លងមហាសមុទ្រភយន្តរាយ ទៅកាន់ត្រើយសុខក្សេមក្សាន្តសន្តិភាព ។ ព្រះសទ្ធម្មទុកដូចជាត្រីវិស័យ សំរាប់ចង្អុលទិសនាំដំណើរសត្វ ដែលកំពុងត្រាច់រង្គាត់វិលកើត-ស្លាប់ក្នុងវដ្តសង្សារ ពុំឲ្យវង្វេងទៅរកផ្លូវខុស ។ ព្រះសទ្ធម្មទុកជាមហាឱសថទិព្វ សំរាប់រម្ងាប់នូវភ្លើងកិលេស ដែលដុតពេលកលសត្វឲ្យបានក្តៅក្រហាយ ទៅជាត្រជាក់ស្រួល ។ ព្រះសទ្ធម្មទុកដូចជាម្លប់ ដែលសត្វកំពុងធ្វើដំណើរកាត់វាលវដ្តសង្សារ មានសេចក្តីក្តៅលំបាក អាចចូលទៅជ្រកក្រេបយកសេចក្តីសុខក្សេមក្សាន្តបាន ។ តែព្រះសទ្ធម្មនោះ ពុំមែនចេះតែកើតមានគ្រប់កាលឡើយ ។ កាលណាពុំមានព្រះពុទ្ធ ព្រះពោធិសត្វ ឬវីរបុរសអ្នកប្រាជ្ញកើតមាន ឬបានប្រតិស្ឋានទុកទេ, ពេលនោះក៏ពុំមានព្រះសទ្ធម្មដែរ ។ ក្នុងលោកទាំងមូលនេះ, ថ្វីបើព្រះសទ្ធម្មនៃព្រះបរមសម្ពុទ្ធបិតទៅឡើយ, តែបើយើងសង្កេតមើលឲ្យដិតដល់មែនទែនទៅ មានសម្បូរណាស់ តែពាក្យពុំមែនជាព្រះសទ្ធម្ម គឺជាពាក្យប្រទូសរាយព្យាបាទរុកគួនគ្នា ឈ្នានីសទៅវិញទៅមក ច្រើនលើសលុបឥតគណនា ។

សត្វលោកទាំងឡាយ បើខ្វះព្រះសទ្ធម្មហើយ មុខជាត្រូវអវិជ្ជាការរួបរិតគ្របសង្កត់ឲ្យងងឹតងងល់លែងយល់ផ្លូវត្រូវ ទៅប្រព្រឹត្តតែអំពើ

អនាធារ បង្កើតចលាចលដល់សង្គមភូមិស្រុកពុំខាន ។ សន្តិសុខ សន្តិភាពក៏វិនាសបាត់ទៅ ។ ទុក្ខលំបាកវិនាសអន្តរាយ ក៏ទឹងកើតប្រាកដលើទ្វីបលោកនេះ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងរឿងនេះ ទើបទ្រង់បង្កើតផែនការព្រះសម្មាសម្មស្សវនៈនេះឡើង ដោយផែលកទៅតាមទំនោសបវត្តិនកាលខ្វះ ទីងកាលចំហ ឬ កាលពិសេសក្រៅពីនេះខ្វះ មិនតែប៉ុណ្ណោះទ្រង់បានសរសើរថា ជាមង្គលដ៏ប្រសើរ សំរាប់មនុស្សទេវតា ដូចមានបទបាលីថា សទ្ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ការស្ដាប់នូវព្រះសទ្ធម្មនេះជាមង្គលដ៏ឧត្តម ។

មួយវិញទៀត ព្រះសទ្ធម្មក្រដោយហេតុពីរយ៉ាងគឺ

ក្រអ្នកសំដែង១, ក្រអ្នកស្ដាប់១ ។ ក្រអ្នកសំដែង គឺក្រអ្នកប្រាជ្ញដូចជាព្រះពុទ្ធជាដើម កើតឡើងក្នុងលោក ។ ក្រអ្នកស្ដាប់ គឺមានអ្នកប្រាជ្ញអ្នកសំដែងហើយ តែពុំមានអ្នកចូលចិត្តជឿស្ដាប់នូវព្រះសទ្ធម្មនោះ ឬស្ដាប់ដែរ តែស្ដាប់លែងៗ ពុំបានបញ្ចូនចិត្តស្ដាប់ម៉ត់ចត់ទៅតាមខ្សែនៃព្រះសទ្ធម្ម ។

មង្គលកាមបុគ្គលទាំងឡាយ កាលបើបានជ្រាបច្បាស់ថា ព្រះសទ្ធម្មក្រព្រះសទ្ធម្មមានតម្លៃកាត់មិនបានហើយ គួរតបញ្ញើសព្វាហ៍ ឆ្លៀតឱកាសត្រងត្រាប់ស្ដាប់តាមកាលគួរ ព្រោះការស្ដាប់នូវព្រះសទ្ធម្ម អាចញ៉ាំងសតិសម្បជញ្ញៈ និងប្រាជ្ញា ឲ្យភ្លឺថ្លាយល់ច្បាស់នូវព្រឹត្តិការណ៍ជុំវិញជីវិតបានជ្រៅឆ្ងាយផង អាចរម្ងាប់បង់នូវសេចក្ដីទុក្ខសោក ដែលកើតមានហើយឲ្យសាបសូន្យ

ទៅវិញផង អាចញុំាងប្រយោជន៍ឲ្យសម្រេចក្នុងលោកទាំងពីរ ដូចមាននិទានក្នុងគម្ពីរ មង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រ អំពីមណ្ឌុកទេវបុត្រថាៈ

ក្នុងធម្មសវនកាលមួយ ដែលពុទ្ធបរិស័ទទាំង៤ពួក កំពុងនាំគ្នាស្ដាប់មធុរៈទេសនារបស់ព្រះមានព្រះភាគ មាននាយគោបាលម្នាក់ បានមកដល់សវនដ្ឋាននោះហើយ ក៏មានចិត្តចង់ចូលទៅស្ដាប់ព្រះសទ្ធម្មដែរ ហើយចូលទៅអង្គុយបោងហោងមួយអន្ទើដោយដំបង ត្រង់ទីបំផុតនៃបរិស័ទសន្និបាត។ គាត់តែផ្ចង់ចិត្តស្ដាប់ធម្មទេសនា ក៏ច្រត់ចុងដំបងយ៉ាងធ្ងន់ទៅលើសត្វកង្កែបមួយ ដែលក្រាបសម្ងំពាប់ទៅនឹងផែនដី ។ មានសេចក្ដីថាៈ កង្កែបសូម្បីជាសត្វតិរច្ឆានតែមានគំនិតជាធម្មសញ្ញាគិតថា បើអាត្មាអញនឹងបំរះ ឬស្រែកថ្ងូរឡើងនោះ ការទេសនារបស់ព្រះមានបុណ្យមុខជារំខាន, មិនសម្រេចប្រយោជន៍ដល់វេនេយ្យសត្វ ដោយសារតែអាត្មាអញពុំខាន, ណ្ហើយចុះ រូបកាយនឹងជីវិតរបស់អញ ទោះឈឺចុកចាប់ ឬរលត់រលាយសូន្យសង្ខារនៅពេលនេះ ក៏តាមយថាកម្មចុះ អញនឹងពុំស្រែក ឬបំរះឡើយ ។ ដោយភាពជាសត្វមានរូបកាយតូច ពុំអាចទប់ទល់នឹងកម្លាំងដៃរបស់នាយគោបាលបាន, កង្កែបក៏ធ្វើមរណកាលក្នុងគ្រានោះទៅ ហើយបានទៅកើតក្នុងទេវលោក សោយសុខសម្បត្តិទិព្វមាននាមប្រាកដថា «មណ្ឌុកទេវបុត្រ» ។

ការស្ដាប់នូវព្រះសទ្ធម្មក្រ មានន័យម្យ៉ាងទៀតថា សត្វលោកកាល

បើត្រូវនីវរណៈគ្របដណ្ដប់ហើយ ពុំអាចស្ដាប់ព្រះសទ្ធម្មឲ្យសម្រេចប្រយោជន៍បានឡើយ ។ នីវរណៈនោះរាំងដឹកនាំចិត្តឲ្យរវើរវាយងងុយងោកងក់ លែងយល់ជ្រុងជ្រោយព្រះសទ្ធម្មអស់ ។ ឯនីវរណៈ៥នោះគឺ:

ក) កាមច្ឆន្ទៈ ស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍មានរូបជាដើម ដែលជាទីគាប់ចិត្ត ។

ខ) ព្យាបាទៈ ចងចិត្តគំគួនអ្នកដទៃ ដែលទំនាស់នឹងចិត្ត ។

គ) ថីនមិទ្ធៈ ដំណើរដែលចិត្តរួញថយ និងដំណើរងងុយងោកងក់ ។

ឃ) ឧទ្ធច្ចកុក្កុច្ចៈ ដំណើរដែលចិត្តរាយមាយនឹងរសាប់រសល់ ។

ង) វិចិកិច្ឆា សេចក្ដីសង្ស័យមិនចេះដាច់ស្រេចក្នុងព្រះសទ្ធម្ម ។

ការស្ដាប់នូវព្រះសទ្ធម្មជាការក្រយ៉ាងនេះឯង បានជាព្រះមានព្រះ-ភាគទ្រង់ត្រាស់ថា កិច្ឆំ សទ្ធម្មស្សវនំ ការស្ដាប់នូវព្រះសទ្ធម្មក្រ ។

៤. កិច្ឆោ ពុទ្ធានមុប្បាទោ កម្រនឹងមានព្រះពុទ្ធកើតមានឡើងក្នុងលោក ។ ពាក្យថា ព្រះពុទ្ធ ជាពាក្យតែមួយគត់មាននៅលើទ្វីបលោក ពុំងាយនឹងបុគ្គលណាយកឈ្មោះនេះទៅដាក់លើខ្លួនបានឡើយ ។ បុគ្គលដែលបាននាមថាព្រះពុទ្ធ ក៏ពុំមែនបានដោយសារ ដាក់ឈ្មោះខ្លួនឯងដែរ ។ ឈ្មោះថា „ព្រះពុទ្ធ" គឺជានាមាភិធេយ្យដែលព្រះមានព្រះភាគទាំងឡាយ បានទទួលក្រោយអំពីព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មា-

សម្ពោធិញ្ញាណ ។ ការត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណនេះ ក៏បាន
មកក្រោយពីព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ បានបំពេញនូវពោធិបារមីកប់
អនេកជាតិ ៗ ក្នុងពេលសាងបារមី ព្រះអង្គបានយករូបកាយនិងអាយុជីវិត
ទៅប្តូរផ្តាច់នឹងពោធិញ្ញាណនោះ គឺទ្រង់បានពុះទ្រូងរូងយកថ្លើម អារសាច់
សំរក់ឈាមធ្វើជាទានក្នុងការបំពេញទានបារមីជាអាទិ៍ ទ្រង់ធ្វើយ៉ាងនេះ
មិនមែនកប់តែមួយជាតិ ឬមួយអាយុជីវិតនៃមនុស្សសត្វឡើយ គឺកប់
អាយុកល្បនៃផែនដីជាច្រើនអសង្ខេយ្យជាតិ ទើបបានសម្រេចបំណងជា
ព្រះពុទ្ធមួយព្រះអង្គក្នុងលោកនេះ ។ ហេតុនេះហើយ បានជាព្រះបរមគ្រូ
ទ្រង់ត្រាស់សំដែងថា កិច្ឆោ ពុទ្ធានមុប្បាទោ កម្រនឹងមានព្រះ-
ពុទ្ធកើតឡើងក្នុងលោក ។

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាន់ ខាត់ រៀបរៀង*

អនិមុត្ត គុ. ដែលមិនរួច, ដែលដោះមិនបាន ។

អនិលោកិត គុ. ដែលមិនប្រឹងមើល. ដែលមិនពិនិត្យ ។

អនិលោឱិត គុ. ដែលមិនរកមើលឲ្យល្អិតល្អន់ ។

អនីវិបនីយ គុ. ដែលមិនគប្បីពោលបញ្ជាក់ ។ អនិវិប្យ គុ ដូចគ្នា ។

អនិវិណ៌នីយ គុ. ដែលបុគ្គលមិនគប្បីសរសើរ ។

អនិវិត្យមាន គុ. ដែលមិនសម្រេច, ដែលមិនបិទមិនបាន ។

អនិវិណ គុ. ដែលមិនរលត់ ។

អនិវិណ្ណ គុ. ដែលមិនធ្លាក់ចុះ ។

អនិវិទ្ធ  គុ. ដែលមិនរួញរា ។

អនិវិជិត្យ  គុ. ដែលមានបំណងនឹងសម្រេច ។

អនិវត្ត ឬ ត្ត  គុ. ដែលមិនប្រព្រឹត្តទៅ, ដែលមិនសម្រេច ។

អនិវេទ  បុំ. ការទុកចិត្តខ្លួនឯង, ការមិនរួញរា, សេចក្ដីក្លាហាន ។ –ករ គុ. ដែលធ្វើនូវសេចក្ដីក្លាហាន, ដែលមិនខ្សោយហាក់ ។

អនិវេទិត  គុ. ដែលមិនដាក់ស្ដែង, ដែលមិនសំដែងអាការវាចយ, ដែលអង់អាច ។

អនិវេគ  គុ. ដែលមិនអស់បាប ។

អនិហិត  គុ. ដែលធ្វើយញ្ញៈ ។

អនិប្រាទិន គុ. ដែលមិនឲ្យសម្លេង ។

អនិល  បុំ. ខ្យល់, ព្រះពាយ, នាមនៃរាក្សសៈ ; រោគខ្យល់ ដូចរួយស្រពន់, រោគស្ពឹក ។ –កុមារ, បុំ. ពហុ ជាន់នៃទេពតាមួយពួក សាសនដៃនៈ ។ –ឃ្ន គុ ដែលរំលើងដោយខ្យល់ ។ –ឃ្នក បុំ. ឈ្មោះឈើ ។ –បហ គុ. ដូចអនិឃ្ន ។ –វ្យាធិ បុំ. ការបៀតបៀនដោយរោគខ្យល់ ។ –សខ បុំ. "មានខ្យល់ជាសំឡាញ់" ឬ –សារថិ បុំ.

“មានខ្យល់ជាសារថី”, ភ្លើង, នាមនៃភ្លើង ។– សិភាវី បុ. នាមនៃភ្លើង ។ – ហានិ ឬ ហ្បានី គុ. ដូចអនិលឃ្ន ។ អនិលាត្មជ (អនិល+អាត្មជ) បុ “កូននៃខ្យល់” ហនុម័ត ឬ ភីម ។ អនិលាឃបហ គុ. ដូច អនិលឃ្ន ។ អនិលាមយ បុ. រោគខ្យល់, រោយស្រពន់ អនិលាយន នបុ. ផ្លូវខ្យល់ ។ អលាគន (អនិល+អគន) បុ “ស៊ីខ្យល់” ខ្លស់ ។ អនិ-លាគិន គុ “ស៊ីខ្យល់” ខ្លស់ ។ អនិលាហតិ (អនិល+អហតិ) ស្រ្តី. ខ្យល់បោក ។ អនិលាង្កុរ (អនិល+អង្កុរ) បុ. “ខ្យល់បំផ្លាញ” ដើមឥង្គុទី ឬ អង្គារបុស្បា ។

អនិលយ គុ. ដែលមិនមានទីសំនៅ ។

អនិលយន គុ. ដែលមិនមានផ្ទះ, មិនមានជម្រក, ដែលមិនមានសរណៈ ។

អនិវត្តិន គុ ដែលមិនវិលត្រឡប់, ដែលនៅនឹងកន្លែង, ដែលមិនផ្លាស់ប្តូរ។

អនិវត្តិត្វ នបុំ ភាវនៃកិរិយាមិនវិលត្រឡប់, ភាពគស៊ូ ។

អនិវារណ នប៉ុ. កិរិយាមិនឃាត់ ។

អនិវារិត គុ. ដែលមិនឃាត់ ។

អនិវិទ្ធ គុ. ដែលមិនមុតធ្លុះ ។

អនិវិដ្ឋ គុ. ដែលមិនរៀបចំការ ។

អនិវត្ត គុ ដែលមិនវិលត្រឡប់, ដែលមិនថយក្រោយ, ក្លាហាន, មុះមុត។

អនិវេទក គុ. ដែលមិនសម្តែង, ដែលមិនប្រាប់, មិននិយាយ ។

អនិវេទន នប៉ុ. កិរិយាមិនសំដែង, កិរិយាមិនប្រាប់ ។

អនិវេទិត គុ. ដែលមិនប្រាប់, ដែលមិននិយាយ ។ – វិជ្ញាត គុ. ដែលដឹងដោយកិរិយាមិនប្រាប់ ។

អនិឝ គុ. " ឥតយប់" ការដេកមិនលក់, ដែលមិនដាប់តង្ហា, រដឹក ។

អនិឝម៑ ក្រិ.វិ. ជំរដឹក ។

អនិឝាន្ត គុ. ដែលមិនរលត់, ដែលមិនស្ងប់ ។

អនិឝ្ចយ ប៉ុ. អនិស្ច័យ, កិរិយាមិនទាន់គិតស្រេច ។

អនិឝ្ចិត គុ. ដែលមិនប្រាកដ ។ – តា ស្ត្រី ភាពនៃកិរិយាមិនប្រាកដ។

អនិះឝេឞិត គុ. ដែលមិនទាន់រលត់អស់រលីង ។

អនិឞង្គ គុ. ដែលមិនញាប់ញ័រ ។

អនិឞវ្យ គុ. ដែលមិនគប្បីស្លាប់ដោយព្រួញ ។

អនិឞិទ្ធ គុ. ដែលមិនអនុញ្ញាត, ដែលមិនការពារ ។

អនិឞុ គុ. ដែលមិនមានព្រួញ ។–ធន្វ គុ. ដែលមិនមានព្រួញនឹងធ្នូ ។

អនិឞ្កៈធ្វឫក៑ គុ. ដែលមិនពាក់គ្រឿងប្រគោង ឬ ទំហូ ។

អនិឞ្កឫត គុ. ដែលមិនទាន់សម្រេច, ដែលមិនទាន់ហើយ ។

អនិឞ្ដ គុ. ដែលមិនប្រាជ្ញា, ដែលអាក្រក់, ដែលខុស, ដែលផ្ទុយនឹងច្បាប់, ដែលហាម ។ នបុំ. អពមង្គល, ព្រឹត្តិការណ៍មិនល្អ ។ អនិឞ្ដា ស្ត្រី. ឈ្មោះឈើ ។ – ហគ្រ បុំ. អនិឞ្ដ-គ្រោះ នក្ខត្តឫកមិនល្អ ។ – ទុឞ្ដធី គុ. ដែលមានចិត្តអាក្រក់ផង ប្រទុស្តផង ។ – ប្រសង្គ បុំ. កិរិយាលាយដោយវត្ថុមិនល្អ ឬ ដោយច្បាប់ខុស ។ – ផល បុំ. ផល-សង្កា ស្ត្រី. ទំនាយពីហេតុអាក្រក់, សេចក្ដីខ្លាចពីហេតុអាក្រក់ ។ – សូចក គុ. ដែលទាយពីហេតុអាក្រក់ ។ – ហេតុ បុំ. ហេតុអាក្រក់, ការទាយអាក្រក់ ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជៈសេនា នូ-កាន ប្រែរៀបរៀង

(តអក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកភិងវៃឆ្លាស់បើបានអាន |
| នឹងចេះទាយកលចំណាន |
| ទាំងមានសន្តានស្នេហាជាតិ |
| យូរ-អ៊ុន |

ទៅចូថា យើងមានកម្លាំងពលំហើយ មិនត្រូវខ្លាចអ្វីទេ ពេលយប់នេះក៏មានខែភ្លឺដូចថ្ងៃ យើងនឹងបង្អង់នៅធ្វើអ្វី ទៅចូក៏ឡើងសេះនាំមុខរទេះទៅ ដល់ពេលប្រហែលយាម១បាយ ក៏ទៅដល់ក្នុងក្បែរផ្លូវជិតបន់ស្រុកប៉ាដីវ ហើយបានឮស្នូរស្គរ នឹងសំឡេងត្រែអឺងកង ៗ

ទៀវហ៊ុយឃើញដូច្នោះ ក៏បំផាយសេះ កាន់លំពែងតម្រង់ទៅដេញទៅចូ ៗ ទៅចូតច្បាំងគ្នានឹងទៀវហ៊ុយ ដោយកម្លាំងស្រវឹងស្រាខ្លាំងណាស់ មិនទាន់បានប៉ុន្មានគ្នេង ទៀវហ៊ុយ ក៏លើកលំពែងចាក់ត្រូវទៅចូ ត្រង់ស្មាធ្លាក់ពីលើសេះ នោះពួកទាហានដែលនៅជាមួយនឹងទៅចូក៏រត់បោលរទេះទាំងអស់ ស្ទុះស្រទៅឱបពយកទៅចូនាំរត់ចេញទៅបាន ទៀវហ៊ុយក៏យកបានរទេះស្បៀង នាំត្រឡប់ទៅវិញ ទាហានដែលគ្រាហ៍ទៅចូយកទៅនោះក៏នាំចូលទៅដល់ចូចូ ៗ ឃើញដូច្នោះក៏ឲ្យពេទ្យទៅព្យាបាល

រក្សាបួសនោះ ហើយចូចូក៏លើកទ័ពត្រឡប់មក ធ្វើសង្គ្រាមនឹងឡៅតីវិញ ឯឡៅតីឃើញចូចូ លើកទ័ពត្រឡប់មក ក៏ឲ្យឡៅហងលើកទាហានចេញទៅ ចូចូថា អាឡៅតីវាប្រើអាឡៅហងជាកូនគេលក ម្តេចក៏ហ៊ានមកតស៊ូនឹងយើងមិនគួរសោះ យើងនឹងឲ្យកូនយើងឈ្មោះ ចូជៀងពុកមាត់លឿងចេញទៅតស៊ូកាប់ឲ្យល្អិតសាច់ឲ្យអស់ ឡៅហងឮដូច្នោះក៏ខឹងណាស់ បំផាយសេះកាំលំពែង ចូលដេញទាហានចូចូ ៗ ក៏ប្រើស៊ុយឡុងចេញទៅត ឡៅហងធ្វើជាកន្ទ្រាក់សេះរត់ ត្រឡប់ទៅក្រោយ ចូចូក៏លើកទាហានដេញបណ្តោយ តាមឡៅហងទៅ ៗ

ឡៅតីនៅក្នុងបន្ទាយក្រឡេកឃើញ ក៏ឲ្យទាហានដុតផាវវាយឃ្មោះគោះគងទូងស្គរ ផ្លុំត្រែត្រសន្ទឹកសន្ទាប់ ចូចូឃើញថាមានទាហានពួនបង្កប់ ក៏ទឹកគក់ស្លុត រន្ធត់ខ្លាច ឲ្យទាហាន ត្រឡប់ថយទៅវិញ លុះទៅដល់ផិតកំពែង គយអេងបេងគួន ដែលជាទីនៅនោះ ទាហានឡៅតីដេញទៅទាន់ព័ទ្ធ ហោមជុំ ទាំង ៤ ទិស ខ្លះក៏ដុតភ្លើងស្រែកហៅឡើងព្រមគ្នា ចូចូភ័យណាស់ក៏ រត់ចេញពីទីនោះទៅទៀត ៗ

ខណៈកាលចូចូរត់ទៅនោះ ទៀវហ៊ុយក៏លើកទាហានមួយពួកទៅស្កាត់ពីខាងមុខ ជូឡុងលើកទាហានមួយពួក ដេញប្រកិតពីខាងក្រោយបណ្តោយទៅ ហងគុងលើកទាហានមួយពួកចេញពីផ្លូវដំបន់ស្រុកប៉ោជីវ លុះចូចូរត់ទៅដល់ដំបន់រូងភ្នំ សៀតកុក ក៏ឃើញផងធូលីហុយទ្រលោម

ឡើង មានទាហាន១កងលើកមក ចូចូស្មានថាទាហានឡៅពីមកបន្តប់នៅ ទីនោះ ក៏គិតតែក្នុងចិត្តថា យើងមុខជាស្លាប់មួងណោះហើយ កំពុងតែទឹក ដូច្នោះ ពួកនោះក៏មកដល់ជិត ក្រឡេកទៅឃើញចូជៀងជាកូនទី ២ លើកមកក៏សប្បាយចិត្តណាស់ ឯចូជៀងនោះកាលនៅពីក្មេងតូចនៅឡើយ រមែងជិះសេះបាញ់ធ្នូ មានកម្លាំងលើសជាងមនុស្សទាំងឡាយ ចូចូជាឪពុកក៏បានប្រដៅថា ចៅមិនចូលចិត្តរៀន សំបុត្រអក្សរទេឬ បានជាចូលចិត្តជិះសេះបាញ់ធ្នូដូច្នេះ ឯសិល្បសាស្ត្រនេះ សំរាប់តែអ្នកមានកំឡាំងម្នាក់ឯងទេ មិនមានកិត្តិយសល្បីល្បាញដូចអ្នកចេះសំបុត្រអក្សរនោះឡើយ ។

ចូជៀងនិយាយនឹងឪពុកថា សិល្បសាស្ត្រយ៉ាងនេះជាសិល្បសាស្ត្រសំរាប់ជាតិប្រុសទាំងអស់គ្នា អាចនឹងមានបុត្តាគ្រប់គ្រងលើទាហានរាប់-សែន ក្នុងការរក្សាផែនដីគាប់ប្រសើរប្រពៃលើសជាងអ្នកចេះសំបុត្រស្នាមទៅទៀត ចូចូសួរកូនទាំងអស់គ្នាថា ដែលចូជៀងនិយាយយ៉ាងនេះ ចិត្តកូនឯទៀត នរណានឹងស្រឡាញ់ចូលចិត្តប្រការម្ដេចកូនទាំងអស់ក៏នៅស្ងៀម តែចូជៀង១ឆ្លើយតបថា ខ្ញុំបាទស្រឡាញ់ធ្វើទាហាន ។

ចូចូថាបើធ្វើជាទាហាននោះ កាលចៅចូលតស៊ូសង្គ្រាមនឹងធ្វើប្រការម្ដេច ក្នុងក្បួនសង្គ្រាមនោះ ចូជៀងថា ខ្ញុំបាទធ្វើសង្គ្រាមនឹងសត្រូវនោះ

ទីងពាក់អាវក្រោះ កាន់អាវុធចេញនៅមុខទាហានទាំងពួង ទោះនឹងស្លាប់ចុះយ៉ាងណា កំមិនអាល័យដល់កូនប្រពន្ធឡើយ បើទាហានឯណាមានសេចក្តីគាប់ប្រសើរក្នុងការសង្គ្រាម ក៏ទីងឲ្យបំណាច់រង្វាន់តាមគុណានុរូប បើនរណាធ្វើខុសល្មើស ក៏ត្រូវធ្វើទោសតាមទោសានុទោសាឬប្រហារជីវិតបង់ ។

ចូចូពុដូឡោះ កំពេញចិត្តណាស់អស់សំណើចហើយថា ចៅគិតហ៊ាន់ខេះគួរប្រពៃណាស់ ខណៈនោះព្រះចៅហៀនតេទៅគង់នៅក្រុងហ៊ូតោ ២៣ ឆ្នាំ ទទួលអហ្គូននៅស្រុកតៃកុនគិតក្បត់ ចូចូក៏ប្រើចូជៀងជាបុត្រលើកទាហាន ៥០-០០០ ទៅសង្កត់ស្រុកតៃកុន ហើយប្រដៅរំឭកថា បើយើងនៅផ្ទះសម្បែងក្នុងស្រុកភូមិ ក៏នៅជាអាពុកជាកូនតាមធម្មតា បើកាលណាចេញទៅធ្វើសង្គ្រាម ក៏ដូចជាខ្ញុំនិងម្ចាស់ទៅវិញ កុំបីគិតប្រមាណ បើខុសហើយ ត្រូវតែធ្វើទោសតាមខុស បិតារំឭកប្រដៅចៅដូច្នេះ ចូរចងចាំទុកក្នុងចិត្តចុះ លុះនិយាយប៉ុណ្ណោះហើយ ចូជៀងក៏លាបិតាលើកទ័ពចេញទៅដល់ស្រុកតៃកុននៅទិសខាងជើង ក៏ចូលទៅច្បាំងនឹងអហ្គូន វេលានោះអហ្គូនក៏ចាញ់ទ័ពចូជៀងរត់ទៅនៅដំបន់សង់ខៀន ចូជៀងក៏ប្រាប់ប្រាម ស្រុកតៃកុនបានរាបទាបហើយ ទទួលពុ្ធដំណឹងថា ចូចូជាបិតាទៅតាំងទ័ពនៅគយអេង បេងគួន ចូជៀងក៏លើកទ័ពឈៀងចូលទៅជួយ ។

ចូចូបានឃើញ ចូជៀងជាបុត្ររបស់ខ្លួន ច្បាស់ក៏អរណាស់ ទើប

និយាយថា អើចៅពុកមាត់ស្លៀង បុត្រយើងមកដល់ហើយឬ បើដូច្នោះការដែលយើងច្បាំងនឹងឡាវពីនោះមុខជាមិនប៉ុន្មានទេ រួចក៏នាំគ្នាលើកទ័ពនោះទៅបោះបន្ទាយនៅភ្នំសៀតកុក វេលានោះមានគេនាំដំណឹងកងជការទៅប្តឹងឡាវពីថា ឥឡូវប៉ូចូនាំប៉ូជៀងជាបុត្រលើកទ័ពត្រឡប់មកទៀតហើយ ។

ឡាវពីឮដូច្នោះ ក៏សួរទាហានទាំងអស់ថា នរណានឹងយកអាសាចេញច្បាំងនឹងប៉ូជៀងបាន ឡាវហាន់ឆ្លើយទូលថា ខ្ញុំបាទសុំទទួលយកអាសាចេញទៅច្បាំង វេលានោះបេងតាត់បានឮក៏ឆ្លើយថា ខ្ញុំបាទនឹងសុំទៅផង ឡាវពីថា គ្រានេះយើងនឹងមើលថ្វៃដៃអ្នកទាំងពីរសិន តើនរណាគ្រាន់បើជាងនរណា ហើយក៏ចាត់ទាហានឲ្យម្នាក់ ៥.០០០, ឡាវហាន់ជាទ័ពមុខបេងតាត់ជាទ័ពជំនួយ លាឡាវពីហើយក៏លើកទ័ពទៅ ។

លុះទៅដល់ទ័ពប៉ូជៀងក៏ចូលច្បាំងគ្នានឹងប៉ូជៀងបាន ៣ ក្បួន ឡាវហាន់ចាញ់ក៏ថយទ័ពត្រឡប់មកវិញ បេងតាត់ឃើញដូច្នោះក៏ដេញទាហានជាជំនួយចូលទៅ កាលនឹងចូលទៅច្បាំងនោះ ឃើញទាហានប៉ូចូនឹងប៉ូជៀងជ្រួលច្របល់ ហេតុព្រោះម៉ាឈៀវនឹងឆ័ឡាន់ ទាហានឡាវពីលើកតាមច្បាំងមកពីក្រោយទៀត ១ ពួក បេងតាត់យល់បានចំណាប់ក៏ឲ្យទាហាន ស្រែកហោចូលវាយ ប្រសព្វខ្ទប់គ្នានឹងទ័ពម៉ាឈៀវទាំងសង-ខាង ពួកទាហានប៉ូចូក៏បែករត់ទៅ ។

ឯចូដៀងនោះ លុះឃើញទ័ពបែកហើយ នៅតែខ្លួន ១ ចូលច្បាំងនឹងងឺឡាន់ មិនទាន់បាន ១ ភ្លែង ចូដៀងក៏ លើកលំពែងចាក់ត្រូវទីសំខាន់ ងឺឡាន់ធ្លាក់ពីលើសេះស្លាប់ ទាហានទាំងសងខាងក៏ត្រឡប់ចូល ប្រកាប់គ្នាទៀតមិនទាន់ចាញ់ឈ្នះគ្នា ចូឆូក៏ឲ្យទាហានថយ ត្រឡប់ទៅឈប់នៅរូងភ្នំសៀតកុក ចូឆូគិតតែក្នុងចិត្តថា តាំងពីមកតាំងទ័ពនៅទីនេះជាយូរពេលហើយ បើនឹងលើកចេញទៅវេលានេះ ទាស់នឹងម៉ាឈៀវនៅទទឹងពីមុខ ទឹកអៀនខ្មាសដល់សត្រូវក៏ឈប់នៅក្នុងទីនោះទៀត មិនទាន់លើកទៅ ។

វេលានោះ ពួកអ្នកធ្វើបាយឲ្យចូឆូ លុះដល់ព្រលប់លើកយកមាន់ (ស្ងោ) មួយចូលទៅថ្វាយ ចូឆូ ។ ស៊ីសាច់មាន់អស់ហើយ នៅសល់តែឆ្អឹង ទើបយកចង្កឹះ ចាប់យកជើងមាន់ (ស្ងោ) ស្ទួយឡើងនឹករំពឹងតែក្នុងចិត្ត ថា នឹងចោលទៅឲ្យនឹកស្ដាយ ព្រោះវាឆ្ងាញ់ណាស់ ជើងមាន់នេះប្រៀបដូចធ្វើការសង្គ្រាមគ្រានេះ បើនឹងលះបោលក៏អាប់យស នឹងធ្វើឲ្យបានជ័យជំនះក៏មិនស្រួល ។

កាលចូឆូរំពឹងនៅនោះ ទទួលហៃហ៊ូទុនចូលទៅទូលសួរថា វេលាយប់នេះ នឹងហៅឈ្មោះអ្វីជាសំគាល់ស្រែកយាម ចូឆូរវល់តែពិគ្រោះជើងជាប់ចិត្តក៏ភ្ញាត់មាត់ចេញទៅថា ជើងមាន់ អៀវស៊ីវសមុហបញ្ជីកងទ័ពនោះមានប្រាជ្ញាឆ្លាតណាស់ ក៏ដឹងនូវបទស្រែកយាមតាមសំដីចូឆូថាជើងមាន់

នោះ កំប្រាប់ទាហានជាពួកម៉ាករបស់ខ្លួនថា ឲ្យប្រុងប្រៀបរៀបចំបំរុងខ្លួនឲ្យស្រេចចុះ ទឹងលើកទ័ពទៅហើយ ។

ខណៈនោះ មានទាហានម្នាក់មកប្រាប់ហៃហ៊្វុនថា អៀវស៊ុីវឲ្យបក្ខពួក ត្រៀមខ្លួនបំរុងទឹងលើកទ័ពត្រឡប់ទៅហើយ ហៃហ៊្វុនឲ្យហៅអៀវស៊ុីវមកសួរថា អ្នកឯងដឹងយ៉ាងម្តេច បានជាថាទឹងលើកទ័ពទៅនោះ អៀវស៊ុីវថា ខ្ញុំបានឮស្រែកយាមថាដើងមាន់ក៏ចូលចិត្តថា ចូចូទឹងលើកទ័ពត្រឡប់ទៅវិញ បានជាប្រាប់ឲ្យត្រៀមទាហានទុក ហៃហ៊្វុនបានឮក៏ស្ងុតស្ងាត់ ទើបតាំងបង្គាប់ពួកទាហានឲ្យប្រុងប្រៀបរៀបខ្លួនទាំងអស់គ្នា ។

ចូចូនោះ លុះដល់ពេលកណ្តាលយប់មិនសប្បាយចិត្តសោះ បេះតែដើរទៅមកជុំក្នុងបន្ទាយ ឃើញអស់ពួកទាហានប្រុងប្រៀបរៀបខ្លួន ដូចជាទឹងចេញដំណើរទៅ ក៏ទឹកឲ្យពិគាល់ក្នុងចិត្តណាស់ ចូចូត្រឡប់មកទីកន្លែងវិញ ឲ្យហៅហៃហ៊្វុនមកសួរថា ទាហានទាំងអស់រៀបខ្លួនដូច្នេះ តើជាយ៉ាងម្តេច ហៃហ៊្វុនថាអៀវស៊ុីវមកប្រាប់ទូលបង្គំថា ទឹងលើកទាហានទៅហើយ ចូចូឲ្យហៅអៀវស៊ុីវ ចូលមកសួរថា អ្នកឯងបានប្រាប់ហៃហ៊្វុនថា ទឹងរៀបលើកទ័ពទៅនោះ តើដឹងយ៉ាងម្តេច អៀវស៊ុីវទូលថា ទូលព្រះបង្គំបានឮទាហាន (ស្រែកយាម) ថា.ដើងមាន់ក៏ដឹងថាទឹងលើកទ័ពទៅ ចូចូឮដូច្នោះ ក៏ខឹងណាស់ថា អ្នកឯងនាំនិយាយដូច្នេះ ខុសណាស់ គឺកុំឲ្យទាហានយើងខូចចិត្តគំនិតញញើតខ្លាច ទោសអ្នកឯងត្រូវស្លាប់

ទើបប្រើតាហានឲ្យយកខ្លួន អៀវស៊ីវទៅកាត់ក្បាល ដោតនៅទ្វារបន្ទាយ មិនឲ្យតាហានទាំងពួងយកយឿងយ៉ាងតាម ។

ឯអៀវស៊ីវនេះ ពីដើមមករមែងជាមនុស្សអំនួតលើកខ្លួនថាវិជ្ជាល្អប្រសើរលើសគេ ចូចូក៏នឹកកោតញញើតអៀវស៊ីវជាដរាប ពីកាលដែលមានមនុស្សកំណាចគិតប្រទូសរ៉ាយចូចូ ឧបាយប្រាប់មនុស្សទីទុកទុកចិត្តថា យើងដេកអាក្រក់ណាស់ កុំឲ្យនរណាចូលទៅជិត ព្រោះយើងតែងមមើកាប់ស្លាប់ មានថ្ងៃមួយពេលកណ្ដាលថ្ងៃ ចូចូធ្វើជាដេកលក់នៅលើគ្រែ ក្លែងធ្វើជាធ្លាក់ភួយពីលើគ្រែអស់ វេលានោះមានបាវបំរើផ្ទាល់ម្នាក់ចូលទៅលើកភួយនោះដណ្ដប់គ្របឲ្យចូចូ ធ្វើជាមមើក្រោកឡើងកន្ត្រាក់ក្របីកាប់មនុស្សនោះស្លាប់១រំពេចទៅ ហើយត្រឡប់ប្រះដេកទៅវិញ បានមួយស្របក់ក៏ក្រោកឡើង ក្លែងធ្វើជាភិតភ័យណាស់សួរថា នរណាមកសម្លាប់មនុស្សជំនិតរបស់អញដូច្នេះ មនុស្សក្នុងទីនោះក៏ឆ្លើយដោយត្រង់ថា លោកសម្លាប់ខ្លួនឯងទេតើ ចូចូធ្វើជាយំសោកស្ដាយ ហើយបង្គាប់ឲ្យយកសពនោះទៅបញ្ចុះ តាមសមគួរ មនុស្សទាំងអស់មិនដឹងដល់ក៏និយាយថា ចូចូដេកកាចអាក្រក់ រមែងមមើសម្លាប់មនុស្ស មានតែអៀវស៊ីវ ១ ដែលដឹងកលឧបាយចូចូ កាលដែលនាំយកខ្មោចមនុស្សស្លាប់ទៅកប់ ក៏កើតសេចក្ដីអាណិត និយាយនឹងខ្មោចនោះថា មហាឧបរាជមិនមែនដេកមមើកាចទេ គឺជាកម្មរបស់អ្នកឯង ដែលមកត្រូវស្លាប់ឥតកំហុសដូច្នេះ

ចូឆូដឹងហេតុនោះក៏ចាំទុក គិតថា អៀវស៊ីវដឹងកលឧបាយក៏នឹកខឹងតែក្នុងចិត្ត ។

មួយទៀត ចូឆូចង់ល្បងមើលគម្រិប្រាជ្ញាចូស៊ិត និងចូភី ជាបុត្រទាំង ២ នាក់ ទើបប្រើឲ្យដើរចេញទៅក្រៅទ្វារវាំង ហើយចូឆូប្រើមនុស្សឲ្យទៅលបស្ដាប់ប្រាប់ហាមអ្នកយាមទ្វារថា ថ្ងៃនេះកុំឲ្យនរណាចេញទៅក្រៅ ឯចូភីដើរទៅដល់ទ្វារហើយក៏ចេញទៅ នាយទ្វារឃាត់មិនឲ្យចូភីចេញ ចូភីក៏ត្រឡប់ចូលមកវិញ ឯចូស៊ិតដឹងថានាយទ្វារហាមឃាត់មិនឲ្យចូភីជាបងចេញទៅក៏មានចិត្តអាណិតណាស់ ទើបនាំហេតុនោះទៅសួរអៀវស៊ីវៗប្រាប់ថា បង្គាប់មហាឧបរាជប្រើឲ្យអ្នកចេញទៅ បើនរណាបង្អាក់ហាមឃាត់ទាំង ត្រូវតែសម្លាប់អ្នកនោះចេញទើបត្រូវ ចូស៊ិតឮដូច្នោះ ក៏ត្រឡប់ទៅធ្វើតាមបង្គាប់អៀវស៊ីវ លុះទៅដល់នាយទ្វារក៏ហាមឃាត់ ចូស៊ិតខឹងក៏ស្រែកគំហកឲ្យនាយទ្វារថា ឯងមិនអាចមកហាមឃាត់យើងជាអ្នកកាន់ព្រះតម្រាស់ ហើយក៏សម្លាប់នាយទ្វារនោះស្លាប់ ។

ចូឆូដឹងដូច្នោះក៏ចូលចិត្តថា ចូស៊ិតមានប្រាជ្ញាជាងចូភី លុះកន្លងយូរមកមានមនុស្សក្រាបទូលចូឆូថា ចូស៊ិតអាចធ្វើការដូច្នោះបាន ក៏ព្រោះអាស្រ័យគម្រិះប្រាជ្ញាអៀវស៊ីវណែពន្យល់ ចូឆូឮដូច្នោះ ក៏នឹកក្នាញ់ព្រះទ័យនឹងអៀវស៊ីវណាស់ សូម្បីទាំងចូស៊ិតនោះក៏បោះបង់ពុំសូវរាប់អាន លុះកន្លងមកទៀត ចូឆូដេញដោលសួរការពីសង្គ្រាមផ្សេងៗ ដល់ចូស៊ិតៗ

ក៏ឆ្លើយដោះសាបានគ្រប់ប្រការមិនទើសទាល់ ព្រោះអៀវស៊ីវជាប៉ាញ្ញាយទ៍ វៃណាតទ្យល់ជាដរាប ចូចូក៏រឹងរឹតតែសង្ស័យណាស់ ។

មានមួយថ្ងៃនោះ ចូភីចូលទូលចូចូជាបិតាថា ដែលចូស៊ិតដឹងកិច្ចការបានច្រើននោះ ព្រោះបានតម្រិះពីអៀវស៊ីវវៃណាតទ្យល់មកទេ ចូចូក៏រឹតតែមានកំហឹងគុំគួនក្នុងព្រះទ័យជាដរាប គិតព្យាបាទប្រុងនឹងសម្លាប់អៀវស៊ីវចេញឲ្យបាន ដល់មានឱកាសមកធ្វើការសង្គ្រាមនៅភ្នំសៀតកុកនេះ ទទួលអៀវស៊ីវធ្វើសេចក្ដីល្មើសពីព្រោះដើងមាន់ ដែលដឹងគំនិតចូចូ ក៏ខឹងដោយអាការព្យាបាទជាប់មកនោះ លុះបានហេតុប៉ុណ្ណេះហើយក៏ឲ្យសម្លាប់អៀវស៊ីវទៅ ហើយចូចូធ្វើជាខឹងនឹងសម្លាប់ហែហ៊ួទុនទៀតថាសមគប់គ្នា ។

ឯបណ្ដានាម៉ឺនខ្ញុំរាជការទាំងឡាយ ក៏ថ្វាយបង្គំសុំទោសហែហ៊ួទុន ចូចូក៏គំហកឲ្យហែហ៊ួទុនថយចេញពីទីដំនុំទៅ ហើយបង្គាប់ទាហានទាំងឡាយថា ព្រឹកស្អែកយើងនឹងលើកទ័ព ត្រឡប់ទៅវិញ លុះព្រឹកឡើងចូចូក៏លើកទ័ពចេញពីទីរូងភ្នំសៀតកុកទៅ ស្រាប់តែអ៊ុយអៀនលើកទាហានចេញមកស្ទាក់ផ្លូវពីមុខ ចូចូក៏ស្រែកថា អ្នកចូលមកនៅខាងយើងចុះ យើងនឹងឲ្យបំណាច់រង្វាន់អ្នកច្រើន ។

អ៊ុយអៀនឮដូច្នោះក៏ខឹងណាស់ ស្រែកជេរចូចូដោយពាក្យអសុរោះ ទ្រគោះផ្សេងៗ ចូចូក្ដៅណាស់ក៏ប្រើបាំងតេកចេញច្បាំង នោះទាហាន

ទាំងសងខាងក៏ចូលប្រឡុកគ្នាទៅវិញទៅមក ខណៈនោះមានបំរើចូលទៅទូលចូចូថាឥឡូវម៉ាឈៀវលើកតាមមក ទឹងបូទ់យកកងកណ្ដាល , កងក្រោយរបស់យើងទៀតហើយ ចូចូឮដូច្នោះ ក៏ហូតក្រប៊ីចេញគ្រវីហើយថា បើទាហានណាញញើតរញ្ញកថយត្រឡប់មកវិញយើងនឹងកាត់ក្បាលចេញ ទាហានទាំងអស់ក៏ចូលច្បាំងស៊ើគ្នាមិនមានកោតញញើត ។

ខណៈនោះ អ៊ុយអៀនក៏ធ្វើថយរត់ទៅក្រោយ ចូចូក៏បរពលដេញបណ្ដាយទៅប្រទះនឹងម៉ាឈៀវ ចូលប្រយុទ្ធគ្នាទៀត ឯខ្លួនចូចូជិះសេះឈរនៅលើភ្នំ មើលទាហានទាំងសងខាងច្បាំងប្រឡុកគ្នា អ៊ុយអៀនបំដាយសេះរត់មកត្រង់មុខចូចូ ហើយស្រែកថា យើងឈ្មោះអ៊ុយអៀនត្រឡប់មកនេះហើយ ក៏លើកធ្នូបាញ់សំដៅទៅ ត្រូវមាត់ចូចូបាក់ធ្មេញ ២ របូតធ្លាក់ពីលើខ្នងសេះ អ៊ុយអៀនឃើញដូច្នោះ ក៏សប្បាយចិត្តណាស់បោះធ្នូចោល កន្ត្រាក់ដាវបំបោលសេះដេញតាមដើងភ្នំទៅ បំណងនឹងចាប់យកខ្លួនចូចូសម្លាប់ឲ្យបាន ។ ខណៈនោះទទួលប៉ាំងតេក ត្រឡប់មកឃើញអ៊ុយអៀនដេញចូចូ ប៉ាំងតេកស្រែកថា អ្នកឯងកុំធ្វើអន្តរាយម្ចាស់យើង ក៏ចូលទៅតទល់ពីមុខ ហើយដេញទាហានចូលតយុទ្ធគ្នានឹង អ៊ុយ-អៀន ដោះយកចូចូរួចពីចំណោមបាន ម៉ាឈៀវ ក្រឡេកឃើញដូច្នោះក៏នាំទាហានថយទៅឈប់ ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ត)

លោក ឌ. គាម ស្រាវជ្រាវ និង រៀបរៀង

នាងផ្កាស្រេចក៏យានលីលា ស្រក់ទឹកនេត្រាហូរហាម ហើយនាងផ្សង សច្ចាអធិដ្ឋានថា សូមអស់រុក្ខទេវានៅនាព្រៃភ្នំក្រំថ្ម ជ្រៅស្រលូងរូងគុហា សូមអ្នកជួយអភិបាលព្យាបាលរក្សាឲ្យបានខ្ញុំផង លុះផ្សងសច្ចាដ៏ស្រេច ហើយ នាងក៏ខំយាត្រាចេញចាកពីគុហាកែវសុរិយកាន្ត ខំយានតាមដាន រូងទៅហោង ៗ វេលានោះ អស់ពួកទេវរុក្ខដែលស្ថិតនៅក្នុងកំឡុង គុហានៅជាយព្រៃអង្គាទាំងឡាយនោះ លុះបានស្តាប់ស័ព្ទនាងទិល-កេសរផ្ញើផ្ញោះហើយ ក៏មានចិត្តនោះមេត្តាករុណាអាណិតជ្រួល ក៏ បបួលគ្នាចូលទៅរក្សានូវស្នែងទាំងពីរខាង នូវជើងទាំង ៤ រក្សាថែជូន ជាប្រក្រតី· ទេវរុក្ខក៏សន្មតនាមក្របីនោះឲ្យឈ្មោះជាទូរភីហោង ៗ

យើងនឹងថ្លែងសម្តែងពីព្រះបាទ មហាយមយក្ស ដែលគ្រប់គ្រង-ភាពបុរីក្រុងបាតាល ត្រកាលមានមហន្តយសសក្តិខ្ពស់ប្រសើរក្រៃប្រកប នូវសៅកែវស្រីស្រីង្គារ សេនាអាមាត្យ មុខមន្ត្រីធំតូចទាំងពួង ទាំងក្រសួង អាណាប្រជាជនរាប់សែន ត្រេកអរសោមនស្សក្សេមក្សាន្តជាភិយ្យោភាព មិនមានពួកបច្ចាមិត្រមកបៀតបៀនចង្រៃយាយីសោះឡើយ ហើយស្តេចក៏ សោយរាជសម្បត្តិមកជាយូរយារមានព្រះជន្មានោះបាន ៥០.០០០ ឆ្នាំ

ហើយស្តេចក៏ទ្រង់ព្រះផ្កាពាធជិតទឹងដល់សង្វារមេណភាព ទើបត្រាស់ប្រាប់ទៅនឹងអគ្គមហេសីថា កាលព្រះរាជបិតានឹងប្រគល់រាជសម្បត្តិឲ្យបងនោះ ស្តេចបានមានព្រះបណ្តាំទុកថា កុំឲ្យខ្លួនបងដើរទៅសេពគប់គិតជាមិត្រមេត្រីនឹងទសកណ្ឋនោះឡើយ អូនអើយ ត្បិតចិត្តវាជាមនុស្សមិច្ឆាទិដ្ឋិអាក្រក់ជួជាតិអប្រិយ ចូរនាងស្តីប្រាប់ប្រដៅ កូនចៅកុំឲ្យវាទៅគប់គិតជាមិត្រភក្តិឡើយ ស្តេចផ្តាំរួចហើយក៏ទ្រង់អាពាធធ្ងន់ដរាបក្ស័យព្រះជន្មាទៅហោង ។

កាលនោះ វៃយកពណ៌ទ្វើឫងនោះ លុះព្រះបិតាស្តេចសុវណ្ណគតទៅ ក៏ឡើងសោយរាជសម្បត្តិគ្រប់គ្រងព្រះនគរ ហើយស្តេចក៏នឹកព្រួយព្រះ-ទ័យភ័យបារម្ភ រំពឹងគិតទៅឃើញថា បើមានពួកសត្រូវមកច្បាំងតាំងតដណ្តើមយកនគរ បុរីរាជស្ថាន ហើយអញក៏គ្មានឫទ្ធានុភាពសោះឡើយ ហើយគួរតែអាត្មាអញនឹងរករៀនសិល្បសាស្ត្រ នឹងព្រះអាចារ្យសុមេធតាបសឥសីនៅព្រៃហិមវន្ត ក្រុងកុម្ភណ្ឌគិតហើយក៏ទ្រង់គ្រឿងប្រដាប់សំពត់ស្តេចស្រេចហើយ ពុំលង់ឡើយក៏ទ្រង់ចរលីចាកទីមណ្ឌលស្តេចទៅគាល់ព្រះមាតា លុះអស្សុកយាត្រាមកដល់ហើយក៏ក្រាបថ្វាយបង្គំបរមមាតា ហើយក្រាបទូលថា ទូលព្រះបង្គំខ្ញុំសុំក្រាបបង្គំលា ទៅរករៀនវិជ្ជាសិល្បអាគមសំណាក់នៅ នឹងព្រះមុនីសុមេធតាបស ។

កាលនោះ រីនាងច័ន្ទប្រភាសីបានស្តាប់វាទីរាជឱរសលាទៅរៀន

សិល្បដូច្នោះ នាងក៏ត្រេកអរសោមនស្សណាស់ ហើយក៏ត្រាស់ឲ្យពរពជ បុត្រាថា អើបើកូនអ្នកទៅរៀនសិល្បវិជ្ជា ចូរអ្នកឧស្សាហ៍ខំឧហាត សង្វាតឲ្យបានសម្រេចសំបូរ្ណដូចក្តីប្រាថ្នាហោង ។

កាលនោះវិវ័យពពណ៌អសុរ ក៏លើកហត្ថាបង្គំក្រាបទទួលព្រះពរអំពី ព្រះមាតាលាថយចេញមកហើយ ពុំលង់ឡើយក៏ជ្រែកក្រឡាមហាប្រថ-ពីហោះ សំដៅទៅបានដល់មណ្ឌលព្រះអាចារ្យ ក៏ចូលទៅក្រាបនមស្ស-ការបង្គំ ព្រះសុមេធអាចារ្យធំថា ខ្ញុំព្រះករុណាមកសូមរៀនសូត្ររៀនសិល្បវិជ្ជា នឹងលោកតាឥសី ។

កាលនោះ រីឯព្រះសុមេធធិបតី បាន ជ្រាបសេចក្តីអសុរពាទីដូច្នោះ ចំពោះសែនត្រេកអរ ហើយក៏តាំងប្រៀនបង្រៀនមន្តវិជ្ជាទាំងគាថាមហា រនាំងផញ្ចាំងពេជ្រទាំងកិច្ចសន្តំគង់ស្ថិតអាពន្ធ បំបាំងបាត់មិនឲ្យឃើញ កាយ ហើយក៏បរិយាយប្រាប់ទាំងថ្នាំដាក់ក្នុងបំពង់ផ្លុំសត្វសារពើ ហើយ ក៏ប្រៀនឲ្យធ្វើទាំងពិធីពលីការ ប្រាប់កិច្ចឧបាយកលមិនសល់ត្រង់ណានូវ រឿងយុទ្ធនាទាំងឡាយ ។

កាលនោះ វិវ័យពពណ៌រៀនឫទ្ធិសាយ ខំឧហាតសង្វាតកាយរៀន វិជ្ជាការ មហាមន្តទាំងពួងដែលព្រះអាចារ្យប្រាប់ប្រៀនប្រដៅសព្វថ្ងៃ អសុរក៏ទន្ទេញសិល្បសាស្ត្រ ត្រៃវេទ ចេះចាំសព្វគ្រប់ប្រការ ទើបអង្គ ព្រះមហាឥសីសៃយ យកដៃអង្អែលបបោសខ្នងថា ចៅតាមានប្រាជ្ញា

ធ្មៀវឆ្លាតសង្វាតរៀន ជីតាទឹងប្រៀនមន្ត ១ ឲ្យចៅហៅឈ្មោះមន្តដក-ដួងវៃដួងចិត្ត មិនឲ្យបច្ចាមិត្រសត្រូវរូបណាពិឃាដប្រហារជីវិតចៅបានឡើយ ។

គ្រានោះ រីវៃយកពណ៌អសុកបានស្តាប់ពុទ្ធដីកាជីតាប្រាប់សាស័ព្ទព៌ទ ថាតាំងពីផីកងអគ្គីបំរើនពុទ្ធីនោះ ចំពោះសែនត្រេកអរកើក្រាបថ្វាយបង្គំទូលតបពុទ្ធដីកាថា ដែលលោកតាថា ទឹងតាំងពិធីដកយកដួងជីវិតនោះ ចៅមានចិត្តត្រេកអរណាស់សា តាមតែលោកតាប្រណីចៅហោង ។ ទើបព្រះមុនីបុទ្ធីឲ្យឯសោតក៏នាំវៃយកពណ៌អសុក ចេញពីសាលាអាស្រមបទទៅសំដៅដល់ទីដើមព័ងមួយធំសាខា មានស្លឹកផ្លែផ្កា ត្រសុំត្រសាយជុំជិតឥទឹតបិទបាំងតាំងសែងព្រះសុរិយា សែនក្រអូបសេគន្ធាពិដោរឈ្ងុយឈ្ងប់ដូចអប់អស់អង្គអាត្មា ក្រោមដើមរុក្ខានោះ ចំពោះពបភាបស្មើល្អល្អះស្រឡះស្រួល ហើយមានទាំងទួលដីខ្សាច់សល្អផុតដើងគិរី ទើបអង្គព្រះមុនីឥសីឃ្នាតវ៊ី កងគរអគ្គីតាមគេទពិធីការតម្រាសែស ជូចព្រះមុនីបុទ្ធីក្រេក៏ប្រាប់ទៅវៃយកពណ៌អសុកថា ចូរបាទៅស្រង់ទឹកដំរះមន្ទិលសេទោឲ្យស្រេចហើយ ក៏អ្នកស្លៀកពាក់ប្រដាប់សំពត់គ្រឿងសក់ដូតក្បាលពានាឈៀង ហើយយកម្សៅក្រអូបមកលាបថ្ពាសលាបមុខហើយ ដៃកាន់ផ្កាសំពះក្រាបព្រះអាចារ្យ អសុកក៏ចូលទៅអង្គុយតាវនាបរិកម្មទៅ ទើបព្រះឥសីសេពទិព្វមន្តប្រោះព្រំប្រោះខ្លួនអសុក ពយវេទវិជ្ជាផ្ទុំពោជា

ប្រក្រតីទាល់តែកំណត់ ១៥ រាត្រី កាលណា រីអាកាសវេហាស៍មេឃ ក៏បណ្តាលឲ្យលាន់គ្រឹកគ្រេងល្វេងល្វើយ ហើយក៏ងងឹតអត៉ួអស់ទាំងនភា-ល័យ ត្រូវត្រកងតម្រោសាយវេទព្រះមុនី រីឯគន្ធក្រុងវៃយកពណ៌អសុរពេទ្ធ រនត្រាសជ្រួមចិត្ត អសុរីបុទ្ធិក៏មិនដឹងហេតុការណ៍អ្វី កាលដួងចិត្តអសុរី នឹងចេញចាកពីខ្លួន ហើយដោយតេជៈព្រះវេទមន្តវិជ្ជា ក៏ឃើញ ជាកន្ទង់មាសហើរចេញមកពីមាត់អសុរិន្ទ្រ ហើរប្រទក្សិណវិលវង់ជុំ ៣ ជុំ បំណងចង់ទៅក្របកេសរផ្កាក៏ដែរ មានក្លិននោះពិដោរខ្ចរខ្ចាយ សាយសព្វហើយ ហើរត្រឡប់វិលមកកាន់អសុរី កាលនោះព្រះឥសីនោះ លុះឃើញសុវណ្ណកមរហើរទៅក្របកេសរផ្កាហើយ ហើរវិលមកវិញ នៅមុខអសុរ ឥសីសែនសោមនស្សត្រេក ទើបយកដៃលូកទៅចាប់យក កមរសុវណ្ណបានហើយ ក៏ប្រគល់ឲ្យទៅវៃយកពណ៌អសុរ ហើយក៏មាន វាចាថា ម្នាលវៃយកពណ៌អើយ ចៅរុំយចូរអ្នកយកដួងជីវិតរបស់នេះទៅ ទុកដោយក្តាក្នុងត្រកូដបពិត ហើយខ្លួនអសុរទៀតក៏គង់អាពន្ធផង បើមានពួក បច្ចាមិត្រមកគិតកាប់សម្លាប់នឹងអាវុធនានា ក៏មិនស្លាប់ឡើយ ។ កាល នោះ រីគន្ធវៃយកពណ៌បុទ្ធិវង្គនោះ លុះឃើញព្រះអាចារ្យហុចប្រគល់ដួងថៃ ឲ្យទៅអាត្មា អសុរក៏ទទួលយកពីដៃព្រះអាចារ្យ ហើយក៏ត្រេកអរសោ-មនស្សពេកណាស់ ទើបត្រាស់និយាយថា រីគុណព្រះអាចារ្យជាម្ចាស់ នោះធំក្រៃលែងណាស់ នឹងគណនាពុំបាន ដែលទ្រង់ព្រះរាជទានមេត្តា

ប្រោសខ្ញុំព្រះករុណា ៗ ថាហើយអសុរក៏ក្រាបថ្វាយបង្គំលាវិលទៅនគរ បាតាលភព ៗ ស្រេចៈហើយអសុរក៏សម្តែង វែកញែកប្រថពីហោះចុះ ទៅដល់ក្នុងត្រីកូដ ខាងជើងក្រោមកាលណា អសុរក៏យកដួងវែចនោះដាក់ ទុកនៅបាតគិរីត្រីកូដនោះហោង ៗ ស្រេចហើយអសុរក៏ហោះវិលទៅ សីមាភពស្ថានជាទីទីបាតាល ៗ

ទំនងជំណាលពណ៌នាពីព្រះបាទកៃកេសចេស្តា ស្តេចសោយសម្បត្តិ វត្ស្យនាជាមហាមហៃក្រលើក្រុងកៃកេសធានី មានចតុរង្គយោធានោះច្រើន ក្រាស់ក្រៃពេកពន់ទឹងគណនាពុំបានឡើយ ហើយស្តេចមានតាំងស្រីស្នំ ក្រមការ បំរើជាបរិវារគាល់ហៀវជាប្រក្រតី ហើយស្តេចមានរាជបុត្រីនោះ ឈ្មោះនាងកៃកេសី វែងទៅវស្សារាជក្សត្រីនោះបាន ១៩ ឆ្នាំគត់ ទ្រង់ ប្រកបដោយបញ្ចពិធកល្យាណី វីក្រុងក្សត្រនៃឯដទៃមកដណ្តឹងចង់បាន ស្តេចក៏មិនប្រទានឲ្យឡើយ ហើយមាតាបិតាក៏ស្រឡាញ់ពេញចិត្តដូច ដួងជីវិត ស្តេចក៏ស្ថិតគ្រប់គ្រងប្រជានុរាស្ត្រទាំងឡាយ ក៏សុខសប្បាយ ក្សេមក្សាន្ត ទូទៅទាំងស្ថានដានសីមាក្រុងក្រៃ ៗ លុះមានសម័យថ្ងៃ ១ នោះ ព្រះអង្គកៃកេសធិបតី ដល់ពេលរាត្រីយប់ហើយ ព្រះគ្រាណ ត្រើយក៏ស្តេចទ្រង់ផ្ទុំលក់ទៅបន្តិច ស្តេចក៏ទ្រង់សុបិននិមិត្តអស្ចារ្យ ឃើញ ថាព្រះច័ន្ទវៃងបាំងបាំងច័ត្រកណ្តាលអម្ពរ ដូងភាពក៏រះដេរដាស ចូល ទៅនៅក្នុងវង់ព្រះច័ន្ទពេញពាសព្រះវេហាស៍ រស្មីព្រះច័ន្ទ្រានោះ ភ្លឺថ្លា

លើសពន្លឺព្រះអាទិត្យផ្ទុះស្វាងរុងរឿងកណ្តាលអម្ពរ ពុំមានពពកមកបិទបាំងសោះឡើយ ហើយទ្រង់បរភជរថប់ភ្លឺផ្ទុះទ្វីបទាំង ៤ ស្តេចទ្រង់សុបិនតែប៉ុណ្ណោះស្រេច ក៏ស្តេចតើនចាកពីទីនៃទក្រឡា មួយរំពេចទ្វី លុះព្រះសូរ្យសែងរះចែងពីទិសបូព៌ា ស្តេចក៏យាត្រាចេញចុងព្រះរាជពេនគង់ហើយ ព្រះអង្គទ្រង់មានព្រះឱង្ការ ត្រាស់សួរទៅហោរារាជបណ្ឌិត ម្នាលរាជបុរោហិតអាចារ្យ វេលាយប់មិញនោះ អញយល់សប្តិឃើញអស្ចារ្យណាស់ ទើបស្តេចត្រាស់ពីដើមដល់ចុងចប់និមិត្ត ឲ្យបុរោហិតហោរស្តាប់ហោង ៗ

គ្រានោះ ហោរាផងបានស្តាប់ហើយ ពុំលង់ឡើយក៏លើកដៃប្រណម្យបង្គំ ក្រាបទូលទៀបព្រះបាទា ចាប់យកក្បួនតម្រាពិចារណាមើលទៅតាមទំនាយ ដឹងស្រេចក៏ថ្វាយបង្គំទូលព្រះចមពិនថា ឱព្រះសុបិននេះ សែនល្អប្រសើរណាស់ណា នឹងថាជាអពមង្គលនោះក៏ទេ រីឯអង្គព្រះច័ន្ទដែលទ្រង់បាំងឆត្រកណ្តាលវេហាស៍ ព្យាករទំនាយទាយថា នឹងមានព្រះមហាក្សត្រខត្តិយវង្សអង្គ ១ នឹងមានយសស័ក្តិធំឧត្តមក្រៃលែងលើស បណ្តាស្តេចដែលនៅក្នុងជម្ពូទ្វីបទាំងប៉ុន្មានក្តី ហើយនឹងមកទំពឹងព្រះបារមីទាំងអស់ពុំលែងឡើយ ហើយមួយទៀតដូចដួងតារាដែលរះរៀងរាយទៅចូលនៅក្នុងរង្វង់ឆត្រព្រះចន្ទ្រាទាំងអស់ គ្មានសល់ដល់មួយឡើយ ហើយមួយទៀតដែលពន្លឺភ្លឺផ្ទុះ ស្វាងរុងរឿងច្រើន

លើសពន្លឺព្រះអាទិត្យនោះ ទំនាយថា ព្រះមហាក្សត្រនោះ នឹងឲ្យត្រៃលោកទាំងបីបានក្តីសុខនិរទុក្ខភ័យជាទិវត្ត៍ ហើយក៏ព្រះអង្គនោះស្តេចនឹងបង្ក្រាបសត្រូវពួកពាលបច្ចាមិត្រក្ស័យបានទាំងអស់ហោង ម្យ៉ាងទៀតដែលសុបិនឃើញថា បើកបរាជវត្ថុព្រោងប្រះធ្លុះឡើងទាំង ៤ បាន ស្តេចនោះទំនាយថា នឹងមានបុត្តាអានុភាពជ្រាបលាន់ឮទៅទិសឆ្ងាយ សាយសព្វគ្រប់ស្ថានទាំងបីហូតទាំងស្ថានសួគ៌ស្រី ១៦ ចប់ហូតទៅទាំងបាតាលរាជស្ថាន ពុំមានអ្នកណាឯងអាចកាចក្លៀវក្លាហានតតេជដៃបានឡើយ សូមព្រះករុណាត្រើយស្តេចទ្រង់ជ្រាប ។

កាលនោះ ព្រះបាទកែកេសនោះលុះបានទ្រង់ព្រះសណ្តាប់ ពាក្យរាជហោរាព្យាករថ្វាយដូច្នោះ ចំពោះព្រះអង្គទ្រង់ឆ្ងល់ពិតាល់សង្ស័យក្នុងព្រះទ័យណាស់ ទើបត្រាស់សួរទៅសេនាបតីមន្ត្រីតូចធំទាំងពួងថា ក្រុមក្រសួងវង្សក្សត្រអង្គណា ១ ដែលបណ្តានៅក្នុងកំឡុងសកលជម្ពូទ្វីប ឃើងមានបុណ្យប្រសើរ តើអ្នកពល់គ្នាបានដឹងថា មានស្តេចណានៅបុរីរដ្ឋាឯណាខ្លះ គ្រានោះអែស់បណ្តាសេនាអាចារ្យមុខមន្ត្រីកវីរាជបុរោហិតតូចធំទាំងអស់គ្នា លុះបានស្តាប់ព្រះរាជតម្រាស់ត្រាស់សួរដូច្នោះហើយពុំលង់ឡើយ ក៏ក្រាបថ្វាយបង្គំព្រម ១ គ្នា ហើយទូលថា ព្រះវង្សពង្សពូជអម្បូរត្រកូលព្រះបាទអនោមាតាន់ ជាចមពង្ស គឺវង្សព្រះបក្កាឈ្មោះហៅថាព្រះបាទអជបាលធិបតី ស្តេចសោយរាជសម្បត្តិគ្រងបុរីក្រុងសាវ៉ី

អយុធ្យាទ្វារាវតី ព្រះអង្គនោះមានបារមីចេស្តាអានុភាព ស្តេចបង្ក្រាបប្រាប សត្រូវបានទាំង ១០ ទិសា ហើយព្រះចក្រនោះស្តេចមានព្រះខ័នកែវ សុរិយកាន្ត ដ៏មានសក្តាអានុភាពណាស់ បើស្តេចនឹងត្រាស់ប្រើឲ្យទៅកាត់ ក្បាលអ្នកណាក៏កាត់បានដូចបំណង ៗ កាលមួយនោះ ចំពោះព្រះអង្គ ទ្រង់ប្រើទៅកាត់ក្បាលអសុរកេក្រ្ត យកមកទុកដាក់ ឲ្យប្បារស្មួនធុញ្ញានជា សត្វថៃ ៗ

រីបណ្តាក្សត្រគ្រប់ក្រុងកៃលាទី ក៏ថ្វាយសុវណ្ណមាលីសួយសាអាករតាមសណ្តាប់ធ្នាប់ប្រពៃណី សព្វៗវស្សា ៗ ហើយស្តេចមានព្រះរាជ-ទេវស មួយព្រះអង្គទ្រង់នាមាជាទដ្ឋរដ្ឋកុមារ សូមព្រះករុណាទ្រង់ជ្រាប ៗ

កាលនោះ រីអង្គព្រះបាទកៃកេសវទ្ធិរដ្ឋទ្រង់អានុភាព ស្តេចបាន ជ្រាបសេចក្តីអស់ពាក្យមន្ត្រីទូលដូច្នោះហើយ ព្រះត្រាណត្រើយទ្រង់រំពឹង គិតទៅ បើអញនឹងស្ងៀមនៅដូច្នេះ ប្រហែលយូរទៅនឹងបានសេចក្តីខុស មិនខាន ដូច្នេះមានតែអង្គអញ នឹងទៅគប់គិតបង់ជាសម្ពន្ធមិត្រមេត្រី គិតហើយអង្គព្រះចក្រី ស្តេចក៏ចរលីយានទៅកាន់ល្វែងកែវមណីទីទេន ហើយក៏គង់ជិតនៃបទិត្យនឹងព្រះអគ្គមហេសី ហើយស្តេចស្តីប្រាប់ពីនិមិត្ត សុបិនទៅនឹងចមពិនមហេសីថា ឥឡូវនេះហោរាគេទំនាយ ទាយថាដូច បង់អធិប្បាយរាយរឿងសេចក្តី ឲ្យអូនស្រីស្តាប់ តើធ្លាមចំណាប់អ្នកនឹង គិតយ៉ាងណា ឥឡូវនេះចិត្តជេដ្ឋា គិតទៅឃើញព្រួយគ្រប់ប្រការ ត្បិត

យើងមានរាជធីតាស្នេហ៍សំឡាញ់តែមួយ យើងនឹងគិតលើកឲ្យទៅក្សត្រដទៃនោះ បងពិគ្រោះមើលទៅមិនត្រូវរាស្នាជាគូនឹងកូនយើងឡើយ ។ អូនអើយរីចៅរដ្ឋរដ្ឋកុមារ ជាពង្សវង្សព្រះបាទអជបាលធិបតីសិរីវង្សពង្សព្រះនារាយណ៍កាលា ស្តេចមានឫទ្ធានុភាពបារមីពេកក្រៃ រីឯនាងកែកេសីជាកូនយើងដែលនៅក្មេងផង មានរូបឆោមល្អហ្មត់ហ្មង់សមនូវលក្ខណៈ យើងនឹងលើកទៅឲ្យគេជាគូរួមរ័កតិមេ្យ នោះទើបនឹងសមជាប្តីនឹងកូនស្រីយើងហោង តើអ្នកមាសបងនឹងថាដូចម្តេចហ្ន៎ ។

កាលនោះ នាងប្រថែមហេសី បានស្តាប់ជាក់ព្រះឱង្ការរាជស្វាមីស្តីប្រាប់ថាដូច្នោះហើយ ពុំលង់ឡើយនាង ក៏លើកហត្ថាទ្វីយទូលតបព្រះឱង្ការថា ដែលព្រះអង្គទ្រង់គិតនឹងលើកកូនសំឡាញ់ ដែលយកទៅថ្វាយជាអគ្គរេតវិសេដ្ឋវិសាល នៃវង្សព្រះបាទអជបាលធិបតី ឯនគរទ្វារាវតីសិរីអយុធ្យាធានី ខ្ញុំម្ចាស់ក៏យល់ឃើញសមនឹងយសសក្តិសុរិយវង្សពង្សស្មើគ្នាប្រៀបគណនាដូចដួងព្រះសុរិយ៍និងដួងព្រះចន្ទ្រា នឹងបានពន្លឺកើតនាមាឈ្មោះពីរោះខ្ពស់តទៅ នៅក្នុងភពត្រៃជាលោកាផែនដីនឹងសួគ៌ាគ្រប់ពាសស្ថានទេព ។

កាលនោះ រីអង្គមហាក្សត្រថ្វៃកេស ស្តេចត្រាស់ប្រឹក្សានឹងមហេសីសេចក្តីព្រមព្រៀងត្រូវព្រះទ័យហើយ អង្គព្រះត្រាណត្រើយ ក៏ទ្រង់សោមនស្សណាស់ ស្តេចក៏យាងយាសយាត្រាវិលមកគង់ក្នុងព្រះរាជរោងជ័យ

លុះដល់ហើយនៃ ស្ដេចក៏មានព្រះឱង្ការថា នៃសេនា អាមាត្យមុខមន្ត្រីជាធំចូលអ្នកគិតរៀបចំតែងព្រះរាជសារទៅ ឯនគរពារីអយុធ្យក ត្បិតអញនឹងថ្វាយអគ្គរេករាជធីតា ទៅព្រះបាទអជបាលធិបតី ហើយឯងចាត់តាំងមន្ត្រីសេនាយោធាចតុរង្គ ដង្ហែអគ្គធីតា នឹងរាជសារយកទៅថ្វាយ ។

គ្រានោះ រីមន្ត្រីជានាយធំ ក៏ក្រាបថ្វាយបង្គំលាថយចេញទៅតាំងចាត់ចែងតែងសារៈឲ្យក្រុមអាលក្សណ៍ ធ្វើរាជសារស្រេចហើយក៏រៀបចាត់សេនាទាហាន សុទ្ធសឹងតែមានប្រាជ្ញាអធ្យាស្រ័យស្រួល ហើយចាត់តាំងស្រីស្នំបំរើចាស់ទុំអករយាយជាគ្រប់ស្រេច ក៏រង់ចាំស្ដេចមានព្រះឱង្ការ ។

កាលនោះ រីនាងប្រពៃផាមាតានាងឧបរាជធីតា ហើយបបោសអង្អែលអស់អង្គទ្រង់មានព្រះវាចាថា ម្នាលរាជធីតាបុត្រីសំឡាញ់ពេញចិត្តម្ដាយ កូនអើយឥឡូវនេះអ្នកនឹងចាកពីទ្រូងម្ដាយទៅនៅឯនគរអយុធ្យាធានី នៅជាខ្ញុំក្រោមល្អងធូលីព្រះហរិរក្សចក្រពង្ស នោះចូរកូននាងស្ងួនអង្គផ្ចង់ចិត្តខំបំរើគាល់ហ្វៅព្រះចក្រា ឲ្យឧស្សាហ៍ព្យាយាមផ្ញើអាយុជីវិតនឹងព្រះទ្រង់ឫទ្ធិតទៅ ចូរស្រីពៅនាងកុំមានចិត្តគិតឥច្ឆាព្យាបាទនិន្ទា ហើយកូនយកចិត្តទុកដាក់នឹងកិច្ចរាជការទាំងពួង តាមក្រសួងតូចធំទាំងឡាយ គ្រាន់ម្ដាយនឹងបានជាទីពឹងពំនឹងលើអ្នកទៅមុខនាយហោង ។

(នៅមានត)

# ឯកសារទំនៀមទម្លាប់ខ្មែរ

## រឿងស្រះយក្សឡោម

(ខេត្តរតនគិរី)

នៅក្នុងដំបន់ឡាបានសៀក ឃុំឡាបាន ស្រុកលំផាត់ ខេត្តរតនគិរី មានស្រះមួយធំ ទំនងជាអាងទឹកបុរាណ ដែលសេសសល់មកពីលក្ខណៈភូមិសាស្ត្រ ព្រោះស្រះនេះនៅចំចន្លោះជ្រលងភ្នំ ហើយមានសណ្ឋានមូលដូចបាតខ្ទះ ។

អ្នកដំណើរណាដែលបានទៅដល់រតនគិរី គេពុំអាចភ្លេចនឹងទៅលំហែ ឬ ទៅទស្សនាស្រះយក្សឡោមឡើយ សមបើសព្វថ្ងៃនេះ នៅឡាបាន-សៀកមានការរៀបចំភូមិស្រុកល្អផង ដូចជាមានផ្សារផ្សោ មានវត្តអារាម មានភូមិនិវេសន៍ស្ថាន មានចំការកៅស៊ូជ្ល ។ល។ ក៏តែងតែបានជាទីជំនុំចំណោមធំដុំមួយឡើង ។

កាលបើទៅដល់ "ស្រះយក្សឡោម" គេតែងនឹករកដើមហេតុនៃឈ្មោះចំឡែកនេះភ្លាម ។ ការឆ្ងល់នេះ ក៏នាំឲ្យសាកសួររកហេតុដើមដែលមាននៅជាប់នឹងបែបទិតានរបស់អ្នកស្រុក ជារឿងព្រេងប្លែក ៗ គ្នា ដែលយើងលើកមកអធិប្បាយដូចតទៅនេះ ៖

ពាក្យថា «យក្ខឡោម» គេអាចយល់បានដោយងាយថា: «យក្ខរព័ទ្ធ» តាមពាក្យបរម្បរាតៗគ្នាមក មានរឿងនិទានថា:

តាំងពីយូរលង់មកហើយ មានស្ដេចក្រុងយក្សមួយ មានឫទ្ធិអំណាចខ្លាំងពូកែណាស់ មានព្រះរាជបុត្រីមួយ ស្អាតលើសស្រីនានា, ទាំងសក់ ទាំងរូបកាយរបស់នាងតែងមានក្លិនក្រអូបជានិច្ចរៀងរាល់ថ្ងៃ ទើបយក្សជាបិតាឲ្យនាមបុត្រីនោះថា : «នាងសក់ក្រអូប» ។ លុះដល់នាងមានវ័យគ្រប់គ្រាន់កាលណា នាងក្បត់ចិត្តពីបិតា ទៅលបលួចស្នេហាប្រតិព័ទ្ធជាមួយនឹងមនុស្សម្នាក់ ដែលមានឫទ្ធិអំណាចខ្លាំងពូកែណាស់ដែរ មិនឲ្យបិតាដឹង ។ ថ្ងៃក្រោយមក ទាំងពីរប្រាណដោយភ័យខ្លាចស្ដេចយក្សជាបិតាដឹង ក៏នាំគ្នារត់ទៅនៅក្នុងព្រៃមួយ ។

ក្រោយមកស្ដេចក្រុងយក្ស ដឹងរឿងរ៉ាវនេះ ក៏ផ្អើលគោឡោស្រែកឡូឡា កេណ្ឌពលយក្សជាបរិវារហោះហើរតាមរកកូនសំឡាញ់ខ្លួន ដល់មកត្រង់កន្លែងព្រៃស្ដុកនេះក៏មានសេចក្ដីសង្ស័យថា ប្រហែលជាបុត្រីខ្លួននៅទីនេះ ទើបបញ្ជាឲ្យយក្ខជាកូនចៅ យាមល្បាតព័ទ្ធហ៊ុមព្រៃនោះយ៉ាងមាំ ហើយឲ្យយក្ស ១ ក្រុមទៀត ដកព្រៃព្រឹក្សាគ្រវែងចោល ហើយនាំគ្នាជីកកកាយរកនាង តែទោះបីជីកយ៉ាងណាក៏គេពុំឃើញ ទើបស្ដេចក្រុងយក្ស នាំបរិវារត្រឡប់ទៅនគរដើមវិញ ។

អាស្រ័យហេតុពួកយក្ស កកាយរកនាងសក់ក្រអូបនេះ ទើបមាន

នៅសល់ជាស្រះមួយនៅរតនគិរី ហៅថា «ស្រះយក្ខឡោម» រហូតដល់សព្វថ្ងៃ ។

ស្រះយក្ខឡោម ជាស្រះមួយមានទឹកថ្លាឈ្វេងដែលមានជម្រៅជាង ៧០ម. នារដូវប្រាំង, មានបណ្ដោយ និងទទឹងប្រហែល ១គ.ម. ៤ ជ្រុងស្មើ ។ នៅមាត់ស្រះមានដើមហាកប្រេង មាក់ប្រាង សារ៉ៅ សីរមាន់ គៀវដុះនៅពាសពេញក្បែរមាត់ស្រះ ជាពិសេសមានដើមកាំង ដែលមានផ្កាយោនយោន សំយុងចុះទៅក្នុងស្រះគួរឲ្យទស្សនា ។ នៅជុំវិញស្រះនេះ កងខេមរភូមិន្ទយើង ទើបនឹងបានស្ថាបនាផ្លូវថ្នល់ដីវិចិត្រ បើកបររថយន្តបានដោយស្រួល ។ មានព្រះរាជដំណាក់សម្រាប់ព្រះរាជាស្ដេចយាងទៅក្រសាលម្ដងៗ, និងមានភោជនីយដ្ឋានតូចៗ សម្រាប់ទទួលភ្ញៀវទៀតផង ។ សព្វថ្ងៃកងខេមរភូមិន្ទបានចាត់ចែងស្ថាបនាដំណាក់ថ្មីមួយទៀតពីបេតុង គឺចាប់ស្ថាបនាក្នុងឆ្នាំ ១៩៦៤ ។ នៅក្នុងស្រះមានមច្ឆាជាតិតូចធំហែលតាំងហ្វូងៗ ។ លោកអ្នកទៅទស្សនាអាចដើរព័ទ្ធជុំវិញស្រះបានដោយមានផ្លូវថ្នល់វង់ជុំវិញ[១] ។

តាមសេចក្ដីទំនាយមួយបែបទៀត មានន័យប្រលិះគ្នានេះដែរ គឺថាៈ- មានទ័ពយក្សដេញតាមវាយនាងបុត្រីយក្សដូចរឿងខាងលើដែរ ប៉ុន្តែខាងចុងថា កាលបើទ័ពយក្សឡោមព័ទ្ធជុំវិញភ្នំដែលនាងនេះទៅពួនជ្រក

---

១ – តាមឯកសារទំនៀមទម្លាប់លេខ ៦៣–០១០ រៀបរៀងដោយលោក ហ៊ុន-សារី ។

នោះហើយ នាងក៏យល់ថាគ្មានផ្លូវណាឲ្យគេចខ្លួនរួច ទើបនាងអធិដ្ឋានសុំឲ្យនាងលិចបាត់ទៅក្នុងដី ពេលនោះព្រះធរណីក៏ស្រូបនាំទាំងនាងស្រីនោះទៅផង ។ ត្រង់កន្លែងព្រះធរណីស្រូបនេះហើយ ដែលក្លាយទៅជាស្រះទឹក ដែលហៅថាយក្ខឡោម ។

តាមរឿងដំណាលមួយទៀត, មានសេចក្ដីផ្សេងពីនេះច្រើន ទំនងជារឿងពិតរបស់ភូមិស្រុកផង មានសេចក្ដីថា ៖- ពាក្យ «យាក់ឡោម» ត្រូវសរសេរដូច្នេះទៅវិញ, ព្រោះថាមកពីដើមហេតុពាក្យ យាក់ ក្លាយមកពី «យ៉ាន់» ភាសាខ្មែរបុរាណ ប្រែថា មេ នាយ នាយក ឯ ឡោម ជាឈ្មោះមនុស្ស ដូច្នេះបានសេចក្ដីថា មាននាយក្រុមម្នាក់ឈ្មោះឡោម ជាអ្នកត្រួតត្រានៅភូមិភាគខាងជួរភ្នំនោះ ម្ល៉ោះហើយអ្នកផង ក៏សន្មតហៅឈ្មោះទឹកកន្លែងនោះឯង តាមនាម និងងារសក្ដិ អ្នកត្រួតត្រានោះទៅ ។

ឯស្ថានភាពកន្លែង ដែលប្រាកដតាមការសង្កេតទៅវិញ អ្នកស្រាវជ្រាវយល់ថា ទីស្រះនេះឯង ជារន្ធភ្នំភ្លើងកាលពីសម័យបុរាណ ហើយផុតរលត់ទៅនៅសល់តែស្នាមជាន ហេតុនេះ បានជាមានស្រះនោះជ្រៅដល់ទៅជម្រៅ ៧០-៨០ម៉ែត្រ ហើយរាងវង់មាត់មូលដូចថាសព័ទ្ធជុំវិញសុទ្ធតែភ្នំ ហើយដែលសព្វថ្ងៃ ទៅជារមណីយដ្ឋានមួយ យ៉ាងប្រសើរសំរាប់អ្នកទៅទស្សនាទីដំបន់នោះ ។

# ឯកសារ សាស្ត្រាស៊ឹករិតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

**បំណងដើម** «សាស្ត្រាជិនវង្ស»

**អ្នកនិពន្ធ** ព្រះអរិយគាម៉ទី «ហ៊ុន» រាជាគណៈ សម័យក្រុងឧដុង្គមានជ័យ

**កាលបរិច្ឆេទ** ឆ្នាំរោង អដ្ឋស័ក ព.ស ២៣៩៩ ម.ស. ១៧៧០[១]

ច.ស. ១២១៨ (គ.ស. ១៨៥៦)?

**របៀបនិពន្ធ** ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-ភុជង្គលីលា)

**ប្រភពរឿង** ចលនារឿងនិងសកម្មភាព របស់តួអង្គ ស្របតាមចលនា អក្សរសាស្ត្រ ព្រាហ្មណ៍និយម ប៉ុន្តែប្រហែលជាកវី ចង់រចនា រឿង ឲ្យទៅជារឿងជាតក ចលនាពុទ្ធនិយម បានជាទុកដាក់តួឯក ជាតួអង្គពោធិសត្វ ហើយបញ្ចប់រឿង ដោយការសេជាតិ ៗ

**លក្ខណៈឯកសារ** សាស្ត្រាស៊ឹករឹត មាន ១១ ខ្សែ ចប់ក៏មាន មានដល់ ១៩ ខ្សែ ទើបចប់ក៏មាន ៗ គម្ពីរមាន ១១ ខ្សែ លេខសាស្ត្រា ៤៦០ គម្ពីរមាន ១៩ ខ្សែ ទើបចប់ លេខសាស្ត្រា ៤៦១ ៗ

---

១ សករាជទាំង៣នេះ ហាក់ដូចមិនទាន់ចុះសម្រុងគ្នាទេ សូមជូនអ្នកសិក្សា ស្រាវជ្រាវពិនិត្យថែមទៀតផងចុះ ។ ការបញ្ជាក់នេះ តាមសេចក្ដីកប់រៀប ក្នុងអត្ថបទដើម ដូចបានចម្លងទុក ក្នុងអត្ថបទផ្ដើមស្រាប់ ។

ចំពោះគម្ពីរដែលមាន ១៩ ខ្សែ ចែកជា ២ គម្ពីរ គម្ពីរទី១មាន ៩ ខ្សែ គម្ពីរទី២ មាន ១០ ខ្សែ គឺខ្សែទី១ មាន ៦៦ សទ្ទិក ខ្សែទី២ មាន ៨៨ សទ្ទិក ខ្សែទី៣ មាន ៧២ សទ្ទិក ខ្សែទី៤ មាន ៨០ សទ្ទិក ខ្សែទី ៥ មាន ៨២ សទ្ទិក ខ្សែទី ៦ មាន ៩៦ សទ្ទិក ខ្សែទី៧ មាន ៦៩ សទ្ទិក ខ្សែទី៨ មាន ៦៩ សទ្ទិក ខ្សែទី ៩ មាន ៦៦ សទ្ទិក ខ្សែទី១០ មាន ៩៨ សទ្ទិក ខ្សែទី ១១ មាន ៥០ សទ្ទិក ខ្សែទី១២ មាន ៣៥ សទ្ទិក ខ្សែទី ១៣ មាន ៨៦ សទ្ទិក ខ្សែទី ១៤ មាន ៤៧ សទ្ទិក ខ្សែទី១៥ មាន ៥០ សទ្ទិក ខ្សែទី១៦ មាន ៥៥ សទ្ទិក ខ្សែទី ១៧ មាន ៥០ សទ្ទិក ខ្សែទី១៨ មាន ៧៨ សទ្ទិក ខ្សែទី១៩ មាន ៨៨ សទ្ទិក ។ បូករួមសទ្ទិកស៊ីករតែទាំងអស់ ត្រូវជា ១២៩៤ សទ្ទិក ។

គប្បីយល់ថា មហាកំណាព្យរឿងជិនវង្សនេះ ជារឿងវែងបំផុត ក្នុងចំណោមមហាកាព្យ ដែលកើតឡើង ដោយស្នាដៃនកវីតែ ១ រូប គឺព្រះអរិយគាម៉ទី(ហ៊ីង)(១) នាសម័យក្រុងឧដុង្គ ។

អត្ថបទផ្ដើម បទកាកថ្មែងកេះ ឆ្នាំពេងកាលនោះ អដ្ឋស័កសាសនា

សកកពដបពិត្រ សម្ដេចព្រះមហា– លោកនាថសាស្តា

១ នាមរបស់កវីនេះ មានច្បាប់បោះពុម្ពផ្សាយខ្លះដាក់ថា “ភឹង” ខ្លះដាក់ថា “ហ៊ីង” ប៉ុន្តែច្បាប់សាស្ត្រាស្លឹករឹត លេខ ៥៦១ ដាក់ថា “អ្នកភិក្ខុ ហ៊ីង” ងារជាព្រះអរិយគាម៉ទី ។

ថ្ងៃយើងនេះក្តី ។ ទើបបានពីរពាន់ បីរយគ្រប់គ្រាន់ វស្សាទិន

ទៅ សិបប្រាំបួនផង មហាសករាជក្តី . . (១) ឆ្នាំសោតកទ្ទិន ៗ

មួយពាន់ប្រាំបី(២) រយចិតសិបទ្វី ខែប្រាំបួនផង ទើបឯព្រះ

ពុទ្ធ– សករាជកន្ទង មួយពាន់ឆ្នាំហោង ពីររយប្រាំបី ។

ផណ្តប់វស្សា គ្រានោះរាជមហា- ក្សត្រាពិសីហ រិក្សព្រមា

ឥស្សរាធិបតី បមរោបុរី ឥន្ទបត្តរដ្ឋា . . . .

។ល។
. . . . . . . . . . .

អត្ថបទបញ្ចប់ សុវណ្ណវង្សា ជាព្រះបិតា ជនវង្សទេវបតី អន្ទោលជាតិមក

យោនយកជាតិ ជាព្រះបាទស្រី សុទ្ធោទនរាជា ។ នាងជិន-

បុប្ផា ជាព្រះមាតា ជនវង្សសម្ភារ អន្ទោលជាតិមក យោនយក

ជាតិជា សិរីមាយា ពុទ្ធមាតាថ្លៃ ។ . . . .

។ល។
. . . . . . . . . . .

ទ្រង់ត្រាស់ទេសនា ប្រោសអស់នោះណា បានលុះអស់ផង បាន

ចូលនិព្វាន ទៅអស់ហើយហោង នេះគឺទំនង ដំណើរសេចក្ដី ។

---

១ ត្រង់ចន្លោះចុចពងត្រី គឺបាត់ពាក្យកាព្យ ១ ឃ្លា ប្រហែលអ្នកចារចម្លង រំលងចោលដោយអចេតនាទេដឹង? ។ ២ តាមន័យនៃអត្ថបទនេះវា កាលណោះ មហាសករាជកន្លងទៅបាន ១៩៧០ និង ៩ ខែ ប៉ុណ្ណោះ ។ កាលបរិច្ឆេទនេះ មិនចុះសម្រុងនឹងពុទ្ធសករាជទេ ដូច្នេះ ពាក្យកាព្យនេះគួរកែជា "មួយពាន់ប្រាំពីរ– រយចិតសិបទ្វី . . . ." ។ ដូច្នេះវិញ ទើបសមជាង "មួយពាន់ប្រាំបី" . . . . . . ។ សូមជូនអ្នកសិក្សា ពិនិត្យស្រាវជ្រាវតទៅទៀតផងចុះ ។

ថែងចប់ពាក្យ ពេចន៍អក់ប្រាយ កែម្ទេះឯងនៃ ដំណើរអំពី
ព្រះសាន់បារមី ពង្រួមស្រដី កែម្ទេះឯងហោង ។

—X—

**បំណងជើង** សាស្ត្រា «ចន្ទលីវង្ស»(១)

**អ្នកនិពន្ធ** ភិក្ខុបណ្ឌិត «ខៀវ»

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទទេ ។

**របៀបនិពន្ធ** ពាក្យកាព្យ (បទកាកគតិ·ពំនោល·ព្រហ្មគីត·កុជង្គលីលា)

**ប្រភពរឿង** បញ្ញាសជាតក ឬហាសិបជាតក ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត មាន ៥ ខ្សែ ចប់ដុំជាតក់ បណ្ណាល័យពុទ្ធសាសនាបណ្ឌិត្យ មានឯកសារនេះ ១ ចប់ ចុះលេខសាស្ត្រា ៦៧៣ ។

**អត្ថបទផ្ដើម** នេះបទកាកគតិ ។ ខ្ញុំសូមបង្គំ លុតលើកកំបង់ ព្រះមកុដ នោមឆាយ ព្រះអង្គបានត្រាស់ ប្រោសសត្វសព្វសាយ ដាក់ដល់សួគ៌ាឆាយ បាននិព្វានពិត ។ . . . .

១ សាស្ត្រាចន្ទលីវង្សនេះ គ្មានបញ្ជាក់កាលបរិច្ឆេទក្នុងអត្ថបទទេ មានតែកាលបរិច្ឆេទរបស់អ្នកចារចម្លងថា បានចារចប់ នៅថ្ងៃព្រហស្បតិ៍ ខែផល្គុន ឆ្នាំរោង ឆស័ក សម្រេចស័ក ពេលម៉ោងប្រាំបី ប្រាំបួន សំបុត្រ ។ ប៉ុន្តែសំនួនវោហារ នាំឲ្យស្មានថា ប្រហែលជាងចុងសតវត្សរ៍ទី ១៩ ។

បណ្ឌិតទៀវខ្ញុំ ឧស្សាហ៍ចិត្ត រំពឹះភាសា ល្បងលងកាព្យ

កិច្ច ដោយល្បិចប្រាជ្ញា សង្ហាតឧស្សាហ៍ គសាសនាព្រះ ។

សូមសុខសួស្តី វិទ្ធីជោគជ័យ គេជោគបះ ជៀងជួយជ្រោមជ្រែង

ខ្ញុំតែងរៀងព្រះ ខាតខុសលើសខ្វះ បំពេញឲ្យផង ។ . . .

. . . . . . . . . . . ។ល។

អគ្គបទបញ្ចប់ ហៃអស់ភិក្ខុផង គួររៀនចាំចង ព្រះធម៌ថ្លាថ្លៃ ភិក្ខុ

ផងបង្គំ ប្រណម្យលើកដៃ ស្តាប់សេធម៌ថ្លៃ បន្ទូលទេសនា ។

លង់លុះចប់ស្រេច ហើយព្រះអង្គស្តេច គោចរយាត្រា ចេញពី

ព្រះធម្ម សភាសាលា ខ្សែប្រាំសាស្ត្រា ចន្ទលីផ្សែនេះ ។

ភិក្ខុខ្ញុំគិតតែង រំពឹងគិតល្បែង ភាសារំពឹះ សេចក្តីខ្សែប្រាំ

ដុំជាតក៍ទុកស្មេះ បរិបូណ៌ប៉ុណ្ណោះ សូរេចម៉េះហោង ។

—X—

បំណងជើង "សាស្ត្រាកិនសុវណ្ណា"

អ្នកនិពន្ធ កវីនាម "ចន្ទ"

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអគ្គបទ ។

របៀបនិពន្ធ៍ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជង្គលីលា)

ប្រភពរឿង ហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្ទឹករឹត មាន ៦ ខ្សែ ចប់ផុំផ.តក់ ។ នៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មានឯកសារនេះ ២ គម្ពីរ លេខសាស្ត្រា ៦៧៤ និង ៦៣៦ ។ ក្នុងនេះ បានពិនិត្យតែគម្ពីរ លេខសាស្ត្រា ៦៧៤ ។

នេះបទកាកគតិ ។ ទើបទសករកំ- បង់បត់បង្គំ ដាក់ដល់សិសារ ទៀងទៅព្រះស្រី ត្រៃកតកគរ ព្រះអង្គជាតិជា កំពូលលោកផង ។ ព្រះត្រោងរស្មី ប្រាំមួយពណ៌ពី ព្រះអង្គកន្ទង់ ព្រះបាទលាយលក្ខណ៍ កងចក្រជួបផង ហេតុព្រះជាច្បង លើសលើកពត្រៃ ។ . . . . . .

. . . . . . . . ។ល។

អត្ថបទបញ្ចប់ ព្រះគិនសុវណ្ណ ប្រសើរសោភ័ណ លើសលើលោក គឺអញ្ញតថា- គតជាពុទ្ធ គ្រូគ្រប់អស់ឯ ទេវតាមនុស្សផង ។

នេះគឺនិបាត ហៅហាសិបជាតក៍ ប្រសើរកន្ទង់ ចទ្ទុៈនាមៈ អហំចែងចង អនុជស្នេហ៍ស្នង អាចលើកកាព្យា ។

—X—

បំណងជើង "សាស្ត្រាព្រះស្វ៉ាំត"

អ្នកនិពន្ធ បណ្ឌិត «កោរ» ។

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទទេ(១) ។

**របៀបនិពន្ធ** ពាក្យកាព្យ(បទកាកគតិ-ពំនោល-ព្រហ្មគីត-កុដដ្ឋលីលា)

**ប្រភពរឿង** ហាស្យជាតក ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹតមាន៥ខ្សែ ចប់ជុំជាតក ។ នៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មានឯកសារនេះ១ ចប់ លេខសាស្ត្រា ៦៧៩ ។

**អត្ថបទដើម** បទព្រហ្ម ។ ខ្ញុំនុនអង្គអក- អាចរិទ្ធិលុតលើកលើ សិរសើ
សូមសរសើរ ព្រះសម្មាសម្ពុទ្ធស្ស ។ ព្រះអង្គឯកឥស្សរ ជាកំ-
ពូលលោកនាថច្បាស់ មាកបាបបីបាស បរិបូណ៌បានបាក់បែប
បប ។ ញែកកន៍ពាញ់ពាល ព្រះសម្ភារខ្ជាន៍ខ្ជាប់ខ្ជួប ប្រែប្រឹង
ប្រាសប្រាណប្រែប ល៖លែងលាក់លុះត្រៃសរណ៍ ។ . .
អហំគោនាមា ចិន្ដ្តាអង្គអំពល់ បំណរទឹងសល់រល់ ត្បិត
សង្សារគតន្ត្រ ។ ទើបរិះរៀសសំដែង ចាយចាប៉ែងសាង៍សូមពរ
សរសើរព្រះគុណ កាលកន្ទង៍ជាជាគោ ។ នៅជាពោធិសត្វ
បុរសោត្ថថ្ងៃទុត្តមោ បវរត្ថអគ្គោ ឯកឥស្សរគូមិកតត្រៃ ។
. . . . . . . ។ល។

**អត្ថបទបញ្ចប់** ហៃជនទាំងឡាយ ចូរចាំនិយាយ ដំណាលព្រះសុគត

---

១ ប្រហែលជាបាននិពន្ធឡើង នៅពាក់កណ្ដាលខាងដើម នៃសតវត្សរ៍ទី ១៩ ទេដឹង ? ។

ដោយកម្មពាក់ព័ន្ធ ខាំងខណ្ឌនិបាត ហៅហារយជាតក៍ កន្លង
ទៅហើយ ៗ នេះហៅវេរា កំណើតនៅនា វដ្តសង្សារហើយ
ក្រណាយល់ក្រណាប្រាស និពសឥតត្រើយ ទល់ទុក្ខឥតល្ហើយ
ឥតពុំនាក់នៃ ៗ លុះផ្តាច់កិលេស ពតទោសនិរទេស ទុះទឹង
និរភ័យ ទុក្ខទោសនោះបាន ក្រេមក្សាន្តប្រពៃ ហៃជន
សព្វថ្ងៃ គួរគិតអនិច្ចា ៗ លុះសាងកុសល សង្វាតផ.ផល
នាទាំអាត្មា ឲ្យបានរដោះ រង្គោះវេរា ទុក្ខទោសភយា ទូវ
ភ័យភិតផង ៗ

រីអាថ៌បរិយាយ និទានអក្រប្រាយ អស់អាថ៌កន្លង ដំណើរ
ផុំជាតក៍ ព្រះសូរ៉ាតច្បាស់ច្បង បរិបូណ៌កន្លង និដ្ឋិតោចែងចប់ ៗ

—X—

បំណាំងដើង "សាស្រ្តា សុវណ្ណក្តាមស" (១)

អ្នកនិពន្ធ រកពុំទាន់ឃើញ ៗ

របៀបនិពន្ធ៍ ពាក្យកាព្យ (មានបទពាក្យ ៧ និងបទកាកគតិ-ពំនោល-
ព្រហ្មគីត-កុដង្គលីលា) ៗ

---

១ រឿងនេះ បំណងដើងសាស្ត្រាដាក់ថា "សាស្ត្រាក្តាមស" ឬ "សាស្ត្រាសុវណ្ណក្តាមស" មានច្បាប់ខ្លះទៀតថា "សាស្ត្រាសុវណ្ណកិន្នរ" ដូច្នេះក៏មាន · បំពោះច្បាប់ដែលយកមកពិនិត្យនេះ បារបម្លងដោយសាមណេរ យស់ បួសនៅវត្តពោធិលង្កា ខេត្តសៀមរាប កាលពីឆ្នាំឆ្លូវ បញ្ចស័ក ព.ស. ២៤៥៦ ។

ប្រភពរឿង រឿងព្រេងបុកណា?

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៥ ខ្សែ ចប់ ។ ឯកសារនេះ នៅ
បណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មាន ១ ចប់ លេខសាស្ត្រា
៦៨០ ។ ឯកសារចាស់ពេក មានអាយុជាង ៥០ ឆ្នាំហើយ ។

អត្ថបទផ្ដើម ។ ពាក្យ ៧ ។ ទូនអគ្គបង្គំអភិវាទ ព្រះពុទ្ធបាទនិងព្រះធម៌ថ្លៃ
ទោះទាំងឥន្ទព្រហ្មតេជៈត្រៃ ទេពទិសប្រាំបីសូមអត់ទោស ។
និយាយរឿងរ៉ាវតាមដើមទង តាមពីទំនងចាំនិទាន ទោះខុស
លើសលស់សូមសន្ដាន សូមទ្រង់ប្រោសប្រោណខ្ញុំករុណា ។
នេះនឹងថាថ្ងៃនិស័យដែនចង តាមដោយទំនងដំណើរថា កាល
ណោះស្ដេចមួយព្រះអង្គណា សោយរាជ្យនៅនាចម្ប៉ាកបាន ។

. . . . . . . . ។ល។

អត្ថបទបញ្ចប់ កាលណោះឯអង្គព្រះសុវណ្ណ កិន្នរសោកណាសោយរាជ្យ
ខ្ញុំ សម្បូរក្សេមក្សាន្តពស្ដ្រឥតបី .. ស្ដេចរាយឯកនៃសឹងបុះចូល ។
សឹងនាំដង្វាយអស់សួយរ ទ្រព្យថ្លៃប្រពៃសឹងមិត្តមូល ·មាស
ប្រាក់កែវកងពិទូរ្យសុ- រ្យកាន្តកបបង្ហូរកែវសព្វថ្ងៃ ។ . . .
សេចក្ដីទាំងនេះយើងជួបចប់ ជួបជុំសព្វគ្រប់ស្រេចហើយណា
មិនមានសល់ខានទំនេរណា សូរេចនិជ្ជិតាថែងចប់ហោង ។

—X—

បំណងជើង "សាស្ត្រាឡង់សង្ខ"

អ្នកនិពន្ធ កវីម្នាក់ បាននិពន្ធ ប្រហែលក្នុងរជ្ជកាល ព្រះបាទជ័យ-ជេដ្ឋា ។

កាលបរិច្ឆេទ ថ្ងៃព្រហស្បតិ៍ ៨ រោច ខែពិសាខ ឆ្នាំរកា ម.ស. ១៦៥១ (គ.ស. ១៧២៩) ។

របៀបនិពន្ធ៍ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-ភុជង្គលីលា)

ប្រភពរឿង រឿងជាតក ?

លក្ខណៈឯកសារ សាស្ត្រស្លឹករឹត មាន ៨ ខ្សែប់ ។

នៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មានបីគម្ពីរ លេខសាស្ត្រា ៥៨៣-៥៨៤-៥៨៥ ។

អត្ថបទផ្ដើម នេះបទព្រហ្មគីត ។ សុភមស្តុសោ តិត្ថិយោ មង្គលេ ជយាតិរេកេ ឯកឆបញ្ចក់[១] ។ ស័កក្កុដៈ នក្សត្រពៃសាខ អដ្ឋរោជស់ គរុពារសុវម្មា ។ . . .

(បទកាក) ។ ស្រេចស្ដេចត្រកាល ត្រាស់ឲ្យអាចារ្យ ចង ជាកាព្យ កាលពោធិសត្វ ឧប្បត្តិក្នុងនា ព្រះឧទរ មាតាវរ ។

. . . . . . . ។ ល ។

---

១ នេះជាពាក្យបញ្ជាក់ កាលបរិច្ឆេទរបស់កវី ផ្ទួចសេចក្ដីបកប្រែ ត្រង់បន្ទាត់បញ្ជាក់កាលបរិច្ឆេទរបស់ខ្ញុំ ។

អត្ថបទបញ្ចប់ និទាននេះនៃ អាចអធ្យាស្រ័យ ស្រែកស្រាយស្រេច ស្រាប់ ដោយពុទ្ធឱស្ឋ ទេសនាប្រាយប្រាប់ ទូន្មានសណ្តាប់ សំដែងថៃងចប់ ។ ទោះអ្នកណាស្តាប់ នោះគ្រេកគ្រងគ្រាប់ សេធម៌គោរព អ្នកនោះនឹងបាន ក្សេមក្សាន្តសួស្តីសព្វ លោ-កិយគ្រាន់គ្រប់ ដល់បរលោកណា ។ ទោះពាក្យពុំពី- រោះសារសេចក្តី កិច្ចកលកាព្យ សូមអ្នកណាមាន ញាណ-ញេយ្យថ្លៃថ្លា ជ្រោមជ្រែង . . . បរិបូណ៌បុណ្យហោង ។

—X—

បំណងដើង "សាស្ត្រាវិមានចន្ទ"

អ្នកនិពន្ធ កវីឈ្មោះ យ៉ែម(១) ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជង្គលីលា)

ប្រភពរឿង បញ្ញាសជាតក ឬបាសិបជាតក៍ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មាន ៨ ខ្សែ ចប់ជុំជាតក៍ ។

ឯកសារនេះ នៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មាន ៣ ចប់ លេខសាស្ត្រា ៥៩០-៥៩១-៥៩២ បានពិនិត្យមើលតែ

១ កវីនេះ បានបញ្ជាក់នាមរបស់ខ្លួនថ្វីច្នេះថា "អហំវីទុំ នាមយ៉ែមសុខសម ប្រុះប្រាជ្ញា យល់ ព្រះធម៌និទាន វិញ្ញាណទសពល គ្រាស់សាងកុសល ក្នុងជាតិពោធិ" ។

គម្ពីរ ១ លេខសាស្ត្រា ៥៩២ ។

**អត្ថបទផ្ដើម** នេះបទគាកគតិ ។ អហំនមា នមស្កាក សុសម្ពុទ្ធំ អនុត្តរេ សេដ្ឋាគុណំ បុញ្ញក្ខេត្តំ បញ្ញាញាណោ ។ ធម្មគុណំ និយ្យានិកំ អរិយបថោ មោក្ខបទំ សង្ឃគុណោ នមស្កាពេ-ត្តមោកាយំ ។

ខ្ញុំអរនុនអង្គ កិរិន្ទ្រទៅត្រង់ ផ្ដោះគុណពុទ្ធ ព្រះប្រាំព្រះអង្គ ក្រោកចស្រង់ស្រិតស្រាំង សត្វសង្ស្ការរំលាងបាបបង់ ។ . . .

. . . . . . . . ។ល។

**អត្ថបទបញ្ចប់** បានត្រាស់ច្បាស់ប្រាជ្ញា ទ្រង់ទេសនាក្នុំជាតក សំដែងសេចក្ដីទុក្ខ ឲ្យមហាជនផង់ត្រង់ត្រាប់ ។ សូរេចអស់សេចក្ដី តាមបាលីនិបាតច្បាប់ តំណតសណ្ដាប់ ពីប្រាំពីរខ្សែមកណា ។ ប្រាកដប្រកបកាព្យ រឿងរ៉ាវរៀបតាមគាថា ដួបចប់ចូលចាប់ជា ប្រាំបីខ្សែម៉្ងះឯងហោង ។

—X—

**បំណាងជើង** "សាស្ត្រា បុញ្ញសារសិរសា"

**អ្នកនិពន្ធ** អ្នកឧកញ៉ាព្រះឃ្លាំង "នង" កាលនៅជាឧកញ៉ាវង្សាក្សត្រី ។

**កាលបរិច្ឆេទ** ថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំម្សាញ់ នក្សត្រ ព.ស. ២៣៤០ ម.ស. ១៧១៩ (គ.ស. ១៧៩៧) ។

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុដ្ឋលីលា)

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មាន ៣ វៀរ ចប់ជុំជាតក់ ។

លេខសាស្ត្រា ៥៩៣ ។ ឯកសារនេះ មាននៅបណ្ណាល័យ

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

អត្ថបទដើម នមាមិហំ ពុទ្ធសេដ្ឋំ លោកជេដ្ឋោ បរមសត្ថា ទេវម-

នុស្សា លោកុត្តមោ អនន្តញាណំ ។ . . .

ទសករកំបង់ បទបាទនុនអង្គ នុនអញ្ជលី មនោវាចា

កាយាទ្វី បញ្ចប្រតី- ស្ថានបំភអភិវាទ ។ ព្រះស្រីសម្មា- សម្ពុទ្ធ-

សាស្តា ធម្មិកលោកនាថ ឯកឥតទុតិយំ ទេពទាំងលោកធាតុ

ក្រាបក្រោមព្រះបាទ ព្រះបរមសារពេជ្ញ ។ . . .

. . . . . . . . ។ល។

អត្ថបទបញ្ចប់ ខ្ញុំគិតកាព្យ កាលជាឧញ៉ា វង្សាក្សត្រី ជាខ្ញុំព្រះបាទ

នរនាថចក្រី ពមាធិបតី ទ្រង់កង្សផ្តើងថ្កាន ។ ស្ដេចសោយ-

វិលា- ល័យលុះដន្មា ពិធីបាកហ៊ាន ខ្ញុំសោកវេល ខ្វាយខ្វល់ពុំ

បាន គិតកាព្យនេះទាន ពិតពុំទាន់ចប់ ត្បិតលោកហៅហ្វា

ទឡ្ហៈជាតិជា បិតាធម៌ថប់ គាត់តែងមន្ត្រី សេនិយសាយសព្វ

សង់មេរុមណ្ឌប ប្រាសាទវេទនា ។ ធ្វើបុណ្យសព្វថ្ងៃ

ពេញពីរវស្សា ឲ្យទានទ្រព្យធន ពេកពន់មហិមា ទើបបាន

បូជា ថ្វាយព្រះអគ្គី ។ ហើយលោកគន់គិត តែងឲ្យធ្វើឥដ្ឋ
សាងព្រះចេតិយ បញ្ចុះព្រះធាតុ ព្រះបាទចក្រី ធ្វើបុណ្យប្រក្រតី
ឧទ្ទិសថ្វាយទៅ ។ លោករួមរក្សា ព្រះរាជបុត្រា ទាំងប្អូន
ចមចៅ គ្រប់គ្រងធានី បុរីឥតសៅ អស់រាស្ត្រក្នុងក្រៅ សឹង
សុខសប្បាយ ។ លោកឱ្យសក្តា ខ្ញុំជាឧកញ៉ា ព្រះឃ្លាំងទៅ
ហាយ ឃ្លាំងមណីរត្ន ទើបគិតខ្វល់ខ្វាយ កាព្យកិច្ចបរិយាយ
វែងចងចរចា ។ ទុកតជាកេរ្តិ៍ ក្រោយក្រែងចំណោរ អនាគតា
ក្រែងសោះសូន្យស្ងាត់ បទបានបរិហារ ជាតិព្រះសិរសា បរម-
ចក្រពត្តិ ។ ពាក្យខ្ញុំសុភាព ពុំពីរោះរាប ក្រែងភ្លាំងភ្លេចភ្លាត់
ពិតពុំទាក់ទង គន្លងបរមត្ថ អ្នកណាចេះស្ទាត់ តម្រង់ឲ្យទាន ។
តំណសាសនា ប្រាំពាន់វស្សា ជាតិព្រះទ្រង់ញាណ ក្នុងហា-
សិបជាតក៍ និបាតមែនមាន អស់អាថ៌និទាន និដ្ឋិតចែងចប់(១)។

---

១ អត្ថបទបញ្ចប់នេះ វែងជាងអត្ថបទដទៃទៀតបន្តិច ដោយខ្ញុំយល់ថា មានសេចក្តីទាក់ទងដោយជីវប្រវត្តិរបស់អ្នកនិពន្ធខ្លះ ។ មួយវិញទៀត គប្បីយល់ថា អ្នកឧកញ៉ាព្រះឃ្លាំង (នង) នេះ ជាកវីឯកមួយរូប ក្នុងសម័យឧដុង្គ ដែលបានទុកស្នាដៃជាច្រើនរឿង ដូចមាន នយល័ក្ខណ៍ ខាងលើស្រាប់ ។ មានឯកសារមួយទៀត ហៅថា “សាស្ត្រាព្រះសិរសា” ចុះលេខសាស្ត្រា ៦៦៨ ដែលពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តសិរីឧទុម ខេត្តកំពង់ចាម ហើយឯកសារនេះ មានតែ ១ ខ្សែ ចប់ជុំជាតក៍ មានចំនួនសន្លឹកដល់ ១៣៤ សន្លឹក តែចាស់គ្រាំគ្រាពេក ។ អ្នកនិពន្ធ-កាលបរិច្ឆេទ-អត្ថបទផ្ទៃរឿង ស្របគ្នានឹងស្តាស្ត្រាបុញ្ញសារសិរសានេះទាំងអស់ ខុសតែចំណងជើងប៉ុណ្ណោះ ។

បំណងជើង សាស្ត្រា ល្បើកកាកី (១)

អ្នកនិពន្ធ ព្រះបាទព្រះហរិរក្សរាមា ព្រះអង្គឌួង

កាលបរិច្ឆេទ ថ្ងៃពុធ ១១ កើត ខែពិសាខ ឆ្នាំកុរ សប្តស័ក

ព.ស. ២៣៥៨ ម.ស. ១៧៣៧ ច.ស. ១១៧៧ ។

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជង្គលីលា)

ប្រភពរឿង ៥០០ ជាតក៍ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ ចប់ជុំជាតក៍ ។

ឯកសារនេះ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត សិរីបទុម ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦៨១ ។

អត្ថបទដើម នេះបទកាកគតិ ។ អង្គអញត្រកូល ជាតិជាកំពូល កម្ពោជ-
ជាទី នុជនាថបូឡ្យជា បុត្រាជាតិ ក្នុងពជសុវី សុខុមវត្តិយា ។
បរបោកបូរី បុកណាវេណី ទៅជិតនៅនា ក្រុងទេពនគរ កុល-
ករចិន្តា តែងតាមបទបា- ឡីលោកសំដែង ។ ក្នុងប្រាំរយជាតក៍
បង់ជាបទបាទ កិច្ចកាព្យចាយថែង ទុកជាតំណតែងតរវង្វែង
ឲ្យអស់គម្ពែង ជនជាតិដឹងជាន ។ . . . ។ល។

---

១ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានបម្លងចេញ បោះពុម្ពផ្សាយមកយូរហើយ ហៅថា (រឿងកាកី) ដាក់លក់ដោយដំឡៃថោកៗ ។ សព្វថ្ងៃ ប្រើជាសៀវភៅសិក្សា សម្រាប់ថ្នាក់ទី ១ ទំនើបផង ។

អត្ថបទបញ្ចប់ ស្ត្រីស្រីណាគាប់ កុំត្រូវគ្រាប់តែគាត់ គំនិតផិតក្បត់ប្តី

ពេលស្វាមីសេពសោយ ៗ កំពុងពេញស្នេហា ចិត្តពេស្យា

ទឹកនិរណាយ ផិតក្បត់ប្តីទាំងឡាយ ព្រោះចិត្តពោរពេញសម្ពន្ធ ។

ដំណើរនោះកាត់ តែប្រសេចក្តីសៀមភាសា ជាពាក្យខ្មែរកាព្យ

សូរសេចរឿងអម៉េះហោង ។

—X—

បំណងដើម "សាស្ត្រា ព្រះសមណគោតម"

អ្នកនិពន្ធ គ្មានបញ្ហាក់ក្នុងអត្ថបទ ។

កាលបរិច្ឆេទ

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជង្គលីលា

ប្រភពរឿង ប្រហែលជា ក្នុងក្រមបញ្ញាសជាតក ។

(ក្នុងបញ្ញាសជាតក មានឈ្មោះជាតក១ហៅថា សមណគោតម)

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មាន ៩ ខ្សែ ប់ដុំជាតក ។

សាស្ត្រាគម្ពីរនេះ ពុទ្ធសាសនបណ្ឌិត្យ បានទទួលមក អំពី

ខេត្តកំពង់ចាម ចុះលេខសាស្ត្រ ៦៨៥ ។

# សិលាចារឹកត្រពាំងរុន

លោក ឌឹក-គាម ស្រាវជ្រាវរៀបរៀង

(គ)

## អត្ថបទនៃសិលាចារឹកត្រពាំងរុន

ជាភាសាខ្មែរចារដោយ កវីន្ទ្របណ្ឌិត

(១) ៩២៨ សកបិកេតជ្យេស្ឋ ឝុក្រវារអាទ្រនក្សត្រឝុទ្ធ-លិវ្រះកម្រតេងអញ ឝ្រីជយវីរវម្មទេវ (២) ស្មេយវ្រះរាជឝុ ឝក ៩២៤.០[1] ស្ដាប(តា) វ្រះឝិលាតតាក[2] វ្រះឝ្រីយគោ ធរបុរីបិ (៣) ម្រតាញ៖ខ្លាង ឝ្រីកវីន្ទ្របណ្ឌិត ស្រុកវ្រៃងក្រិ . . . បុគិវេទ-កគ្លោកបិ ស្វំ ភូមិវ្រះករុណាប្រសាទលេង (៤) ជាវ្រះទាន បិ-ថ្វគ្គវ្រះកម្រតេងអញនារាយណម័ន ម្រតាញខ្លាញស្លាបនាត-ស្រុក វ្រៃករងតតិអជិ (៥) ម្រតាញខ្លាញ តោយមាត្ឫបក្ស ទារវ្រះករុណាប្រសាទតគិវ្រះរាជ្យវ្រះបាទបរមេឝ្វរ ០ វ្រះករុណា កម្រតាញ (៦) តនត្យុរវិភូមិបិឝ្មិម្រតាញខ្លាញបង្គុំប៉្យងគិវេទន ម័នមាន ភូមិអនិន្ទិតបុរតនម្ហិល (៧) បិអាយត្តតាកដ្ហាលគុ-សតោយប្ញុស្រុកវ្រៃករងបិសមិបនុវ្រះ ម្រតាញខ្លាញនោះ គិបិ ម្រតាញ (៨) ខ្លាញស្វំលេងជាវ្រះទាន បិថ្វគ្គវ្រះអាយវ្រៃករង

---

១– ០ ជាឈ្មោះដែលប្រើនៅសម័យនោះ ។ ២ ប្រហែលជា "សិលាតដាក" ប្រែថា ល្អាងភ្នំ ទេដឹង? ។

បុត្រនៃព្រះករុណាកម្រតាញខ្លោញ ឱយប្រសាទ (៩) ភូមិនោះ
ជាព្រះទាន ០ អ្នកសញ្ញកៈសវិតៈនោះ នាព្រះទ័យប្រសាទភូមិក-
ម្រតាញខ្លោញ (១០) ម្រតាញខ្លោញគ្រីប្រឹបិវិន្ទ្រវម៌្ម ០ ម្រ-
តាញខ្លោញគ្រីវាគិត្ធវម៌្មស្តេង អញតវញវ្យងម្រតាញខ្លោញប
(១១) គ្រីកវិន្ទ្រវិជយ ស្សង្គគុណទោមខរស្បស្តេងទន្លេជ្រៃអាចា-
យ្យប្រធានសភាសត ០ ម្រតាញខ្លោញ (១២) គ្រីវាសអ្កល្ប
ស្វតព្រះធម្មគាស្ត្រ ០ ម្រតាញខ្លោញ គ្រីក្សិតិន្ទ្រវម៌្មខ្លោញគ្លង់ឯក
០ ម្រតាញខ្លោញគ្រី-ន្ទបតិន្ទ្រ (១៣) វម៌្មខ្លោញគ្លាងទោម្រតាញ
ខ្លោញគ្រី-ក្សិតិន្ទ្រវម៌្មខ្លោញគ្លាងត្រិណិម្រតាញខ្លោញ គ្រីន-
វេន្ទ្របណ្ឌិតបាមព្រះបញ្ជិយ (១៤) ព្រះបន្ទូលស្តេងអញទន្លេជ្រៃ-
ប្រទៅឱយភូមិនេះ កម្រតាញខ្លោញជាព្រះទានព្រះបន្ទូលប្រេ-
ស្តេង (១៥) អញទន្លេជ្រៃនគុណទោមទគ្គិផោង ស្សង្គបុញ-
កបាតកម្រតេងអញព្រះគុរុម៌នឱយករុណាប្រសាទ (១៦) ភូមិក-
ម្រតាញខ្លោញគ្រីកវិន្ទ្របណ្ឌិតប្រេសមក្សនព្រះសភាផោង អាយ
ព្រះសភាស្តេងអញទន្លេជ្រៃ (១៧) នគុណទោមទស្សិផោង-
ស្សង្គបុញ កបាពោះហព្រះគាសនតកម្រតេងអញព្រះគុរុកម្រតេង

អ័ញព្រះគរុបន្ទូល (១៨) ព្រះអាសនតលោញ គ្រឹងរភាគវិតប-
ម្រេព្រះក្រលាៈស្រាងតខ្លោញ សំរាបនុវិបហោត្បូងវៀវហារាធិ
(ការធិ) (១៩) ការិ នុវិបរាបទគវិតតរង្វាងឯកប្រេទៅនុស្តេង
អ័ញទន្លេជ្រៃ ប្រេថ្វៃយោព្រះគរុសនស្តេងអ័ញទន្លេជ្រៃ (២០)
នុព្រះសភា រង្វាងទៅឈ្មោះតគិស្រុកព្រៃករងស្តេងអ័ញទន្លេជ្រៃប្រេ
រង្វាងទៅហោគ្រាមវិទ្ធបុរស (២១) ប្រជានរសមីបនុស្រុកព្រៃ-
រងចុំបាន តោយបន្ទូលព្រះគរុសនប្រេបង្យង តយុគបតនាគ-
ង្គោលតភូមិ (២២) តោះបិឡយកគ្រតាញខ្លោញគ្រឹកវិទ្ធ្របណ្ឌិត
តគិ ទគមីៈរាបផ្សេម្ពតោះសៅរិវរវេតីនក្សត្រស្តេងទន្លេជ្រៃ
(២៣) នុព្រះសភាបៈង្គោល តភូម្យៈឆាះឲយជាព្រះទានកម្រភាញ
ខ្លោញរោះហព្រះគរុសន (២៤) ម្រតាញខ្លោញថ្វិន្តព្រះកម្រតេង
អ័ញនរាយនអាយព្រៃករង គ្រាមវិទ្ធតជាសាក្សីទាសង្គោលខ្លោញ
(២៥) វិលប្លាញគ្រេះរវេហ ០ រាបទគគ្រាមស្រុកអធ្វាជិត ០
រាបហិស្រុកត្រវាងគុរុ ០ រាបគម ប្រជាន (២៦) ស្រុកកំលុង
លំរាង ០ រាបស្វរ ទគគ្រាមស្រុកកំលុងលំរាងសុត ០ ម្រតាញ
ព្រះទូកលេ យោនរាយនខ្ញុំព្រះ (២៧) ប្តាលបាសស្រុកព្រៃករង-

សិប្បទ្ទយវិត្តុទុំកំស្តេង  បរាជិតស្រុកក្តាលវិលវាបជ្រៅគ្រាបវិទ្ធ ស្តេញ (២៨) ប្រត្យយស្រុកសម្បៀប វាបទបគគ្រាមស្រុកទា-ត្យកតិក វាបគិរិព្រៅហ្មណ វាបប្រ វាបទាន បវាឯមរាប (២៩) វិទ្យាមយខ្លោញផ្កាលអ្នឹន[1] វាបបិត មេអ្សក មេធំមេទេស មេសានមេទូត តេះស្យង ស្រុកអមរាលយ (៣០) ម៉នស្តេង អញទន្លៃជ្រវិងអំវិសង្គោល ត ភូមិបិ ឱយកម្រតាញខ្លោញ ០ ព្រះស្តាបអាយព្រះបតុទ្វារ (៣១) តាមេលព្រះវ្នមតគិប្រែបច្ចៃនិម្នា-ណ ០ ម្រតាញខ្លោញ ត្រីកវិត្រូបណ្ឌិត ស្វតគ្លោកតាព្រះវិឞ្ណុ-ធម្មបង្គមប្ប៉ៀង  (៣២) និរវទនពេះវាផលផ្លេឃឱយទានភូមិ ស្តេងអញទន្លៃជ្រៃបង្គំ ប្ប៉ៀងនិវេទនម៉នមានភូមិតគិខ្លោញផ្កាល (៣៣) អនិនលកផ្តាត អ្នកតប្ចលកំលុងប (ង្វា) ត គោលតោះ បិអ្នករោលវាទព្រះ គាសនប្រែទៅស្វេងបិត្យ (៣៤) តាមានភូមិ តនិម្វលិ ប្រែឱយស្មោង ០ ស្តេងអ៉ញទន្លៃជ្រៃនុម្រតាញខ្លោញ ត្រីប្រឹបិវិត្រូវម្មិនុគុណទោគទស៊្សី (៣៥) ដោង្វបុញកឋាវោះហ ព្រះគាសនតកម្រតាញអ៉ញត្រីគុរុ ០ កម្រតេងអ៉ញព្រះគុរុបត្វល

(១) ជាពាក្យសង្ខេបពីពាក្យថា អនិន្ទិតបុរ ។

វ្រះ (៣៦) គាសនតលោញវ្រហ្មភាគវតបម្រេតខ្លោញសំតាប ឆុ
ម្រតាញគ្រីគ្រុតភក្តិតជិតខ្លោញសំតាបឆុ (៣៧) វង្វាងឯក ប្រេ
ទៅថ្ងៃពោះហាវ្រះគាសនវ្រះសភាពោះហានេះទៅ ឈ្មោះតស្រុកវ្រៃ
កង្វ ប្រេវង្វាង (៣៨) ហៅគ្រាមវ្ប្ទបាត្តោយស្រុក្កបន្ទួលវ្រះគា
សនឱយគបបិតនត្បងទហាមានភូមិ វណ្ណិគ្រមតនិ (៣៩ ម្បូល
០គ្រាមវ្ប្ទស្បង្គគបបិកឋារុវភូមិ អនិនតនិម្បូលតោយក្រៅគោល
០ វ្រះសភាវាសអំរុងភូមិតមាន (៤០) អបវាទកំលុងគោលទេប-
វាសអំរុងភូមិតនុជាស្នោងម្វាយអំរុងសង្គោល សមក្បនុគ្រាមវ្ប-
ទ្ទបុរុប )៤១) ប្រជានដោងបន្ទួលវ្រះគាសនត វាបគិមត្ជូយ្យ
ស្រុក្កំលុងលំវាទុកិក្ប្បវ្រះស្រមោតមានភូមិ (៤២) ចូលកំលុង
គោល ... ភូមិនោះស្នោងម៉នវ្រះស្តាបនាវ្រះគិលាត តាកនាវ្រទិ-
កតវ្រះទានបិឱយត (៤៣) វ្រះបំ (... ម្រតា) ញ ខ្លោញ គ្រឹ
កវិន្ត្របណ្ឌិតបង្គុប្បឹងវេទនម៉នភូមិស្រាបតីវ្រះសភាទៅ (៤៤)
ឱយស្នោង ... ដោង ០ វ្រះគាសនប្រេសិទ្ធភូមិនោះម៉នឱយទាន
កម្រតាញខ្លោញតវាបផ្ទែកពោំ (៤៥) នោះមាន ... ម្រតាញ-
ខ្លោញ បង្គុប្បឹងនិវេនសោតលេងអាបុ្តទុក្តវ្រះវិក្តអាយវ្រះសភា-

សេង (៤៦) អាប្ដិបារតិគិលា ... វ្រះវ្រាហ្មគាលាលេងអាប្ដិទុក្ដ ផ្អាត នាបំរេវ្រះក្រលាស្រោងលេងអាបិទុក្ដ (៤៧) ប្រគស្ដត... (ស្រុ)ក វ្រៃករងលេង្វំអាប្ដិ កុលសន្ដាន ម្រត ញខ្លោញយោក ភូមិនេះបិលក (៤៨) ផ្ដាតអ្នក ... អវិធិតអំបាលនេះរោះហាតថ្មី ម្រតាញខ្លោញ៖ភូមិវ្រះទានតទិង (៤៩) ប្វាយ...បិតទិងប្វាយ ប្វ្រិគតវ្យរផែបិ ១៩បន្ដោយប្វាយស្លិកគត...(ប្វា)ទ (៥០)ភូមិ... ល្វោះគោលឧត្ដរឧត្ដរតើរិ នៅរិស្លិក ១ គតវ្យរ ៥០(៥១)ក្វនម្រ (តាញខ្លោញគ្រីករិន្ទ្រ)បណ្ឌិត តង្វះលោញនាវាយណាទារង្វះម្រ តាញគ្រីករិន្ទ្រ (វិជយ...) កន្សៃ (៥២) បម្រេវ្រះក្រលាស្រោង ជាវាជបុរោហិតឧត្ដរម្រតាញខ្លោញតវិបាតាញបង្គុំប្វ្យង (៥៣) និវេទនកុលេម្រតាញ គ្រីករិន្ទ្រវិជយម្វាយមូលនុកុលេម្រតាញ ខ្លោញ នាភាគវតបំប្រេទហ (៥៤) កុលេម្រតាញគ្រីករិន្ទ្រវិជ-យអាបទហកុលេម្រតាញគ្រីករិន្ទ្រវិជយ (៥៥) មូលតកុលេម្រ តាញខ្លោញអាចរិយភាគតា វ្រះកម្រតេងអញនាវាយណានុភូ-ម្យាក[1]ទ្វំ (៥៦) ផ្លើយនោះអាយត្ដកុលម្រតាញ គ្រីករិន្ទ្រ

១- មកពី „ភូម៉ា" ភូមិក អ្នកកាន់កាប់ភូមិ ។

វិជយតាភាគព្រះកម្រតេងអញឝិវលិង្គនុ (៥៧) ខ្ញុំភូម្យាកផ្លេយ អាយត្តតក្វនម្រតាញខ្លោញ តោយភាគកុលេស្តេងនត្ធិកាបាយ្យៀ (៥៨) អាចាយ្យៀហោមបិបាំតសំម្ងូលនុម្រតាញខ្លោញ ផ្លេនា·ភាគវិតបំរេនេះ កល្បនាតរោនេះ (៥៩) នៅរុកុលេម្រតាញខ្លោញកុលអ្នកនេះ តវ្យិរលោះតមានភក្តិបរិបាលនលេងរោះហានេវុំ (៦០) អាប្តបនហ្យតទមាន្តបនហ្យតកល្បនានេះ បញ្ចុ(?)តិវ្យិវិហារ កម្រតេងផ្ទែករោំ និណ្ណាយត (៦១) តបរលោកព្រះយ-មយាតាតនរកតទំនេប្រអរិបីល្ងះសង្សារ ០ នាភូមិភាគ ០ ភូមិឧត្តរនុ (៦២) ភូមិព្រះទានតិ ម្រតាញខ្លោងជ្ងន្ត ព្រះកម្រតេងអញនារាយណ ភូមិតិទក្សិណនុស្រេព្រះទានបិ (៦៣) តិម្រតាញខ្លោញជ្ងនតកម្រតេងអញឝិវលិង្គ ។

## បទានុក្រម

*សិលាចារឹកនេះ ខ្ញុំមិនបាច់សរសេរតាមបែបភាសាខ្មែរយើងសម័យបច្ចុប្បន្ននេះទេ ខ្ញុំគ្រាន់តែជូនពាក្យខ្លះដែលលោកអ្នកអានមិនធ្លាប់បានឃើញដូចតទៅនេះ :-*

| | | | |
|---|---|---|---|
| *កកេ* | *ក្រោម* | *ផៅង* | *ផង* |

| | | | |
|---|---|---|---|
| ក់ម្រេគង | គម្ពែង | ផ្តេយ | ផ្តៃ |
| កេត | កើត | ម័ន | មុ័ន |
| ក្រលាស្រោង | ក្រឡាស្រង់ | ម្រតាញខ្តោញ | គម្ពែងខ្តោង |
| គ្ត័ង | ឃ្តាំង | ម្តាយ | មួយ |
| ឃោ | ឃោសកៈ | លោញ | ខ្តោញ? |
| ចាម | ចាំ | ល្តោះ | លុះ |
| ជូន្ត | ជូនដំ | វល | ពល |
| ជៀស្ត | ដេស្ត | វេល | ពោល |
| ដេង | ដើង | វ្តំ | ពុំ |
| ដ្ទាល | ឈួល | វ្តង | ពួង |
| គនក្យង | ដណ្តឹង | ប្រាហ្មណ៍ | ព្រាហ្មណ៍ |
| តេំ | ដើម | ប្រះ | ព្រះ |
| តោយ | ដោយ | សំគាប | សណ្តាប់ |
| ច្យង | ត្យូង | ស្តាប | ស្តេប |
| ទុ, ទូ | ទូវ | ស្តេង | ស្តែង |
| បន្ទួល | បន្ទូល | ស្យង្ត | សឹងដ៏ |
| បម្រេ | បំរើ | ស្វត | សូត្រ |
| ប៊ | បី | ស្វេយ | សោយ |

| | | | |
|---|---|---|---|
| ប្រេ | ប្រើ | ស៊ំ | ស៊ុម, សុំ |
| ប្រេថ្វ | ប្រើធ្វើ | អំវិ | អំពី |

ដើម្បីឲ្យងាយយល់ព្រះនាមព្រះមហាក្សត្រ ដែលមាននៅក្នុងសិលាចារឹក ខ្ញុំសូមជូនព្រះបរមនាមព្រះមហាក្សត្រខ្លះ ដែលខ្ញុំឃើញមាននៅក្នុងសិលាចារឹកខ្មែរ ។ ហេតុដែលយើងមិនស្គាល់ព្រះនាមព្រះមហាក្សត្រ ជាហេតុមួយនាំឲ្យយើងខាតពេលជាច្រើន ក្នុងការស្រាវជ្រាវរកព្រះមហាក្សត្រ ដូចជា ព្រះបាទជ័យវរ្ម័នទី៧ជាដើម កាលដែលព្រះអង្គមានព្រះជន្ម មានព្រះនាមថា ព្រះបាទជ័យវរ្ម័នទី ៧ ដល់ព្រះអង្គសុគតទៅមានមរណនាមថា ជយវរ្មធិវបរមេស្វរ ។

| នាមព្រះមហាក្សត្រ | មរណនាម |
|---|---|
| ព្រះបាទ ភវវរ្ម័ន | សិវបទ |
| ,, ជ័យវរ្ម័នទី ២ | បរមេស្វរ |
| ,, ជ័យវរ្ម័នទី ៣ | វិស្ណុលោក |
| ,, ឥន្ទ្រវរ្ម័នទី ១ | ឥស្វរលោក |
| ,, យសោវរ្ម័ន | បរមសិវលោក |
| ,, ហរ្សវរ្ម័នទី ១ | រុទ្រលោក |
| ,, ឥសានវរ្ម័នទី ២ | បរមរុទ្រលោក |
| ,, ជ័យវរ្ម័នទី ៤ | បរមសិវបទ |

| | | |
|---|---|---|
| ព្រះបាទ | ហស៌វរ្ម័នទី ២ | ព្រហ្មលោក |
| „ | រាជេន្ទ្រវរ្ម័នទី ២ | សិវលោក |
| „ | ជយវរ្ម័នទី ៥ | បរមវិរលោក ឬ បរមវីរលោក |
| „ | សុរិយវរ្ម័នទី ១ | និព្វាណបទ ឬ បរមនិព្វាណបទ |
| „ | ហស៌វរ្ម័នទី ៣ | សទាសិវបទ |
| „ | ជយវរ្ម័នទី ៦ | បរមកៃវល្យបទ |
| „ | ធរណីន្ទ្រវរ្ម័នទី ១ | បរមនិស្កលបទ |
| „ | សុរិយវរ្ម័នទី ២ | បរមវិស្ណុលោក |
| „ | ជយវរ្ម័នទី ៧ | ជយវរមទេវរមេស្វរ(១) |
| „ | អង្គដួង | បរមកោដ្ឋ |
| „ | នរោត្តម | សុវណ្ណកោដ្ឋ |
| „ | ស៊ីសុវត្ថិ | រាជាទុកោដ្ឋ |
| „ | ស៊ីសុវត្ថិមុនីវង្ស | ខត្តិយកោដ្ឋ |
| „ | សុរាម្រិត | មហាកាញ្ចនកោដ្ឋ |

## វាក្យស័ព្ទ

ការសិក្សានូវសិលាចារឹកត្រពាំងរុនទេះ យើងអាចទាញយកនូវន័យនៃពាក្យខ្លះដូចតទៅនេះ :

១– BEFEO P. 145 T. XX VIII—1928 ។

១-ពាក្យ នៅសិលាចារឹកខ្មែរយើង គេតែងជួបប្រទះជាញឹកញាប់នូវពាក្យខាងក្រោមនេះគឺ :

ត្តិ ជាពាក្យសន្ធានសំរាប់តភ្ជាប់ប្រយោគ

យោ ជាពាក្យដែលបំព្រួញមកពីពាក្យថា ឃោសនា

២-សង្ខ្យាស័ព្ទ នៅសិលាចារឹកគ្រប់ជំនាន់ យើងបានជួបពាក្យមួយដែលជាសង្ខ្យាស័ព្ទ គឺពាក្យថា «ស្លឹក» ។ ចំនួននេះមានប្រើរហូតមកដល់សព្វថ្ងៃនេះ ។ ពាក្យថាស្លឹកជាចំនួនមួយស្មើនឹង "៤០០" ។

ការរាប់តាមសង្ខ្យាស័ព្ទនេះមានដូច្នេះគឺ

១ ដំប = ៤

១ ដ្លឹន = ១០ " = ៤០

១ ស្លឹក = ១០ " = ១០០ " = ៤០០

៣-វង្វាស់ នៅសិលាចារឹកនេះ យើងអាចសិក្សានូវរង្វាស់មួយបែបហៅថា « អំរុង » ។ ពាក្យថា អំរុងនេះ ប្រើសំរាប់វាស់ដីស្រែដែលធំ (mesure agraire) ។

គម្ពែង នៅសិលាចារឹកខ្មែរ យើញមានពាក្យគម្លែងនេះស្ទើរតែគ្រប់សិលាចារឹក ។ តែសម័យសិលាចារឹក គម្លែងមិនសរសេរដូចសព្វថ្ងៃនេះទេ ។ គម្លែងសរសេរប្លែក ៗ គ្នាដូចតទៅនេះ

ក- កម្រតេង                    គ - កម្រតេញ
ខ- កម្រងតាញ                  ឃ - កម្រងតាង

ពាក្យទាំងឡាយនេះ មានន័យដូចគ្នាគឺ : ព្រះតេជព្រះគុណ, ម្ចាស់ថ្លៃ ឬអ្នកមានបុណ្យមានអំណាច, មានយសសក្តិគួរគោរពបូជា, មានអានុភាពដ៏ខ្ពង់ខ្ពស់ ។

ពាក្យនេះច្រើនយកទៅផ្សំជាមួយសព្ទដទៃទៀត ហើយអាចឲ្យអត្ថន័យផ្សេង ៗ ទៅដែរ ។

១- កម្រតេងក្រឡា = កម្តែងក្រឡា «ស្វាមី, ប្តី, មេឃុំ» ។

២- កម្រតេងផ្ទៃក្រោម = កម្តែងផ្ទៃក្រោម គឺព្រះមហាក្សត្រ ។

៣- កម្រតេងខ្មោញ = កម្តែងខ្មោង ។

៤- កម្រតេងអញ = កម្តែងអញ ពាក្យនេះគេច្រើនប្រើបានទៅមនុស្ស មានឋានៈខ្ពង់ខ្ពស់ ឬព្រះមហាក្សត្រជាដើម :

ឧទាហរណ៍ :

ក)- សិលាចារឹកក្នុងដីស្បូវថា : . . . ៩៤១ គកព្រះបាទកម្រតេងអញ ត្រីសុយ្យវរ្ម្មទេវជួន . . . «នៅសកកាជ ៩៤១ ព្រះបាទសុរិយវរ្ម័នប្រទាន . . . ។

ខ)- សិលាចារឹកត្រពាំងរុនថា . . . ម្រតាញខ្មោញជួនគ កម្រតេងអញគិរលិង្គ . . . ។

# សេចក្ដីប្រែសម្រួលពីអត្ថបទសំស្ក្រឹត

របស់ កវិន្ទ្របណ្ឌិត

១– សូមថ្វាយបង្គំព្រះពិស្ណុទេវ ដែលជាម្ចាស់នៃបឋមវត្ថុដ៏បរិបូណ៌ ដើម្បីបង្កើតនូវពិភពលោក ដែលមានព្រះបុរុសៈមួយចំណែកក្នុងពិភពលោកនេះ ។

២– ព្រះអង្គមានគុណសម្បត្តិជាបឋមហេតុ ហើយដែលបានប្រកាសដោយអាទិទេព និងដោយសត្វលោកទាំងអស់ និងដោយព្រះព្រហ្ម ដែលកើតអំពីផ្កាឈូក ដែលដុះចេញអំពីព្រះនាភីរបស់ព្រះអង្គ ។

៣ ដោយសុភពចារបស់ព្រះអង្គ គឺព្រះមេរុដែលមានពីកំណើតព្រះព្រហ្ម ហើយនឹងអាទិទេពដទៃទៀតក៏ចេញមកអំពីផ្កាឈូកដែលចេញមកអំពីនាភីរបស់ព្រះអង្គដែរ ។

៤– កើតចេញអំពីព្រះបាទជាទីគោរពនៃសព្វសត្វទាំងឡាយ នទីទាំងឡាយដែលអាចជំរះឲ្យបរិសុទ្ធនូវលោកទាំង ៣ បានប្រកាសនូវមហិទ្ធិភាពដ៏ឧត្ដមខ្ពង់ខ្ពស់ប្រសើរជាងអ្វីទាំងអស់ ។

៥– រំលងនូវពិភពលោកក្នុងនិមិត្តរូបនៃមនុស្សតឿ ដោយវីរិយៈដំហាន ៣ ធ្វើឲ្យអ្នកប្រាជ្ញមុនីប្រមើលឃើញវិសាលភាពនៃធម្មជាតិរបស់ព្រះអង្គ ។

៦– សូម្បីច្បាំងនឹងមនុស្ស ១-០០០ នាក់ ជនណាដែលមានកិរិយាត្រឹមត្រូវ បានប្រកាសនូវសេចក្ដីស្មោះស្ម័គ្ររបស់ខ្លួនដោយនាមតែមួយគឺវិស្ណុ ដែលពេញដោយអត្ថន័យ ។

៧- ចាក់ចុះទៅក្នុងសម្ភារវត្ថុគ្រប់យ៉ាង ព្រះអង្គជាអតិបរមាណូតូចបំផុត ជ្រាបចូលទៅក្នុងចក្រវាឡរបស់ព្រះអង្គទាំងអស់ ព្រះអង្គជាបុគ្គលធំបំផុតជាងវត្ថុដែលធំបំផុតទាំងអស់ទៀត ។

៨- សមភាពរបស់ព្រះអង្គចំពោះសព្វសត្វទាំងអស់ ដែលមានអនុភាពស្មើនឹង ព្រះអគ្និ ហើយនឹងស្មើនឹងអាទិទេពដទៃទៀត គឺព្រះអង្គសំរាប់ជាអ្នកគោរពបូជា ចំពោះអ្នកដែលគោរពបូជាទាំងឡាយ ។ ហើយព្រះអង្គជាមូលហេតុនៃសោមនស្សនិងទោមនស្សនៃតណ្ហារបស់លោក ។

៩ ព្រះនាមរបស់ព្រះអង្គ គឺបុរុសុត្តមៈតែមួយប៉ុណ្ណោះ ដែលអាចកំចាត់ចេញនូវសត្រូវដទៃ ៗ ហើយប្រកាសនូវឧត្តមភាពគ្រប់ទីកន្លែងទាំងអស់ ។

១០– ក្នុងពេលដែលពិភពលោកកើតឡើងបន្តិចម្តង ៗ ព្រះអាទិត្យបានទៅជាគ្រឿងអលង្ការខាងមុខព្រះអង្គ បន្តមកទៀត ហើយបានទៅជាវដីពលង្ការសំរាប់ព្រះទ្រព ហើយទីងអាសនៈជាវិការនៃមាសរបស់ព្រះអង្គ ។

១១– សូមគោរពព្រះវិស្ណុដ៏រុងរឿង ដែលមានក្រោធ និងសក្តិឲ្យទៅជាកំណើតនៃរុទ្រៈ និងអជព្រហ្ម ។

១២– សូមបន្ទន់កាយចំពោះព្រះសិវៈ ដែលមានត្រីសូល៍ជាតំនឹងនៃជយជំនះដ៏មហាស្ចារ្យលើត្រីបុរៈ ។

១៣– សូមគោរពព្រះព្រហ្ម ដែលមានរស្មីដូចជាមាសដែលគេដុត

ដោយភ្លើង, ដល់ហិរណ្យគ្ក:ជាបុត្រនៃបច្ចាមិត្តរបស់ហិរណ្យក្ស ។

១៤– កាលណោះ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមស្រីជយ-វរ្ម័ន(១) ទ្រង់សោយរាជ្យរហូតដល់ទៅសមុទ្រ នៅស័ក ៧២៤ (គ.ស. ៨០២) ហើយមានព្រះរាជដំណាក់នៅលើភ្នំមហេន្ទ្រ(២) ។

១៥– ព្រះអង្គជាពន្លឺនៃព្រះវង្សរបស់សោមា, ជាព្រះចន្ទធ្វើឲ្យសប្បុរសជនមានអាយុជីវិតឡើងជាថ្មី គោរពព្រះឥសូរនិងឧមា ព្រះអង្គមានព្រះទ័យទន់ភ្លន់ដូចព្រះច័ន្ទ ហើយមានព្រះកាយប្រកបដោយលំអ ។

១៦– កាលណោះ មានបុរសម្នាក់ឈ្មោះជយេន្ទ្រកាស: បានទទួលនាមថាជយេន្ទ្រវល្លភ: មានដើមកំណើតនៅអនិន្ទិតបុរ: ជារាជបំរើរបស់ព្រះរាជា ។

១៧– រាជបំរើនេះ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ឈ្មោះគោវិន្ទ ដែលជាអ្នកចេះចាំស្ទាត់នូវវេទ: និងវេទង្គ: គាត់ជាអ្នកគោរពគោវិន្ទ (វិស្ណុ) ហើយបានធ្វើរូបសំណាកគោវិន្ទផង ។

១៨– នៅក្នុងស្រុកកំណើតរបស់គាត់ឈ្មោះតំរ៉ង និងវលិការបុរ: គាត់គោរពទេវតាដែលនៅរក្សាគ្រួសារបស់គាត់ ហើយគាត់សាងរូបទេវតាថ្មី ៗ ទៀតជាច្រើននៅក្នុងភូមិទាំងនោះ ។

១៩– ប្អូនរបស់ជយេន្ទ្រវល្លភ: ឈ្មោះវាសុទេវ: ជាព្រះរាជបំរើនៃព្រះបាទជយវរ្ម័ន(៣) ជាព្រះរាជបុត្រនៃព្រះបាទជ័យវរ្ម័នទី ១ ។

១ ជយវរ្ម័ន ។ ២ ភ្នំគូលេន ។ ៣ ជយវរ្ម័នទី ៣ វិស្ណុលោក (គ.ស. ៨៥៤-៨៧៧) ។

២០- គាត់បានទទួលនាមយ៉ាងគាប់ប្រសើរម្យ៉ាងទៀតថា នឫបេន្ទ្រវល្លភ: អំពីព្រះបាទជយវរ្ម័ន ហើយបន្ទាប់មកបានធ្វើជារាជបំរើនៃព្រះបាទឥន្ទ្រវរ្ម័ន[១] ។

២១- ប្អូនបន្ទាប់នៃបងទាំងពីរនាក់ខាងដើមឈ្មោះប្រទ្យុម្ន ជាព្រះរាជបំរើនៃព្រះបាទឥន្ទ្រវរ្ម័ន ហើយដោយភក្តីភាពចំពោះព្រះអង្គ គាត់បានទទួលគោរមងារជាឝ្រីនវីរ: ។

២២- គាត់បានកសាងសម្ភុលិង្គនៅសកករាជ ៨០២ ហើយតម្កល់ទុកនៅក្នុងប្រាសាទឝ្រីឥន្ទ្រេឝ្វរ:[២] ហើយគាត់បានថ្វាយសទ្ធិបុរ: និងខ្ញុំកំដរជាច្រើនទៀតផង ។

២៣- កូនប្រុសរបស់បងស្រីគាត់ ឈ្មោះសំកសិណ បានសេចក្តីប្រោសប្រាណឲ្យនៅក្នុងសំណាក់នៃព្រះបាទយសោវរ្ម័ន ជាព្រះរាជបុត្រនៃព្រះបាទឥន្ទ្រវរ្ម័ន ។

២៤- រាជបំរើ (សំកសិណ) របស់ព្រះបាទយសោវរ្ម័ន បានធ្វើជារាជបំរើនៃព្រះរាជបុត្រទាំងពីររបស់ព្រះអង្គ គឺហស៌វរ្ម័ន និងឥសានវរ្ម័ន[៣] ។

២៥ កូនរបស់បងស្រីសំកសិណ: ឈ្មោះរវិនាថ ជាព្រះរាជបំរើជំនិតរបស់ព្រះបាទជយវរ្ម័ន[៤] ។ (មានត)

---

១ ឥន្ទ្រវរ្ម័នទី ១ (ឥស្សរលោក គ ស ៨៧៧-៨៨៩) ។ ២ ប្រាសាទនេះសព្វថ្ងៃហៅថា ប្រាសាទបាគង នៅរលួស ។ ៣ ហស៌វរ្ម័នទី ១ (រុទ្រលោក) ឥសានវរ្ម័នទី ២ (បរមរុទ្រលោក)។ ៤ ជ័យវរ្ម័នទី ៤ (បរមសិវលោក ៩២៨-៩៤២ ។

# សេចក្តីកត់ហេតុទី ១
## អំពីការប្រជុំការងារនៅពុទ្ធសាសនបណ្ឌិត្យ

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីដប់បីខែសីហា មានការប្រជុំមួយ ក្រោមអធិបតីភាពនៃសហជីវិន លាង-ហ៊ាបអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ ដោយមានសហការីសំខាន់ខ្លះទៀត ចូលរួមផងគឺ :

១- សហជីវិន រៀល-ហេង អគ្គលេខាធិការ
២- ,, ញ៉ុង-សឿង អគ្គលេខាធិការរង
៣- ,, ឈឹម-ណាក នាយគណនេយ្យ
៤- សហជីវិនី ពេជ្រ-សល នាយការិយាល័យទំនៀមទម្លាប់
៥- សហជីវិន លី-ធាមតេង ការិយាល័យទំនៀមទម្លាប់
៦- ,, ឌឹក-គាម ការិយាល័យបោះពុម្ពផ្សាយ
៧- ,, សឺន-ផន បណ្ណារក្ស

ម៉ោង ៩ កន្លះ លោកប្រធានទីប្រជុំ បានប្រកាសបើកពេលប្រជុំ ដោយបានចាប់ផ្តើមលើកយកការពិនិត្យ ពីដំណើរការណ៍ ដែលក្រុមពុទ្ធ-សាសនបណ្ឌិត្យ បានអនុវត្តពីមុនមកហើយ ។ លោកនាយក និងលោកអគ្គលេខាធិការ ប្រកាសថា ដោយលោកទើបតែនឹងចូលមកកាន់មុខតំណែងថ្មី ដូច្នេះ លោកសុំឲ្យលោក ញ៉ុង-សឿង ជាអគ្គលេខាធិការរង ដែលធ្លាប់ធ្វើការនៅទីនេះជាយូរមកហើយ រាប់រៀបអំពីរបៀបធ្វើការរបស់យើងពីមុន ៗ មក ។

លោក ញូង-សឿន ក៏បានចាប់កប់រៀប ដោយសង្ខេប ពីក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលចែកជាផ្នែកផ្សេង ១ ទៀត មាន :-

–អគ្គលេខាធិការដ្ឋាន ដែលមានសាខារួមជាមួយគឺ : (គណនេយ្យ-ការងារសៀវភៅ-បេឡា ឃ្លាំងសៀវភៅ-សួនច្បារ) ។

–បណ្ណាល័យ

–ក្រុមជំនុំព្រះត្រៃបិដក

-ក្រុមជំនុំទំនៀមទម្លាប់

–ផ្នែកបោះពុម្ពផ្សាយ ។

ក្នុងផ្នែកនីមួយ ១ ទីប្រជុំបានពិនិត្យពិភាក្សា នូវបញ្ហាដែលមានការលំបាកខ្វះ ១ ក្នុងកិច្ចការសព្វថ្ងៃ ដូចជា :-

១– ចំពោះអគ្គលេខាធិការដ្ឋាន ឃើញថា មានការលំបាកខ្លាំង ត្រង់ខ្វះភ្នាក់ងារបំរើការ ដូចជាលេខាហារី-ឆ្មាំ កម្មករ ។ ហេតុនេះ ការប្រញាប់គឺត្រូវធ្វើយ៉ាងណា ឲ្យបានលេខាហារីពីរនាក់ ឆ្មាំម្នាក់ និងកម្មករម្នាក់មកបន្ថែម ឲ្យមានចំនួនដូចដើមវិញ ដើម្បីធ្វើការឲ្យបានស្រួល កុំឲ្យរអាក់រអួល ។

២– ក្នុងបណ្ណាល័យ ត្រូវតែកែប្រែបទបញ្ញត្តិខ្វះ ដោយការលៃលកតម្រូវទៅតាមកាលៈទេសៈសព្វថ្ងៃនេះ ។

៣– ក្រុមជំនុំព្រះត្រៃបិដក មានបញ្ហាគួរគិតជាពិសេសគឺ ត្រូវចាប់ធ្វើវចនានុក្រមបាលី-ខ្មែរ ដែលគាំងពីយូរមកហើយ ក្រុមនេះផ្តើមធ្វើបានខ្វះ

ហើយនោះ ឲ្យបានគេទៅទៀត លុះគ្រាតែបានសម្រេច ។ ឯការផ្សាយ
ប្រែព្រះត្រៃបិដក ពិតមែនតែបានប្រែរួចចប់សព្វគ្រប់ ដល់ភាគទី ១១០
ហើយមែន តែការបោះពុម្ព ពុំទាន់បានហើយស្រេចនៅឡើយ ។
សព្វថ្ងៃនេះ បោះពុម្ពបាន៨៤ភាគហើយ គឺពី ភាគ ១ ដល់ ៨៤ នៅខ្វះ
២៦ ភាគទៀតគឺ ពីភាគ ៨៥ ដល់ភាគ ១១០ ។ ម្យ៉ាងទៀត មុខងារនៃ
ក្រុមនេះ មិនមែនមានការៈត្រឹមតែការប្រែព្រះត្រៃបិដកប៉ុណ្ណោះទេ គឺត្រូវ
ប្រែរឿងបញ្ញាជាតក និងអដ្ឋកថាជាច្រើនទៀត នៃគម្ពីរព្រះពុទ្ធសាសនា។
ដូច្នេះ ឃើញថា ទោះបីការបោះពុម្ពព្រះត្រៃបិដកនេះ ជិតនឹងបានចប់សព្វ
គ្រប់ហើយ ក៏គង់នៅមានការងារច្រើនធំទូលាយណាស់ទៅទៀត ។
ត្រូវជួបសម្ដេចព្រះពោធិវង្សអធិបតី និងព្រះសង្ឃជាសមាជិកនៃក្រុមជំនុំ
នេះ នៅពេលក្រោយ ។

៤– ក្នុងក្រុមជំនុំទំនៀមទម្លាប់ មានបញ្ហាមួយគឺ ខ្វះបទបញ្ញត្តិផ្ទៃក្នុង
សម្រាប់សម្រេចកិច្ចការផ្សេងៗ ដូចជាការកំណត់ប្រាក់ឈ្នួលនៃសមាជិក
ដែលប្រឡងជាប់ខាងឯកសារទំនៀមទម្លាប់ជាដើម ។ រឿងនេះ
សម្រេចថានឹងធ្វើឡើង នៅពេលប្រជុំលើកក្រោយ ។

៥– ផ្នែកបោះពុម្ពផ្សាយ ដោយខ្វះបុគ្គលិកបច្ចេកទេសចាស់ទុំ ដែលមាន
សមត្ថភាព និងការពិសោធន៍គ្រប់គ្រាន់ សព្វថ្ងៃនេះ ពុំបានធ្វើសៀវភៅ
ថ្មីៗទេ គឺមានការកិច្ច ត្រឹមតែពិនិត្យវិញ្ញាសាពុម្ព នៃសៀវភៅចាស់ៗ

ដែលបានដាំអស់ទៅ ហើយត្រូវបោះពុម្ពឡើងវិញ ហើយនឹងបោះពុម្ពផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា តែប៉ុណ្ណោះ ។ ការនេះ គួរដោះស្រាយយ៉ាងណា ឲ្យបានរីកចម្រើនផង ។

ក្រោយពីការពិភាក្សា ឃើញការលំបាកខ្លះៗ នេះមក លោកនាយកបានស្នើសុំទីប្រជុំឲ្យផ្ដល់ នូវគោលការខ្លះគឺ :-

ក- បណ្ណាល័យ ក្រុមជំនុំព្រះត្រៃបិដក ក្រុមជំនុំទំនៀមទំលាប់ និងក្រុមបោះពុម្ពផ្សាយ សុំឲ្យធ្វើសេចក្ដីរាយការ ឬកំណត់ប្រវត្តិហេតុរបស់ក្រុមនីមួយៗ និយាយពីដើមកំណើតនៃក្រុម មុខងារនៃក្រុម សកម្មភាពនៃក្រុម និងលទ្ធផលនៃក្រុមទាំងនេះ ដើម្បីជូនចំពោះលោកនាយក និងលោកអគ្គលេខាធិការ ដែលទើបចូលកាន់កាប់មុខតំណែងថ្មី ឲ្យបានជ្រាបកិច្ចការសព្វគ្រប់ផង ។

ខ- ខាងគណនេយ្យ ក៏សុំឲ្យធ្វើតុល្យការប្រចាំឆ្នាំ ដើម្បីឲ្យបានដឹងច្បាស់នូវស្ថានភាពនៃឥណទានក្រុមយើង ដោយមានប្រៀបធៀបពីឆ្នាំមុននិងឆ្នាំនេះ ព្រមទាំងបញ្ជាក់នូវចំនួនប្រាក់-សៀវភៅ-ទឹកខ្វែងលក់-បេឡាផង ។

គ- ធ្វើតារាងតំរោងរាយនាមបុគ្គលិក ព្រមទាំងមុខងារ តាមផ្នែកផ្សេងៗ ។

ឃ ធ្វើការបុះទិដ្ឋាការ លើលិខិតនៃប្រាក់ចំណូលប្រចាំថ្ងៃ គឺសុំ

ឲ្យលោកអគ្គលេខាធិការ ចុះហត្ថលេខាមុនសិន ទើបយកទៅបង់ឲ្យបេឡាធិការជាក្រោយ ។

ង- ជូនមុខងារ ទៅលោកអគ្គលេខាធិការ ជាបណ្ដោះអាសន្ន ឲ្យចុះហត្ថលេខា លើលិខិតផ្សេងៗ គ្រប់យ៉ាង ជាជំនួសលោកនាយក ទំរាំមានព្រះរាជក្រិត្យតែងតាំងនាយកនេះ ចេញជាផ្លូវការមក ។

ច- ស្នើសុំលៃលក រកពេលប្រជុំ លើកក្រោយទៀត ដើម្បីគិតគូរ ពិនិត្យឲ្យច្បាស់លាស់ នូវបញ្ហាលំបាកខ្លះ ក្នុងក្រុមជំនុំទំនៀមទម្លាប់ ។ ចាំណាត់ពេលជាក្រោយ ។

ឆ- គ្រោងទុកពេលសម្រាប់ជំនុំពិនិត្យ ពីផ្នែកបោះពុម្ពផ្សាយ ។ ណាត់ពេលជំនុំថ្ងៃក្រោយ ។

ជ- បញ្ហាលក់សៀវភៅ ឲ្យបានទូលំទូលាយថែមទៀត ។ ណាត់ពេលជំនុំថ្ងៃក្រោយ ។

ឈ- សុំឲ្យសហការី មានលោកអគ្គលេខាធិការ វៀល-ហេង ជាដើម ជួយពិនិត្យសេចក្ដីព្រាងព្រះរាជក្រិត្យ ស្ដីពីការរៀបចំក្រុមពុទ្ធសាសនបណ្ឌិត្យ ដើម្បីធ្វើឲ្យបានសម្រេចក្នុងពេលឆាប់ៗ នេះ តាមបញ្ជារបស់ ឯ.ឧ. អនុរដ្ឋលេខាធិការក្រសួងធម្មការ ។

ថ្ងៃអង្គារទី ១៧-៨-៦៥ ជួបជុំគ្នាពិនិត្យរឿងនេះទៀត ។

លោកប្រធានទីប្រជុំ បានប្រកាសបិទពេលជំនុំ នៅម៉ោង ១២ កន្លះ ។

លេខ ៦៦៣-ប.រ. ព្រះរាជអាណាចក្រកម្ពុជា

# ព្រះរាជក្រឹត្យ

## សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ

## ជាព្រះប្រមុខរដ្ឋ

បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រ

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ-៨៧០ប.រ ចុះថ្ងៃទី ២៥ ធ្នូ ១៩៦៤ កែប្រែដោយអត្ថបទបន្តបន្ទាប់គ្នា ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី

បានទ្រង់យល់ព្រះរាជក្រមលេខ ៧៩៣ ន.ស. ចុះថ្ងៃទី ៣ មិថុនា ១៩៥៣ ស្តីពីការកំរិតលក្ខន្តិកៈ នៃអ្នករាជការរដ្ឋបាលទាំងឡាយក្នុងព្រះរាជអាណាចក្រ ក្រៅពីអ្នករាជការតុលាការ

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣៦៥ ប.រ. ចុះថ្ងៃទី ២៧ កញ្ញា ១៩៦០ កែប្រែនិងបន្ថែមដោយអត្ថបទបន្តបន្ទាប់គ្នា កំរិតលក្ខន្តិកៈ នៃសាស្ត្រាចារ្យមធ្យមសិក្សាជាន់ដំបូង

បានទ្រង់យល់ព្រះរាជក្រមលេខ ២១៦ ន.ស. ចុះថ្ងៃទី ២ កញ្ញា ១៩៥៧ ស្តីពីលក្ខខណ្ឌនៃការវិវត្តន៍នៃក្រុមពុទ្ធសាសនបណ្ឌិត្យ

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១២៨ ន.ស. ចុះថ្ងៃទី ៣ មេសា ១៩៥២ ស្តីអំពីការរៀបចំជាថ្មីនូវក្រសួងធម្មការនិងសាសនសិក្សាធិការ

បានទទួលស្គាល់ព្រះរាជក្រមលេខ ៤២២ ន.ស. ចុះថ្ងៃទី ១៤ កុម្ភៈ ១៩៤៨ មានបន្ថែមដោយព្រះរាជក្រមលេខ ៨១'ន.ស ចុះថ្ងៃទី ១០ កញ្ញា ១៩៥៣ បានកំណត់ទូវប្រាក់បំណាច់នៃមុខងារ ដែលឲ្យភ្នាក់ងាររាជការក្នុងព្រះរាជអាណាចក្រ

តាមសេចក្តីក្រាបបង្គំទូលស្នើសុំនៃរដ្ឋមន្ត្រីក្រសួងធម្មការ

ទ្រង់ត្រាស់បង្គាប់ដូចមានខាងក្រោមនេះ:

មាត្រា១- លោក លាង-ហ័បអាន សាស្ត្រាចារ្យថ្នាក់ទី ៣ នៃមធ្យមសិក្សាជាន់ដំបូង ដែលបានផ្លាស់មកធ្វើការនៅក្រសួងធម្មការ ត្រូវតែងតាំងជានាយកនៃក្រុមពុទ្ធសាសនបណ្ឌិត្យ

មាត្រា២- ក្នុងឋានៈនេះ លោក លាង-ហ័បអាន ត្រូវបានទទួលប្រាក់បំណាច់មុខងារ ស្មើនឹងប្រាក់បំណាច់ដែលនាយកនៃសិក្សាធារណៈត្រូវបាន ដូចមានចែងទុកក្នុងច្បាប់ជាធរមានបញ្ញត្តិ ។

មាត្រា៣- រដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវទទួលការចាត់ការឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញថ្ងៃទី ២៨ តុលា ឆ្នាំ ១៩៦៥

សម្តេចទ្រង់ឡាយព្រះហស្តលេខា : នរោត្តម-សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា នៃសម្តេចព្រះប្រមុខរដ្ឋ
រដ្ឋមន្ត្រីក្រសួងធម្មការ
ហត្ថលេខា : អ៊ុន-តាំ

ទទួលព្រះបញ្ជានៃសម្តេចព្រះប្រមុខរដ្ឋ
នាយករដ្ឋមន្ត្រី
ព្រះហស្តលេខា ; នរោត្តម-កន្តុល

ទិដ្ឋាការ ប្រ ច ណ
ថ្ងៃទី ៣-៨-៦៥ លេខ ១៨
អ្នកត្រួតត្រានូវប្រាក់ចំណាយ
ហត្ថលេខា ប៉ែន-សេង

បានចម្លងដើម្បីចែក :
អគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រី
ហត្ថលេខា អ៊ុក-សុខ

*អ្នកទទួល :*
- ឧត្តមក្រុមប្រឹក្សាព្រះរាជបល្លង្ក
- អគ្គនាយកដ្ឋាននៃក្រុមនានាក្នុងព្រះបរមរាជវាំង
- ខុទ្ទកាល័យនៃសម្តេចព្រះប្រមុខរដ្ឋ
- រដ្ឋសភា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ
- នាយករដ្ឋមន្ត្រី-រាជកិច្ច
- គ្រប់ទីស្តីការរដ្ឋមន្ត្រី
- សាមីរូប

បានចម្លងត្រឹមត្រូវតាមដើមហើយ
ផ. រដ្ឋមន្ត្រីក្រសួងធម្មការ
ហត្ថលេខា : បន្ទ-សុន

បានចម្លងត្រឹមត្រូវតាមដើមហើយ
នាយកពុទ្ធសាសនបណ្ឌិត្យ
ហត្ថលេខា ណាង-ហ៊ាប់អាន